

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

យុទ្ធសាស្ត្រ
ស្តីពី
ការគ្រប់គ្រងបំណុលសាធារណៈ
២០១៩ - ២០២៣



រៀបចំដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បុព្វកថា

ចាប់តាំងពីឆ្នាំ១៩៩៣ ដែលជាឆ្នាំដំបូងនៃការចាប់ផ្តើមខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសម្រាប់យកមកកសាង, ស្តារ, និងអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលតែងប្រកាន់ខ្ជាប់នូវស្មារតីប្រយ័ត្នប្រយែងខ្ពស់ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដោយបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះៗ ចំនួន ៤ រួមមាន៖

១) ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន;
២) ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់;
៣) ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម; និង
៤) ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

ឈរលើគោលការណ៍គន្លឹះទាំង ៤ នេះ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ចំនួន ២លើក គឺ៖ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១ - ២០១៨ និងយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ ដែលបានដាក់ចេញនូវវិធានការគន្លឹះមួយចំនួន ក្នុងការបន្តធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព នៃការគ្រប់គ្រងបំណុលសាធារណៈ។

តាមរយៈនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ទាំង ២ នេះ, ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រូវបានបន្តរក្សា **«ចីរភាព»** និងមាន **«ហានិភ័យកម្រិតទាប»**។ ការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយប្រសិទ្ធភាពខ្ពស់ បានរួមចំណែកសម្រេចបាននូវសមិទ្ធផលធំៗជាសារវន្តជាច្រើន រួមមាន៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, រោងចក្រផលិតថាមពលអគ្គិសនី, បណ្តាញបញ្ជូននិងចែកចាយថាមពលអគ្គិសនី, ស្ថានីយ៍ផលិតនិងបណ្តាញផ្គត់ផ្គង់ទឹកស្អាត, ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ប្រព័ន្ធធារាសាស្ត្រ, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ, ការលើកកម្ពស់គុណភាពអប់រំ និងការផ្តល់សេវាសុខាភិបាល ជាដើម។ សមិទ្ធផលធំៗទាំងនេះ គឺជាចលករដ៏សំខាន់និងមិនអាចខ្វះបាន ក្នុងការរួមចំណែកសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរង្វង់ជាមធ្យមប្រមាណ **៧,៧ ភាគរយ** ក្នុងមួយឆ្នាំ ក្នុងរយៈកាលជាងពីទសវត្សរ៍ចុងក្រោយ និងកាត់បន្ថយអត្រានៃភាពក្រីក្ររបស់ប្រជាជន មកនៅត្រឹមរង្វង់ **១០ ភាគរយ** ក្នុងឆ្នាំ២០១៨។

ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបានសកម្មចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់នូវរាល់វិធានការគន្លឹះៗ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈទាំង ២ ដំណាក់កាលកន្លងមក និងសូមកោតសរសើរចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចយ៉ាងខ្ជាប់ខ្ជួន ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល លើការដឹកនាំអនុវត្តយុទ្ធសាស្ត្រទាំង ២ ដំណាក់កាលនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងសម្រេចបាននូវភាពជោគជ័យគួរជាទីមោទនៈ។

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលធំៗជាសារវន្តខាងលើ និងក្នុងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចកម្ពុជាដែលកាន់តែរីកលូតលាស់និងមានភាពស្មុគស្មាញ ហើយកំណើនអតិរេកចរន្តសម្រាប់បម្រើឱ្យតម្រូវការវិនិយោគ

សាធារណៈ អាចនឹងថមថយជាយថាហេតុ ដោយសារថវិកាជាតិមួយផ្នែកធំត្រូវចំណាយលើមុខសញ្ញាជាអាទិភាពចំពោះមុខមួយចំនួន ដូចជា៖ ការដំឡើងប្រាក់បៀវត្ស, ការពង្រឹងប្រព័ន្ធគាំពារសង្គម, និងការអនុវត្តវិធានការជាកញ្ចប់ក្នុងការពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ទប់ទល់នឹងការគំរាមកំហែងពីខាងក្រៅ, រាជរដ្ឋាភិបាលមើលឃើញពីភាពចាំបាច់ដែលត្រូវបង្កើនការខ្វីច្រើនជាងមុន ដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការទុនវិនិយោគដ៏គំហុក ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ខណៈដែលកម្ពុជា៖ ១) មានសមត្ថភាពខ្វីខ្ពស់ជាងមុន, ២) នៅមានឱកាសខ្វីបានថោក, ៣) មានដៃគូអភិវឌ្ឍន៍ជាច្រើនកំពុងត្រៀមផ្តល់កិច្ចសហប្រតិបត្តិការ, និង ៤) មានសក្តានុពលខ្លាំងក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានបន្ថែម តាមរយៈការកៀរគរទុនពីទីផ្សារមូលបត្រ និងពីវិស័យឯកជន។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវ **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»** ដែលជាយុទ្ធសាស្ត្រមានភាពរឹងមាំ និងកាន់តែម្ចាស់ការជាងមុន សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរន្តាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣» ដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ ចំនួន ១០ ហើយនៅតែបន្តអនុវត្តគោលការណ៍គន្លឹះទាំង៤ ខាងលើ និងបន្ថែមនូវគោលការណ៍គន្លឹះទី៥ មួយទៀត សំដៅបន្តពង្រឹងប្រសិទ្ធភាពទាំងការគ្រប់គ្រងបំណុលសាធារណៈ និងទាំងការគ្រប់គ្រងការវិនិយោគសាធារណៈ គឺ៖ *«ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ជានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ»*។

ជាថ្មីម្តងទៀត, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបាននាំមុខក្នុងការរៀបចំ **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»** ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់, ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងបន្តចូលរួមសហការពេញលេញជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តរាល់វិធានការជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញក្នុង **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»** ប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃ ចន្ទ ៩ ៤៣៤ ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១៩

ស្នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អារម្ភកថា

ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, កម្ពុជាបានប្រែក្លាយពីប្រទេសដែលមានហានិភ័យបំណុលកម្រិតខ្ពស់ មកជាប្រទេសមានស្ថានភាពបំណុលសាធារណៈប្រកបដោយ **«ចីរភាព»** និងមាន **«ហានិភ័យកម្រិតទាប»** ព្រមទាំងត្រូវបានវាយតម្លៃនិងទទួលស្គាល់ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗថា ជាប្រទេសគំរូមួយ ដែលគ្រប់គ្រងបំណុលសាធារណៈបានល្អប្រសើរ និងមានភាពប្រយ័ត្នប្រយែងខ្ពស់។ ជាក់ស្តែង ពិន្ទុសូចនាករគោលនយោបាយបំណុលសាធារណៈរបស់កម្ពុជា បានកើនឡើងជាលំដាប់ ពី **៣,៥** ពិន្ទុ នៅឆ្នាំ២០០៥ ទៅ **៥,០** ពិន្ទុ ចាប់ពីឆ្នាំ២០១២ មក ធៀបនឹងពិន្ទុល្អបំផុត (អតិបរមា) **៦,០**។

សមិទ្ធផលសំខាន់ៗ ដែលរាជរដ្ឋាភិបាលសម្រេចបាន ក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ មានជាអាទិ៍៖ ១) កៀរគរហិរញ្ញប្បទានឥតសំណង បានប្រមាណ **២,៦ ប៊ីលានដុល្លារអាមេរិក** ដើម្បីសម្រាលបន្ទុកនៃការខ្ចីឥណទាន, ២) កៀរគរ និងសម្រិតសម្រាំងឥណទានដែលមានកម្រិតសម្បទានខ្ពស់និងហានិភ័យទាប បានប្រមាណ **៤,៥ ប៊ីលានដុល្លារអាមេរិក** ដោយបានគ្រប់គ្រងទំហំនៃការខ្ចីប្រចាំឆ្នាំឱ្យស្ថិតក្រោមពិដានដែលកំណត់ដោយច្បាប់, ៣) បានប្រើប្រាស់ឥណទានសម្បទានទាំងនោះចំគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល, និង ៤) បានគ្រប់គ្រងហានិភ័យបំណុលពាក់ព័ន្ធទាំងអស់ មិនឱ្យប៉ះពាល់ដល់ចីរភាពនៃបំណុលសាធារណៈ។

ថ្វីត្បិតតែសម្រេចបាននូវសមិទ្ធផលដ៏ធំធេងទាំងនេះក្តី ក៏រាជរដ្ឋាភិបាលមិនដែលភ្លេចខ្លួន ឬព្រងើយកន្តើយ ក្នុងការបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលសាធារណៈឡើយ។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ទ្វេដង ក្នុងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់ សំដៅបន្តរក្សាបាននូវចីរភាពបំណុលរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាប។

អនុលោមតាមលក្ខខណ្ឌតម្រូវនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ រូបខ្ញុំ, **អូន ព័ន្ធមុនីរ័ត្ន**, ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ បានចាត់តាំងក្រុមការងារមួយ ក្រោមការដឹកនាំ សម្របសម្រួលកម្រិតគោលនយោបាយរបស់ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ឥន្ទ្រី ឥស្សរ** និងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យទទួលការកិច្ចរៀបចំសេចក្តីព្រាង **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»** ដែលធានាបាននូវភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចដែលកាន់តែរីកលូតលាស់ និងមានភាពស្មុគស្មាញជាងមុន ព្រមទាំងរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ធឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣» ត្រូវបានរៀបចំឡើងអនុលោមតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្តជាអន្តរជាតិ ដោយបានត្រួតពិនិត្យ និងវិភាគលើគ្រប់ទិដ្ឋភាពពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ រួមមាន៖ វឌ្ឍនភាព, ហានិភ័យ, បញ្ហាប្រឈម, និងកាលានុវត្តភាព ហើយដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ ចំនួន ១០ ដូចខាងក្រោម៖

១-កំណត់ទំហំនៃការខ្ចីថ្មីបន្ថែម ក្នុងមួយឆ្នាំ ក្នុងរង្វង់ពី **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែរ** សម្រាប់ឆ្នាំ២០១៩ - ២០២៣។ ក្នុងកាលៈទេសៈចាំបាច់ នឹងបង្កើនដល់រង្វង់ **៣ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ តែទំហំនៃការខ្ចីថ្មីបន្ថែមពីក្រៅប្រទេសសរុប ក្នុងរយៈពេល ៥ ឆ្នាំនេះ មិនត្រូវលើសពី **១១ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ១៥ ប៊ីលានដុល្លារអាមេរិក) ឡើយ។

២-កំណត់ពិដានៃសូចនាករបំណុលគន្លឹះៗ ដែលត្រូវគ្រប់គ្រងនិងតាមដាន ចំនួន ៥ ដូចខាងក្រោម៖

- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផសស ត្រូវស្ថិតក្រោម **៥៥%** ដែលក្នុងនោះ៖
  - អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស (រួមទាំងបំណុលដែលមានការធានាពីរដ្ឋ)ធៀបនឹង ផសស ត្រូវស្ថិតក្រោម **៤0%**
  - អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្នុងប្រទេស (រួមទាំងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹង ផសស ត្រូវស្ថិតក្រោម **១៥%**
- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ ត្រូវស្ថិតក្រោម**១៨0%**
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ ត្រូវស្ថិតក្រោម **១៥%**
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ ត្រូវស្ថិតក្រោម **១៨%**។

៣-បន្តខ្ចីសម្រាប់តែវិស័យអាទិភាព ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេស វិស័យបង្កើនផលិតភាពផលិតកម្ម, ជំរុញការតភ្ជាប់, និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង។

៤-បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការវិនិយោគសាធារណៈ តាមរយៈនៃការអនុវត្ត «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»។

៥-បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យទូលំទូលាយជាងមុន ពីដៃគូអភិវឌ្ឍន៍, ពីទីផ្សារមូលបត្រ (ទាំងក្នុង និងក្រៅប្រទេស), និងពីវិស័យឯកជន។

៦-បន្តពង្រឹងការតាមដាន និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ដែលវិធានការគន្លឹះៗ ចំពោះហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ មានដូចខាងក្រោម៖

- បន្តមិនផ្តល់ការធានាឥណទានចំពោះវិស័យឯកជន។
- បន្តវិភាជន៍ថវិកា ក្នុងរង្វង់ **៥ ភាគរយ នៃ សេវាបំណុលសរុបប្រចាំឆ្នាំ** ទៅក្នុង**មូលនិធិបម្រុង (Contingency Fund)** សម្រាប់ត្រៀមដោះស្រាយការធានារបស់រដ្ឋ ដែលនឹងអាចកើតឡើងជាយថាហេតុ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏អាចយកមូលនិធិនេះទៅវិនិយោគដើម្បីបានចំណូលជាគុណប្រយោជន៍ថវិកាជាតិ ផងដែរ។
- កំណត់ពិដាននៃការធានាទូទាត់សរុប សម្រាប់គម្រោងថ្មី មិនឱ្យលើសពី **១0 ភាគរយ នៃចំណូលថវិកាជាតិ**។ ពិដាននេះ នឹងត្រូវបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម ជារៀងរាល់ឆ្នាំ ដើម្បីធានាបាននូវសង្គតិភាពជាមួយក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។
- ធនាគារជាតិនៃកម្ពុជា ត្រូវបន្តសិក្សា និងតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន និងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីវិស័យធនាគារនិងហិរញ្ញវត្ថុ ហើយចែករំលែកព័ត៌មាននិងទិន្នន័យទាំងនោះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងត្រូវពង្រឹងការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ, និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ប្រកបដោយភាពម៉ឺងម៉ាត់ និងប្រសិទ្ធភាពខ្ពស់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័នមួយ ដើម្បី៖ ១) សិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសនានា ក្នុង

គោលបំណងបន្តពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ និង ២) ចងក្រងព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ សម្រាប់ជាគុណប្រយោជន៍នៃការវិភាគ និងគ្រប់គ្រងហានិភ័យ។

៧-បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមមាត្រា ៦៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមាត្រា ៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

៨-បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី តាមរយៈការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមការចាំបាច់។

៩-បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ រួមមាន៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, និង ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

១០ - បន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមគោរពសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលតែងតែផ្តល់ការណែនាំ និងចង្អុលបង្ហាញជាប្រចាំ ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលលើការងារគ្រប់គ្រងបំណុលសាធារណៈ។ ជាមួយគ្នានេះ, ខ្ញុំសូមគោរពដឹងគុណចំពោះ ឯកឧត្តមកិត្តិបរិក្សបណ្ឌិត **គាត ឈន់** ដែលបានកសាងនូវមូលដ្ឋានគ្រឹះដ៏រឹងមាំ ប្រកបដោយវិន័យច្បាស់លាស់ ដែលជាមរតកមិនអាចកាត់ថ្លៃបានក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានកិច្ចសហការពេញលេញពីក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងបន្តប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះទាំង ៥ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុង **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»** សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ធឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ថ្ងៃ អង្គារ ៩កើត *ខែ* អស្សុជ *ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣*
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ *ខែ* តុលា *ឆ្នាំ*២០១៩

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ



អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

មាតិកា

ជំពូកទី១៖ សេចក្តីផ្តើម ១
ជំពូកទី២៖ គោលបំណង, គោលដៅ, និងវិសាលភាព ៣
២.១. គោលបំណង ៣
២.២. គោលដៅ ៣
២.៣. វិសាលភាព ៣
ជំពូកទី៣៖ វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ ..... ៤
ជំពូកទី៤៖ ហានិភ័យ, បញ្ហាប្រឈម, និងកាលានុវត្តភាព ៦
៤.១. ហានិភ័យ ៦
៤.២. បញ្ហាប្រឈម ៦
៤.២.១. ការគំរាមកំហែងពីខាងក្រៅ ៦
៤.២.២. ភាពរឹងស្លូតនៃហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ ៦
៤.២.៣. យន្តការចំពោះកិច្ច សម្រាប់គម្រោង PPP ៧
៤.២.៤. បញ្ហាប្រឈមពាក់ព័ន្ធផ្សេងទៀត ៧
៤.៣. កាលានុវត្តភាព ៨
៤.៣.១. ការកើនឡើងនូវសមត្ថភាពខ្ចី ៨
៤.៣.២. លទ្ធភាពក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន ៨
៤.៣.៣. ការចូលរួមពីវិស័យឯកជនក្នុងការវិនិយោគសាធារណៈ ៨
៤.៣.៤. ភាពរីកចម្រើននៃវិស័យធនាគារ និងហិរញ្ញវត្ថុ ៩
៤.៣.៥. លទ្ធភាពក្នុងការបោះផ្សាយមូលបត្ររដ្ឋ ៩
ជំពូកទី៥៖ ការវិភាគចីរភាពបំណុល ១០
៥.១. ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រឹមដំណាច់ឆ្នាំ២០១៨ ..... ១០
៥.២. តម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈ ១០
៥.៣. សេណារីយ៉ូនៃការខ្ចីថ្មីបន្ថែម ១១
៥.៤. លទ្ធផលនៃការវិភាគ ១១
ជំពូកទី៦៖ វិធានការជាយុទ្ធសាស្ត្រ ១៣
៦.១. កំណត់ពិដាននៃការខ្ចីថ្មីបន្ថែម ១៣
៦.២. កំណត់ពិដាននៃសូចនាករបំណុលគន្លឹះៗ ដែលត្រូវគ្រប់គ្រង និងតាមដាន ១៣
៦.៣. បន្តខ្ចីសម្រាប់តែវិស័យអាទិភាព ១៤
៦.៤. បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ១៤

៦.៥. បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យទូលំទូលាយជាងមុន ១៤
៦.៥.១. ដៃគូអភិវឌ្ឍន៍ ១៥
៦.៥.២. ទីផ្សារមូលបត្រ ១៥
៦.៥.៣. វិស័យឯកជន ១៦
៦.៦. បន្តពង្រឹងការតាមដាន និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ១៦
៦.៧. បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ១៧
៦.៨. បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី ១៨
៦.៩. បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ ១៨
៦.១០. បន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ១៨
ជំពូកទី៧៖ ការតាមដាន, ត្រួតពិនិត្យ, និងការវាយតម្លៃលើការអនុវត្តវិធានការជាយុទ្ធសាស្ត្រ ១៩

ឧបសម្ព័ន្ធ៖

- ឧបសម្ព័ន្ធ ១៖ សទ្ធានុក្រម
- ឧបសម្ព័ន្ធ ២៖ វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨
- ឧបសម្ព័ន្ធ ៣៖ ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣
- ឧបសម្ព័ន្ធ ៤៖ ក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៩ - ២០២៣
- ឧបសម្ព័ន្ធ ៥៖ ការវិភាគចីរភាពបំណុល ២០១៩ - ២០២៩
- ឧបសម្ព័ន្ធ ៦៖ ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣

ជំពូកទី១
សេចក្តីផ្តើម

ជំពូកទី១
សេចក្តីផ្តើម

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ជាមួយស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរង្វង់ជាមធ្យមប្រមាណ **៧,៧ ភាគរយ** ក្នុងមួយឆ្នាំ ដោយ ផសស ក្នុងមនុស្សម្នាក់ បានកើនឡើង ៤ ដង ពោលគឺ ពី **៤១៧ ដុល្លារអាមេរិក** ក្នុងឆ្នាំ២០០៤ ដល់ប្រមាណ **១ ៥៦៣ ដុល្លារអាមេរិក** នៅក្នុងឆ្នាំ២០១៨ ខណៈអត្រាភាពក្រីក្រត្រូវបានបន្តធ្លាក់ចុះជាលំដាប់ពីប្រមាណ **៥៤ ភាគរយ** ក្នុងឆ្នាំ២០០៤ មកត្រឹម **១៣,៥ ភាគរយ** ក្នុងឆ្នាំ២០១៤ ហើយត្រូវបានប៉ាន់ស្មានថាស្ថិតនៅក្នុងរង្វង់ **១០ ភាគរយ** ក្នុងឆ្នាំ២០១៨។ ទន្ទឹមនេះ វិសមភាពដែលត្រូវបានវាស់វែងដោយមេគុណជីនីបានបន្តធ្លាក់ចុះពី **០,៣៨** ក្នុងឆ្នាំ២០០៤ មកត្រឹម **០,២៩** ក្នុងឆ្នាំ២០១៤ ដែលជាកម្រិតល្អប្រសើរនៅក្នុងចំណោមប្រទេសសមាជិកអាស៊ាន ហើយក៏ត្រូវបានរំពឹងថា នឹងបន្តធ្លាក់ចុះថែមទៀត។

ជាមោទនភាព, នៅឆ្នាំ២០១៥ កម្ពុជាបានឆ្លងចូលរបត់នៃការអភិវឌ្ឍថ្មីរបស់ខ្លួន គឺការឈានឡើងចំណាត់ថ្នាក់ពីប្រទេសដែលមានចំណូលទាប (Low-Income Country) មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប (Lower Middle-Income Country) ព្រមទាំងត្រូវបានធនាគារអភិវឌ្ឍន៍អាស៊ីប្រសិទ្ធនាមថាជា **«ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី»** (Asia's New Tiger Economy) ហើយត្រូវបានធនាគារពិភពលោកចាត់ចូលជាប្រទេសមួយក្នុងចំណោម **«ប្រទេសឯកទគ្គកកំណើនសេដ្ឋកិច្ច»** (World's Fastest Growing Economies) នៅក្នុងសកលលោកផងដែរ។ ជាតថភាព, ភាពជោគជ័យគួរជាទីមោទនៈនេះ មិនអាចកាត់ផ្តាច់ចេញពីការរួមចំណែកនៃការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយចីរភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពឡើយ។

ឆ្លងតាមបទពិសោធន៍ជាអន្តរជាតិរបស់បណ្តាប្រទេសនានាលើសកលលោក ការគ្រប់គ្រងបំណុលសាធារណៈ បានរួមចំណែកយ៉ាងសំខាន់ដល់ការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងគ្រប់គ្រងហានិភ័យនៃវិបត្តិបំណុលចំពោះសេដ្ឋកិច្ចនិងថវិកាជាតិ។ ជាគោលការណ៍ ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈរឹងមាំ ត្រូវរួមផ្សំដោយសមាសធាតុជាសារវន្តមួយចំនួន ជាអាទិ៍៖ ១) ក្របខ័ណ្ឌគតិយុត្ត, ២) គោលនយោបាយ, យុទ្ធសាស្ត្រ, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគ្រប់ជ្រុងជ្រោយ, ៣) សមត្ថភាពស្ថាប័ន និងធនធានមនុស្សគ្រប់គ្រាន់, និង ៤) ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងប្រតិបត្តិការ និងរក្សាទុកទិន្នន័យ ដើម្បីជាមូលដ្ឋាននៃការវិភាគ និងតាមដានហានិភ័យបំណុលៗល។

តាំងពីឆ្នាំ១៩៩៣មក, រាជរដ្ឋាភិបាលតែងប្រកាន់ខ្ជាប់នូវស្មារតីប្រយ័ត្នប្រយែងខ្ពស់ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដោយបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះៗ ចំនួន ៤ រួមមានៈ ១) ខ្វីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន, ២) ខ្វីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់, ៣) ខ្វីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម, និង ៤) ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

ឈរលើគោលការណ៍គន្លឹះទាំង ៤ ខាងលើ និងមានអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈជាគោល, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈចំនួន២លើក រួចមកហើយ គឺ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១ - ២០១៨ និងយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ ដោយរួមបញ្ចូលទាំងក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ, ការវិភាគចីរភាពបំណុល, និងផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ។ យុទ្ធសាស្ត្រទាំងពីរនេះ បាន

ដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ ដោយរក្សាបាននូវចីរភាពបំណុល និងកម្រិតហានិភ័យឱ្យនៅទាប សម្រាប់ជំរុញ និងបង្កើនល្បឿននៃការវិនិយោគសាធារណៈ ក្នុងវិស័យអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល រួមមាន៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, រោងចក្រផលិតថាមពលអគ្គិសនី, បណ្តាញបញ្ជូននិងចែកចាយថាមពលអគ្គិសនី, ស្ថានីយ៍ផលិតនិងបណ្តាញផ្គត់ផ្គង់ទឹកស្អាត, ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ប្រព័ន្ធធារាសាស្ត្រ, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ, ការលើកកម្ពស់គុណភាពអប់រំ និងការផ្តល់សេវាសុខាភិបាល ជាដើម។ សមិទ្ធផលធំៗទាំងនេះ បានក្លាយជាកម្លាំងចលករដ៏សំខាន់ និងរឹងមាំក្នុងការរួមចំណែកបន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព។

លើមូលដ្ឋាននៃភាពជោគជ័យដូចបានរៀបរាប់ខាងលើ និងផ្អែកតាមបរិការណ៍ថ្មីរបស់កម្ពុជា, ក្នុងទិសដៅជាយុទ្ធសាស្ត្រ, រាជរដ្ឋាភិបាលចាំបាច់ត្រូវបង្កើនទំហំនៃការខ្ចីច្រើនជាងមុន ដែលក្នុងនោះ មួយចំណែកនឹងត្រូវផ្តល់ឱ្យសហគ្រាសសាធារណៈខ្ចីបន្ត ដោយហេតុថា៖ ១) មានកំណើនតម្រូវការទុនវិនិយោគដ៏គំហុកក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ទាំងទំហំ, បរិមាណ, និងគុណភាព; ២) កំណើនអតិរេកចរន្តសម្រាប់បម្រើឱ្យការវិនិយោគសាធារណៈ អាចនឹងថមថយ ក្នុងបរិការណ៍ ៥ឆ្នាំ ទៅមុខ ដែលថវិកាជាតិមួយផ្នែកធំត្រូវចំណាយលើមុខសញ្ញាអាទិភាពចំពោះមុខ មួយចំនួន រួមមាន៖ ការជំរឿងប្រាក់បៀវត្ស, ការពង្រឹងប្រព័ន្ធគាំពារសង្គម, និងការអនុវត្តវិធានការជាកញ្ចប់ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ទប់ទល់នឹងការគំរាមកំហែងពីខាងក្រៅ; ៣) សមត្ថភាពខ្ចីរបស់កម្ពុជាកើនឡើងខ្ពស់ជាងមុន; ៤) កម្ពុជានៅមានឱកាសខ្ចីបានថោក និងឱកាសស្រូបយកចំណេះដឹង - ចំណេះធ្វើល្អៗបន្ថែមពីក្រៅ; និង ៥) មានដៃគូអភិវឌ្ឍន៍ជាច្រើនផ្សេងទៀតកំពុងត្រៀមផ្តល់កិច្ចសហប្រតិបត្តិការ។ លើសពីនេះ ក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មីនៃសេដ្ឋកិច្ចកម្ពុជា, កម្ពុជានៅមានសក្តានុពលខ្លាំងក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានបន្ថែមទៀត តាមរយៈការកៀរគរទុនពីទីផ្សារមូលបត្រ និងវិស័យឯកជន។

រាជរដ្ឋាភិបាលក៏បានរៀបចំ និងដាក់ឱ្យអនុវត្តផងដែរនូវ «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥» សម្រាប់ពង្រឹងអភិបាលកិច្ចក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ដោយរួមទាំងការខ្ចី តាមរយៈនៃការបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព នៃការបែងចែកនិងការប្រើប្រាស់ធនធានសាធារណៈ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។

សរុបមក ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចដែលកាន់តែរីកលូតលាស់ និងមានភាពស្មុគស្មាញជាងមុន ព្រមទាំងរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ធឆ្ពោះទៅសម្រេចបង្គោលចរន្តឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, រាជរដ្ឋាភិបាលចាំបាច់ត្រូវមានយុទ្ធសាស្ត្រដែលមានភាពរឹងមាំ និងកាន់តែម្ចាស់ការជាងមុន ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដោយនឹងនៅតែបន្តប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះទាំង៤ ខាងលើ និងបន្ថែមនូវគោលការណ៍គន្លឹះទី៥ មួយទៀត គឺត្រូវ៖ ***«ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ជានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ»***។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ នេះ ជា **«ឯកសាររស់»** ដែលអាចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់។

ជំពូកទី២
គោលបំណង,គោលដៅ,
និងវិសាលភាព

ជំពូកទី២
គោលបំណង, គោលដៅ, និងវិសាលភាព

២.១. គោលបំណង

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ មានគោលបំណងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព នៃការគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរន្តាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

២.២. គោលដៅ

យុទ្ធសាស្ត្រនេះ មានគោលដៅកំណត់នូវវិធានការជាយុទ្ធសាស្ត្រ ក្នុងការ៖

១) កៀរគរនិងសម្រិតសម្រាំងធនធានហិរញ្ញវត្ថុ ដែលមានថ្លៃដើមនិងហានិភ័យទាប ដើម្បីបំពេញតម្រូវការទុនវិនិយោគសាធារណៈសរុប ប្រកបដោយប្រសិទ្ធភាព និងបន្តរក្សាបាននូវចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង;

២) ជំរុញការអភិវឌ្ឍទីផ្សារមូលបត្រក្នុងប្រទេស ដើម្បីធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន។

២.៣. វិសាលភាព

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ មានវិសាលភាពគ្របដណ្តប់លើ៖

១) រាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ រួមមាន៖ ការខ្ចីប្រាក់ពីគេ, ការឱ្យប្រាក់គេខ្ចី, ការបោះផ្សាយនិងការដាក់លក់មូលបត្រដ្ឋ, ការធានា, ការវិនិយោគអចលកម្មហិរញ្ញវត្ថុ, និងការគ្រប់គ្រងហានិភ័យបំណុល រួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ;

២) ការតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន សំដៅរួមចំណែកគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមធ្យម និងវែង។

ជំពូកទី៣
ទស្សនាគតនៃការអនុវត្ត
យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង
បំណុលសាធារណៈ
២០១៥ - ២០១៨

ជំពូកទី៣
ទស្សនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨

តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការជាយុទ្ធសាស្ត្រគន្លឹះទាំង ៩ ចំណុច ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាបានវិឌ្ឍទៅរកភាពល្អប្រសើរ ជាលំដាប់។ ជាក់ស្តែង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី បានវាយតម្លៃថា ស្ថានភាពបំណុលសាធារណៈកម្ពុជាមាន «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**» ហើយបានដំឡើងពិន្ទុសូចនាករគោល-នយោបាយបំណុលសាធារណៈរបស់កម្ពុជាជាលំដាប់ គឺពី ៣,៥ ពិន្ទុ នៅឆ្នាំ២០០៥ ទៅ ៥,០ ពិន្ទុ ចាប់ពីឆ្នាំ២០១២ មក ធៀបនឹងពិន្ទុល្អបំផុត (អតិបរមា) ៦,០។

ជារួម សមិទ្ធផលធំៗ និងវឌ្ឍនភាពសំខាន់ៗ ដែលរាជរដ្ឋាភិបាលសម្រេចបាន ក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ មានដូចខាងក្រោម៖

– កៀរគរហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍សរុបបានប្រមាណ **២,៦ ប៊ីលានដុល្លាអាមេរិក** ក្នុងនោះ៖ ប្រមាណ **៣០ ភាគរយ** ត្រូវបានប្រើប្រាស់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រមាណ **៧០ ភាគរយ** ក្នុងវិស័យសេដ្ឋកិច្ច, សង្គមកិច្ច, និងអាទិភាពចំពោះមុខផ្សេងទៀត។

– កៀរគរ និងសម្រិតសម្រាំងឥណទានដែលមានកម្រិតសម្បទានខ្ពស់ និងហានិភ័យទាបពីដៃគូអភិវឌ្ឍន៍សរុបបានប្រមាណ **៣,១ ប៊ីលានអេសដេអ៊ែរ** សមមូលនឹងប្រមាណ **៤,៥ ប៊ីលានដុល្លារអាមេរិក** ដោយបានគ្រប់គ្រងទំហំនៃការខ្ចីប្រចាំឆ្នាំ ឱ្យស្ថិតក្រោមពិដានកំណត់ដោយច្បាប់ និងបានវិភាជន៍ប្រមាណ **៨៧ ភាគរយ** សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រមាណ **១៣ ភាគរយ** សម្រាប់វិស័យអាទិភាពចំពោះមុខផ្សេងទៀត។

– រួមចំណែកជំរុញការកៀរគរធនធានហិរញ្ញវត្ថុពីវិស័យឯកជនមកវិនិយោគសាធារណៈតាមយន្តការ PPP សរុបបានចំនួន **៧ គម្រោង** ដែលមានទឹកប្រាក់សរុបប្រមាណ **៣,៧ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ៖ វិស័យថាមពល ចំនួន **៦ គម្រោង** ស្មើនឹងទឹកប្រាក់ប្រមាណ **២ ប៊ីលានដុល្លារអាមេរិក** និងវិស័យដឹកជញ្ជូន ចំនួន **១ គម្រោង** ស្មើនឹងទឹកប្រាក់ **១,៧ ប៊ីលានដុល្លារអាមេរិក**។

– រួមចំណែកពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន និងគ្រប់កម្រិតរដ្ឋបាល ដោយបានជំរុញការរៀបចំ «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»

– បានបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍មជ្ឈការក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដែលមានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយគត់ ក្រោមការប្រទានសិទ្ធិពីនាយករដ្ឋមន្ត្រី មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ការបោះផ្សាយមូលបត្ររដ្ឋ, ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ, ការវិនិយោគ, ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា, ការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស, និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ។

– បន្តតាមដាន និងត្រួតពិនិត្យយ៉ាងសកម្ម និងបុរេសកម្មលើហានិភ័យបំណុលពាក់ព័ន្ធ ដែលជាលទ្ធផលរួម បានគ្រប់គ្រងមិនឱ្យមានហានិភ័យពាក់ព័ន្ធធំដុំកើតឡើង ប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈទេ។

– បានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈ និងទាំងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

ជាប់ជាប្រចាំ ដែលជាលទ្ធផល ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កសាងបាន នូវធនធានមនុស្សមួយចំនួនដែលមានសមត្ថភាពធ្វើកិច្ចការសំខាន់ៗជាច្រើន ដោយខ្លួនឯងបាន ដូចជា៖ ការ កសាងបទដ្ឋានគតិយុត្ត, គោលនយោបាយ, និងយុទ្ធសាស្ត្រនានា, ព្រមទាំងការវិភាគសំខាន់ៗ, និងកិច្ចការ ពាក់ព័ន្ធ ជាច្រើនផ្សេងទៀត។

– បានបន្តខិតខំប្រឹងប្រែងក្នុងការចរចារដោះស្រាយបំណុលមរតកជាមួយដៃគូ ដោយសម្រេចបាននូវ វឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងនោះ៖ ជាមួយដៃគូមួយ មានការយោគយល់គ្នាច្រើន ដោយបានឯកភាពគ្នាលើ លក្ខខណ្ឌមួយចំនួនរួចហើយ ដោយឡែកចំពោះលក្ខខណ្ឌដែលនៅសេសសល់ ក៏សង្ឃឹមថា អាចនឹងស្វែងរក ដំណោះស្រាយរួមមួយ ដែលភាគីទាំងសងខាងអាចទទួលយកបាន ក្នុងពេលឆាប់ៗ ផងដែរ។ ចំពោះដៃគូមួយ ទៀត បើទោះជាមិនទាន់មានវឌ្ឍនភាពជាដុំកំភួនក្តី ក៏រាជរដ្ឋាភិបាលនៅតែបន្តឆន្ទៈក្នុងការដោះស្រាយឱ្យបាន ជ្រះស្រឡះ ដើម្បីរក្សាទំនាក់ទំនងជាប្រពៃណីដ៏ល្អប្រសើរ និងបើកផ្លូវឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែស៊ី ជម្រៅបន្ថែមទៀត។ ជារួម ការដោះស្រាយបំណុលមរតកជាមួយដៃគូ លែងជាកង្វល់ចំពោះកាតព្វកិច្ចបំណុល ជាយថាហេតុសម្រាប់កម្ពុជាទៀតហើយ ដោយកិច្ចការនេះស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន និងមិនជះឥទ្ធិពល អវិជ្ជមាន ដល់ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានោះទេ។

– បានរៀបចំបោះផ្សាយ និងផ្សព្វផ្សាយជាសាធារណៈនូវព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ប្រចាំ ឆមាស ជាទៀងទាត់ មិនលើសពី ៣ខែ បន្ទាប់ពីដំណាច់ឆមាសនីមួយៗ ក្នុងគោលបំណងបន្តលើកកម្ពស់ តម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាព នៃការគ្រប់គ្រងបំណុលសាធារណៈ។

(វឌ្ឍនភាពលម្អិតនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រនីមួយៗ មានក្នុងឧបសម្ព័ន្ធ ២)

ជំពូកទី៤
ហានិភ័យ, បញ្ហាប្រឈម, និងការលះបង់ភាព

ជំពូកទី៤
ហានិភ័យ, បញ្ហាប្រឈម, និងការលុបបំបាត់

៤.១. ហានិភ័យ

តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨, រហូតមកទល់បច្ចុប្បន្ន ពុំមានហានិភ័យបំណុលធំដុំកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈរបស់កម្ពុជាទេ ពោលគឺ ហានិភ័យបំណុលពាក់ព័ន្ធនីមួយៗ សុទ្ធតែស្ថិតក្នុងភាពអាចគ្រប់គ្រងបាន។ បើទោះជាកម្ពុជាកំពុងស្ថិតក្នុងចំណាត់ថ្នាក់ជាប្រទេសមាន **«ហានិភ័យបំណុលកម្រិតទាប»** បែបនេះក្តី មិនមែនមានន័យថា កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលមានសុវត្ថិភាព ដែលត្រូវព្រងើយកន្តើយនោះឡើយ។ ជារួម រាជរដ្ឋាភិបាលយល់ថា ស្ថានភាពបំណុលសាធារណៈកម្ពុជា នៅតែអាចទទួលរងនូវផលប៉ះពាល់ពីហានិភ័យមួយចំនួន ដូចខាងក្រោម៖

– **ហានិភ័យចម្បងៗ** រួមមាន៖ ១) **ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ** ដែលកើតចេញពីការធានារបស់រដ្ឋ និងពីវិស័យធនាគារនិងហិរញ្ញវត្ថុ, ២) **ហានិភ័យថវិកា** ដែលកើតឡើងដោយសារសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ ពុំសម្រេចបានតាមគោលដៅ, និង ៣) **ហានិភ័យទីផ្សារ** ដែលកើតឡើងដោយសារការកើនឡើងនៃអត្រាការប្រាក់ឥណទាន ព្រមទាំងការធ្លាក់ចុះតម្លៃរូបិយវត្ថុជាតិ ធៀបនឹងរូបិយប័ណ្ណបំណុល។

– **ហានិភ័យបន្ទាប់បន្សំ** រួមមាន៖ ១) **ហានិភ័យប្រតិបត្តិការ** ដែលកើតឡើងដោយសារភាពចន្លោះប្រហោងនៃប្រព័ន្ធគ្រប់គ្រងការងារ, ការធ្វេសប្រហែសរបស់មន្ត្រីទទួលបន្ទុក, បច្ចេកវិទ្យា, ឬករណីប្រជាន់សក្តិ; ២) **ហានិភ័យសន្ធនីយភាព** ដែលកើតឡើងដោយសារតម្រូវការសាច់ប្រាក់គំហុក សម្រាប់ទូទាត់សេវាបំណុល; ៣) **ហានិភ័យហិរញ្ញប្បទាននៃគម្រោង** ដែលកើតឡើងដោយសារដៃគូអភិវឌ្ឍន៍បញ្ឈប់ការផ្តល់ហិរញ្ញប្បទានភ្លាមៗ ហើយកម្ពុជាចាំបាច់ត្រូវស្វែងរកហិរញ្ញប្បទានពីប្រភពផ្សេងដែលមានតម្លៃថ្លៃជាងមុនមកជំនួស; និង ៤) **ហានិភ័យឥណទាន** ដែលកើតឡើងដោយសារឥណទាយិកពុំមានលទ្ធភាពទូទាត់សេវាបំណុលជូនរដ្ឋទាន់ពេលវេលា។

៤.២. បញ្ហាប្រឈម

ក្នុងបរិការណ៍បច្ចុប្បន្ន រាជរដ្ឋាភិបាលពិនិត្យឃើញថា មានបញ្ហាប្រឈមពីកត្តាខាងក្រៅ និងខាងក្នុងមួយចំនួន ដែលអាចនឹងបង្កផលប៉ះពាល់ជាយថាហេតុលើស្ថានភាពបំណុលសាធារណៈកម្ពុជា ជាអាទិ៍ ដូចខាងក្រោម៖

៤.២.១. ការគំរាមកំហែងពីខាងក្រៅ

ឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្មរវាងមហាអំណាចធំៗ និងការគំរាមកំហែងពីក្រៅផ្សេងទៀត អាចនឹងបង្កផលប៉ះពាល់អវិជ្ជមានដល់កម្ពុជា ដោយហេតុថា បច្ចុប្បន្នសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកខ្លាំងលើពាណិជ្ជកម្មអន្តរជាតិ។ ដូចនេះ ក្នុងករណីប្រសិទ្ធភាពនៃការអនុវត្តវិធានការជាកញ្ចប់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញដើម្បីទប់ទល់នូវរិបត្តិជាយថាហេតុទាំងនេះ មានកម្រិត នោះសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ អាចនឹងពុំសម្រេចបានតាមគោលដៅ ហើយអាចនឹងប៉ះពាល់ខ្លាំងដល់ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា។

៤.២.២. ភាពរឹងស្ងួតនៃហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់

ខណៈដែលកម្ពុជានៅតែបន្តរក្សាបាននូវកំណើនសេដ្ឋកិច្ចឥតឈប់ឈរ ជាពិសេស បន្ទាប់ពីផុត

រយៈពេលអន្តរកាលនៃការឡើងឋានៈជាប្រទេសចំណូលមធ្យមកម្រិតទាប ឬនៅពេលដែលចំណូលជាតិដុលក្នុងមនុស្សម្នាក់ឈានដល់កម្រិតមួយខ្ពស់ នោះប្រភពហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានកម្រិតខ្ពស់ដែលកម្ពុជាធ្លាប់តែទទួលបានពីដៃគូអភិវឌ្ឍន៍ អាចនឹងកាន់តែខ្ចីច ដោយសារកម្ពុជាក៏នឹងត្រូវចាត់ជាប្រទេសដែលមានសមត្ថភាពខ្ចី និងលទ្ធភាពសងកាន់តែខ្ពស់ជាងមុន ផងដែរ ពោលគឺ ជាប្រទេសដែលពុំចាំបាច់តែពឹងផ្អែកខ្លាំងលើប្រភពហិរញ្ញប្បទានជាប្រពៃណីក្រៅប្រទេស។

ជាក់ស្តែង ដៃគូអភិវឌ្ឍន៍បច្ចុប្បន្ន ដូចជា៖ ជប៉ុន, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្តល់ឥណទាន ដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះទាបជាងមុនដល់កម្ពុជា។ ទន្ទឹមនេះ តាមការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ថ្មីៗ ដូចជា៖ ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី, អាល្លឺម៉ង់, និងសាធារណរដ្ឋឆែក ជាដើម ក៏បង្ហាញឱ្យឃើញដែរថា ឥណទានដែលដៃគូទាំងនោះនឹងផ្តល់ អាចមិនមានកម្រិតសម្បទានលើសពី **៣៥ ភាគរយ** ទេ។

៤.២.៣. យន្តការចំពោះកិច្ច សម្រាប់គម្រោង PPP

បើទោះជាគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦ - ២០២០ ត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក៏ប៉ុន្តែ ប្រសិទ្ធភាពនៃការអនុវត្តនៅមានកម្រិត នៅឡើយ ដោយហេតុថាយន្តការចំពោះកិច្ចនៅតែត្រូវបានយកមកប្រើប្រាស់សម្រាប់គម្រោង PPP ថ្មីៗមួយចំនួន។

៤.២.៤. បញ្ហាប្រឈមពាក់ព័ន្ធផ្សេងទៀត

ក្រៅពីបញ្ហាប្រឈមចម្បងទាំង៣ ខាងលើ ការគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជាក៏កំពុងប្រឈមនឹងបញ្ហាមួយចំនួនផ្សេងទៀតផងដែរ ដែលរួមមានដូចខាងក្រោម៖

– ការថមថយនៃអតិរេកចរន្តសម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់

ខណៈដែលរាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការអនុវត្ត កម្មវិធីគោលនយោបាយជាអាទិភាពនានា (ដូចជា៖ ការដំឡើងប្រាក់បៀវត្ស និងការគាំពារសង្គម) និងវិធានការជាកញ្ចប់ ដើម្បីពង្រឹងភាពប្រកួតប្រជែងទប់ទល់នឹងការគំរាមគំហែងពីខាងក្រៅ នោះអតិរេកចរន្ត ដែលជាប្រភពដ៏សំខាន់សម្រាប់យកមកហិរញ្ញប្បទានគម្រោងវិនិយោគផ្ទាល់អាចនឹងថមថយ បើទោះបីជាការប្រមូលចំណូលថវិកាជាតិសម្រេចបានខ្ពស់ក្តី។

– ការកត់ត្រាទិន្នន័យកាតព្វកិច្ចបំណុលជាយថាហេតុ

បើទោះជាតាមរយៈកិច្ចខិតខំប្រឹងប្រែងកន្លងមក ទិន្នន័យនៃកាតព្វកិច្ចបំណុលជាយថាហេតុមួយចំនួនដូចជា៖ ការធានារបស់រដ្ឋលើគម្រោងវិនិយោគក្នុងវិស័យថាមពល និងដឹកជញ្ជូន ត្រូវបានប្រមូលយកមកកត់ត្រា និងវិភាគក្តី ក៏ប៉ុន្តែ ទិន្នន័យដែលប្រមូលបានទាំងនេះ នៅពុំទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយ ពោលគឺអាចនៅមានទិន្នន័យពាក់ព័ន្ធមួយចំនួនទៀត ដូចជា៖ ការធានារបស់រដ្ឋលើគម្រោងវិនិយោគក្នុងវិស័យផ្សេងទៀត, គម្រោងដែលរដ្ឋបានបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ហើយទិញត្រឡប់មកវិញ, និងកាតព្វកិច្ចបំណុលជាយថាហេតុក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាដើម។ល។ ប្រការនេះ នាំឱ្យលទ្ធផលនៃការវិភាគ ពុំអាចធានាបាននូវសុក្រឹត្យភាពពេញលេញ ដើម្បីធ្វើការសន្និដ្ឋានឱ្យបានច្បាស់លាស់អំពីទំហំ និងផលប៉ះពាល់នៃកាតព្វកិច្ចបំណុលជាយថាហេតុ មកលើស្ថានភាពបំណុលសាធារណៈ។

– ធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ និងកិច្ចការពាក់ព័ន្ធ

តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ក្នុងរយៈកាលកន្លងមក នេះ ថ្វីត្បិតតែសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការងារគ្រប់គ្រងបំណុលសាធារណៈ និងកិច្ចការពាក់ព័ន្ធ ផ្សេងៗ ដោយរួមទាំងការងារគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ត្រូវបានពង្រឹងក្តី ក៏ប៉ុន្តែ ទាំងចំនួន និងកម្រិតសមត្ថភាពមន្ត្រី នៅពុំទាន់អាចឆ្លើយតបបានតាមតម្រូវការការងារបច្ចុប្បន្ន ក៏ដូចជាទៅអនាគតនៅឡើយ។

៤.៣. ភាលានុវត្តភាព

ទន្ទឹមនឹងបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលយល់ឃើញថា បរិការណ៍ថ្មីនៃសេដ្ឋកិច្ចនេះ ក៏ជាកាលានុវត្តភាពដ៏សំខាន់ផងដែរ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជា។ កាលានុវត្តភាពសំខាន់ៗទាំងនេះ មានដូចខាងក្រោម៖

៤.៣.១. ការកើនឡើងនូវសមត្ថភាពខ្ចី

ភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ដែលស្តែងឱ្យឃើញតាមរយៈការឈានឡើងពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប; ការសម្រេចបាននូវសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗមួយចំនួន ដូចជា៖ ១) ការរក្សាបាននូវចីរភាពកំណើនជាមធ្យមក្នុងរង្វង់ **៧ ភាគរយ**, ២) កំណើនចំណូលថវិកាជាតិជាមធ្យមក្នុងរង្វង់ **១ ពិន្ទុភាគរយ នៃផសស** ក្នុងមួយឆ្នាំ, និង ៣) កំណើនការនាំចេញជាមធ្យមប្រមាណ **១២ ភាគរយ** ក្នុងមួយឆ្នាំ; ព្រមទាំងការរក្សាបាននូវចីរភាពបំណុលសាធារណៈកន្លងមក សបញ្ជាក់ឱ្យឃើញថា កម្ពុជាអាចបង្កើនសមត្ថភាពខ្ចីរបស់ខ្លួនបានខ្ពស់ជាងមុនថែមទៀត សម្រាប់យកមកបំពេញតម្រូវការវិនិយោគសាធារណៈសរុប។ ទោះជាយ៉ាងនេះក្តី ការបង្កើនសមត្ថភាពខ្ចីក្នុងកម្រិតណាមួយនោះចាំបាច់ត្រូវមានការវិភាគគ្រប់ជ្រុងជ្រោយ ស្របតាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ដែលត្រូវពិនិត្យទៅលើសូចនាករបំណុលគន្លឹះៗ ចំនួន ៥ ធៀបនឹងអនុបាតគោល (នឹងមានលម្អិតក្នុងចំណុច ៦.២. នៃវិធានការជាយុទ្ធសាស្ត្រ) ដើម្បីធានាថា ស្ថានភាពបំណុលសាធារណៈកម្ពុជានៅតែមានចីរភាព និងហានិភ័យកម្រិតទាប។

៤.៣.២. លទ្ធភាពក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន

រាជរដ្ឋាភិបាលយល់ឃើញថា ភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា មិនត្រឹមតែបង្កលទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបង្កើនសមត្ថភាពខ្ចីបានខ្ពស់ជាងមុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកាលានុវត្តភាពដ៏ប្រសើរក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យកាន់តែទូលំទូលាយ សម្រាប់យកមកហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈសរុប ប្រកបដោយភាពបត់បែន និងប្រសិទ្ធភាពជាងមុន តាមរយៈ៖ ការពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅជាមួយដៃគូអភិវឌ្ឍន៍ចាស់, ការបើកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ថ្មី, ការពិចារណាទទួលយកឥណទានដែលមានកម្រិតសម្បទានទាបជាងមុន, ការកៀរគរទុនពីទីផ្សារមូលបត្រ ទាំងក្នុង និងក្រៅប្រទេស, និងជាពិសេស ការបន្តពង្រឹងយន្តការ PPP។ល។

៤.៣.៣. ការចូលរួមពីវិស័យឯកជនក្នុងការវិនិយោគសាធារណៈ

ទន្ទឹមនឹងការអភិវឌ្ឍដ៏គួរឱ្យកត់សម្គាល់កន្លងមក កម្ពុជានៅតែត្រូវការវិនិយោគសាធារណៈដ៏សន្ធឹកសន្ធាប់បន្ថែមទៀត ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព សំដៅឈានទៅសម្រេចបាននូវបង្គោលចរឆ្នាំ២០៣០ ដូចបានកំណត់ក្នុងចក្ខុវិស័យឆ្នាំ២០៥០ របស់រាជរដ្ឋាភិបាល។ វិស័យឯកជន គឺជាតួអង្គដ៏សំខាន់មួយ ដែលមិនអាចខ្វះបាន ក្នុងការចូលរួមកសាងស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងក៏ជាតួអង្គដ៏សំខាន់ដែលគាំទ្រដល់ការអនុវត្តគោលនយោបាយអាទិភាពផ្សេងៗរបស់រាជរដ្ឋាភិបាល។

តាមរយៈការអនុវត្តគោលនយោបាយសម្រួលវិនិយោគ ក្នុងរយៈកាលកន្លងមក ការចូលរួមពីវិស័យ

ឯកជននៅកម្ពុជា មានសន្ទុះលឿនគួរឱ្យកត់សម្គាល់ ដែលស្តែងចេញតាមរយៈកំណើននៃការវិនិយោគផ្ទាល់ពីបរទេស ក្នុងរង្វង់ប្រមាណ **៧៣០ លានដុល្លារអាមេរិក** នៅឆ្នាំ២០០៨ ទៅប្រមាណ **២,៦ ប៊ីលានដុល្លារអាមេរិក** នៅឆ្នាំ២០១៨ (តួលេខប៉ាន់ស្មាន) ហើយប្រាក់បញ្ញើរបស់វិស័យឯកជនកើនពីប្រមាណ **២,៣ ប៊ីលានដុល្លារអាមេរិក** ទៅប្រមាណ **១៩,៧ ប៊ីលានដុល្លារអាមេរិក** ក្នុងរយៈពេលដូចគ្នានេះ។ នេះជាសក្ខានុពលដ៏ប្រសើរដែលបង្ហាញថាវិស័យឯកជន កំពុងនិងកាន់តែមានលទ្ធភាពខ្ពស់ក្នុងការចូលរួមវិនិយោគសាធារណៈ ជាមួយរាជរដ្ឋាភិបាល។

៤.៣.៤. ភាពរីកចម្រើននៃវិស័យធនាគារ និងហិរញ្ញវត្ថុ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យធនាគារ និងហិរញ្ញវត្ថុ នៅកម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលស្តែងឱ្យឃើញតាមរយៈការកើនឡើងនៃចំនួនធនាគារពាណិជ្ជ, ធនាគារឯកទេស, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ, ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ, និងក្រុមហ៊ុនធានារ៉ាប់រងថ្មីៗជាច្រើន។

ការរីកចម្រើននៃវិស័យធនាគារ និងហិរញ្ញវត្ថុនេះ មិនត្រឹមតែជាកម្លាំងចលករដ៏សំខាន់ក្នុងការរួមចំណែកទាក់ទាញវិស័យឯកជន ឱ្យមកវិនិយោគនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបង្កើតបរិយាកាសអនុគ្រោះដល់ការអភិវឌ្ឍទីផ្សារមូលបត្រក្នុងប្រទេស ផងដែរ។

៤.៣.៥. លទ្ធភាពក្នុងការបោះផ្សាយមូលបត្ររដ្ឋ

រាជរដ្ឋាភិបាលយល់ឃើញថា ក្នុងបរិការណ៍បច្ចុប្បន្ន កម្ពុជាមានលទ្ធភាពច្រើនក្នុងការចាប់ផ្តើមសាកល្បងបោះផ្សាយមូលបត្ររដ្ឋ ដើម្បីអាចកៀរគរទុនពីទីផ្សារមូលបត្រក្នុងប្រទេស យកមកបំពេញតម្រូវការវិនិយោគសាធារណៈ ដោយហេតុថា មានវិនិយោគិនសក្តានុពលជាច្រើនបាននិងកំពុងត្រៀមលក្ខណៈក្នុងការវិនិយោគលើមូលបត្ររដ្ឋ ដូចជា៖ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធំៗមួយចំនួន, ក្រុមហ៊ុនធានារ៉ាប់រង, បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល, បេឡាជាតិរបបអតីតយុទ្ធជន, និងបេឡាជាតិរបបសន្តិសុខសង្គម ជាដើម។

ជំពូកទី៥
ការវិភាគចំរោះពហុលក្ខណៈ

ជំពូកទី៥
ការវិភាគចីរភាពបំណុល

៥.១. ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រឹមដំណាច់ឆ្នាំ២០១៨

គិតត្រឹមដំណាច់ឆ្នាំ២០១៨ ដោយគិតបញ្ចូលទាំងបំណុលមរតកកំពុងដោះស្រាយ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ **៧ ប៊ីលានដុល្លារអាមេរិក** ដោយភាគច្រើនលើសលុប (**៩៩,៩៦ ភាគរយ**) ជាបំណុលសាធារណៈក្រៅប្រទេស ខណៈដែលបំណុលសាធារណៈក្នុងប្រទេស (កើតចេញពីការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋមិនអាចជួញដូរបាន ដើម្បីបំពេញទុនឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ) មានចំនួនតិចតួចបំផុតត្រឹមប្រមាណ **២,៨ លានដុល្លារអាមេរិក** ត្រូវនឹងប្រមាណ **០,០៤ ភាគរយ** នៃសន្និធិបំណុលសាធារណៈសរុប។


ផ្អែកតាមលទ្ធផលនៃការវិភាគចីរភាពបំណុល បង្ហាញថា សម្រាប់ឆ្នាំ២០១៨ សូចនាករបំណុលគន្លឹះៗទាំង៥ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលនៃបទដ្ឋានបច្ចេកទេសអន្តរជាតិ ក្នុងនោះ៖ ១) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផសស មានត្រឹម **២១,៥ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **៥៥ ភាគរយ**, ២) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស មានត្រឹម **២១,៥ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **៤០ ភាគរយ**, ៣) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ មានត្រឹម **២៨,៤ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **១៨០ ភាគរយ**, ៤) អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញមានត្រឹម **១,៤ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **១៥ ភាគរយ**, និង ៥) អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិមានត្រឹម **៤,៩ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **១៨ ភាគរយ**។ ក្នុងស្ថានភាពបែបនេះ បញ្ជាក់ច្បាស់ថា បំណុលសាធារណៈកម្ពុជាបច្ចុប្បន្នមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»**។

៥.២. តម្រូវការហិរញ្ញប្បទានឥតិយោគមូលធនសាធារណៈ

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ ដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ជាមូលដ្ឋាន រាជរដ្ឋាភិបាលត្រូវការទុនវិនិយោគសាធារណៈសរុបប្រមាណ **១៥ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ៖ ហិរញ្ញប្បទានក្នុងស្រុកមានចំនួន **៧ ប៊ីលានដុល្លារអាមេរិក** ត្រូវនឹងប្រមាណ **៤៧ ភាគរយ** និង ហិរញ្ញប្បទានក្រៅប្រទេសមានចំនួន **៨ ប៊ីលានដុល្លារអាមេរិក** ត្រូវនឹងប្រមាណ **៥៣ ភាគរយ**។ ជារួម មានន័យថា រាជរដ្ឋាភិបាលចាំបាច់ត្រូវកៀរគរហិរញ្ញប្បទានពីប្រភពនានាក្រៅប្រទេស (ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន) ឱ្យបានជាមធ្យមក្នុងរង្វង់ **១,៦ ប៊ីលានដុល្លារអាមេរិក** ក្នុងមួយឆ្នាំ។

ទោះជាយ៉ាងនេះក្តី ប្រសិនបើគិតបញ្ចូលនូវតម្រូវការទាំងអស់នៃចំណាយវិនិយោគសាធារណៈដែលរាជរដ្ឋាភិបាលបានគ្រោងទុក ដូចមានក្នុងយុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៤ និងការប្តេជ្ញាចិត្តគោលនយោបាយដទៃទៀត ដូចជា៖ ការលើកកម្ពស់វិស័យអប់រំ, ការបង្កើតប្រព័ន្ធគាំពារសង្គម, ការគាំទ្រសមត្ថភាពបច្ចេកទេសរដ្ឋបាលនៃស្ថាប័នរាជរដ្ឋាភិបាល រួមទាំងផែនការអភិវឌ្ឍន៍តាមវិស័យ ដែលត្រូវពិចារណាដោយរាជរដ្ឋាភិបាលអាណត្តិទី៦នេះ នោះតម្រូវការហិរញ្ញប្បទានវិនិយោគសាធារណៈសរុប អាចនឹងត្រូវកើនប្រមាណ **៤៩ ភាគរយ** បន្ថែមទៀត។ ដូចនេះ ការកៀរគរហិរញ្ញប្បទានពីក្រៅប្រទេស ជាពិសេសគឺ ឥណទានសម្បទាន ក៏នឹងត្រូវបង្កើនទៅតាមនោះដែរ។

ការព្យាករតម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈ ២០១៩ - ២០២៣



ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

៥.៣. សេណារីយ៉ូនៃការខ្ចីថ្មីបន្ថែម

ឈរលើតម្រូវការហិរញ្ញប្បទានវិនិយោគសាធារណៈខាងលើ រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមពីក្រៅប្រទេសសម្រាប់ឆ្នាំ២០១៩ - ២០២៣ តាមសេណារីយ៉ូចំនួន ៣ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគចីរភាពបំណុល ដូចខាងក្រោម៖

- **សេណារីយ៉ូទី១៖** ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ (សមមូលនឹងប្រមាណ ២,១ ប៊ីលាន ទៅ ២,៨ ប៊ីលានដុល្លារអាមេរិក)។
- **សេណារីយ៉ូទី២៖** ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី **២ ប៊ីលាន** ទៅ **៣ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ (សមមូលនឹង ២,៨ ប៊ីលាន ទៅ ៤,២ ប៊ីលានដុល្លារអាមេរិក)។
- **សេណារីយ៉ូទី៣៖** ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី **២,៥ ប៊ីលាន** ទៅ **៣,៥ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ (សមមូលនឹង ៣,៥ ប៊ីលាន ទៅ ៤,៩ ប៊ីលានដុល្លារអាមេរិក)។

៥.៤. លទ្ធផលនៃការវិភាគ

ជាលទ្ធផលរួមនៃការវិភាគចីរភាពបំណុល តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ បង្ហាញថា៖

- ក្នុងករណីខ្ចីថ្មីបន្ថែមតាមសេណារីយ៉ូទី១ ក្នុងរង្វង់ **១,៥ ប៊ីលាន ទៅ ២ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ២,១ ប៊ីលាន ទៅ ២,៨ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៩ - ២០២៣ នោះស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»**។
- ក្នុងករណីខ្ចីថ្មីបន្ថែមតាមសេណារីយ៉ូទី២ ក្នុងរង្វង់ **២ ប៊ីលាន** ទៅ **៣ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ២,៨ ប៊ីលាន ទៅ ៤,២ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៩ - ២០២៣ នោះស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានឹងនៅតែមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»** ប៉ុន្តែ ត្រូវមានការប្រយ័ត្នប្រយែងពីការធ្លាក់ចុះការនាំចេញ (Exports shock)។

- ក្នុងករណីខ្វីថ្មីបន្ថែមតាមសេណារីយ៉ូទី៣ ក្នុងរង្វង់ **២,៥ ប៊ីលាន** ទៅ **៣,៥ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ៣,៥ ប៊ីលាន ទៅ ៤,៩ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៩ - ២០២៣ នោះស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា នឹងលែងមានចីរភាព ដោយត្រូវប្រឈមនូវ **«ហានិភ័យកម្រិតមធ្យម»** ប្រសិនបើកម្ពុជារងនូវការប៉ះទង្គិច (Shock) ណាមួយក្នុងចំណោមករណីទាំង ៤ រួមមាន៖ ១) តម្លៃរូបិយវត្ថុជាតិធ្លាក់ចុះគំហុក ធៀបនឹង រូបិយប័ណ្ណបរទេស, ២) ការនាំចេញរងការប៉ះទង្គិចខ្លាំង, ៣) ការកើតឡើងនូវបំណុលចេញពីកាតព្វកិច្ចបំណុលជាយថាហេតុ, និង ៤) កំណើន ផសស ថមថយខ្លាំង។

(លទ្ធផលនៃការវិភាគលម្អិតតាមសេណារីយ៉ូនៃការខ្ចីថ្មីបន្ថែមនីមួយៗ មានក្នុងឧបសម្ព័ន្ធ ៥)

ជារួម ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈ ដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣, កម្ពុជាមានសមត្ថភាពខ្ចីថ្មីបន្ថែមពីក្រៅប្រទេស ក្នុងរង្វង់ **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ២,១ ប៊ីលាន ទៅ ២,៨ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ និងអាចកើនដល់ **៣ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ៤,២ ប៊ីលានដុល្លារអាមេរិក) អាស្រ័យតាមវិឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែង និងត្រូវគោរពលក្ខខណ្ឌ ដូចខាងក្រោម៖

- សម្រិតសម្រាំងខ្វីតែឥណទាន ដែលមានថ្លៃដើមនិងហានិភ័យទាប និងខ្វីសម្រាប់តែវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង ហើយរាល់គម្រោងវិនិយោគសាធារណៈដែលនឹងត្រូវហិរញ្ញប្បទានដោយឥណទានសម្បទាន ត្រូវតែជាគម្រោងដែលមានស្តង់ដា និងគុណភាពខ្ពស់ ព្រមទាំងធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងការប្រែប្រួលអាកាសធាតុ។
- ត្រូវសម្រេចឱ្យបាននូវកំណើន ផសស ក្នុងរង្វង់ ៧ភាគរយ និងកំណើនចំណូលចរិកាជាតិជាមធ្យម ០,៣ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ។
- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវកម្មវិធីកែទម្រង់គន្លឹះៗ ដែលជាមូលដ្ឋាននៃការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ដូចជា៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, និង ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ល។
- បន្តពង្រឹងគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ដោយប្រយ័ត្នប្រយែងខ្ពស់ ជាពិសេសហានិភ័យ ដែលកើតចេញពីគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP និងវិស័យធនាគារ និងហិរញ្ញវត្ថុ។

ជំពូកទី៦
វិធានការជាយុទ្ធសាស្ត្រ

ឧបសម្ព័ន្ធ ៦
វិធានការជាយុទ្ធសាស្ត្រ

ក្នុងគោលដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យមនិងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច និងលើកស្ទួយកម្រិតជីវភាពប្រជាជន ស្របតាមបរិការណ៍សេដ្ឋកិច្ចថ្មីរបស់កម្ពុជា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រសម្រាប់ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលសាធារណៈ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ដូចខាងក្រោម៖

៦.១. កំណត់ចំហំនៃការខ្ចីថ្មីបន្ថែម

ផ្អែកតាមលទ្ធផលនៃការវិភាគចីរភាពបំណុលស្របតាមបទដ្ឋានបច្ចេកទេសអន្តរជាតិ និងដោយផ្អែកលើគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ រាជរដ្ឋាភិបាលសម្រេចកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមពីក្រៅប្រទេស សម្រាប់ឆ្នាំ២០១៩ - ២០២៣ ក្នុងរង្វង់ **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ ហើយក្នុងកាលៈទេសៈចាំបាច់ នឹងបង្កើនដល់រង្វង់ **៣ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ តែទំហំនៃការខ្ចីថ្មីបន្ថែមពីក្រៅប្រទេសសរុប ក្នុងរយៈពេល ៥ ឆ្នាំនេះ មិនត្រូវលើសពី **១១ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ១៥ ប៊ីលានដុល្លារអាមេរិក) ឡើយ។

៦.២. កំណត់ពិដានៃសូចនាករបំណុលគន្លឹះៗ ដែលត្រូវគ្រប់គ្រង និងតាមដាន

ដើម្បីធានាបាននូវសង្គតិភាពជាមួយបទដ្ឋានបច្ចេកទេសអន្តរជាតិ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ និងអនុលោមតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា រាជរដ្ឋាភិបាលសម្រេចកំណត់ពិដាននៃសូចនាករបំណុលគន្លឹះៗ ចំនួន ៥ សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រង និងតាមដានចីរភាពបំណុលសាធារណៈ ដូចខាងក្រោម៖

- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប (រួមបញ្ចូលនូវ៖ បំណុលសាធារណៈក្នុងប្រទេស និងបំណុលសាធារណៈក្រៅប្រទេស ដោយរួមទាំងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹង ផសស (PV[1] of total public debt to GDP ratio) ត្រូវស្ថិតក្រោម **៥៥ ភាគរយ** ដែលក្នុងនោះ៖
  - អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស (រួមទាំងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹង ផសស (PV of PPG[2] external debt to GDP ratio) ត្រូវស្ថិតក្រោម **៤០ ភាគរយ**។
  - អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្នុងប្រទេស (រួមទាំងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹង ផសស (PV of PPG domestic debt to GDP ratio) ត្រូវស្ថិតក្រោម **១៥ ភាគរយ**។
- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ (PV of PPG external debt to exports ratio) ត្រូវស្ថិតក្រោម **១៨០ ភាគរយ**។
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ (PPG external debt service to exports ratio) ត្រូវស្ថិតក្រោម **១៥ ភាគរយ**។
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ (PPG external debt service to revenue ratio) ត្រូវស្ថិតក្រោម **១៨ ភាគរយ**។

[1] PV: Present Value

[2] PPG: Public and Publicly Guaranteed

៦.៣. បន្តខ្ចីសម្រាប់តែវិស័យអាទិភាព

រាជរដ្ឋាភិបាលយល់ឃើញថា វិស័យហេដ្ឋារចនាសម្ព័ន្ធ នៅតែជាវិស័យអាទិភាពសម្រាប់កម្ពុជា ក្នុងការទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលមធ្យមនិងវែង និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងបន្តប្រើប្រាស់ថវិកាដែលកៀរគរបានតាមរយៈការខ្ចីឥណទាន សម្បទានពីក្រៅប្រទេស សម្រាប់ហិរញ្ញប្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេស វិស័យបង្កើនផលិតភាពផលិតកម្ម, ជំរុញការតភ្ជាប់, និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ប្រព័ន្ធស្រោចស្រព, អគ្គិសនី, កំពង់ផែ, ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន, ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម, ឡូជីស្ទីក, និងវិស័យឌីជីថលជាដើម។

ទន្ទឹមនេះ ត្រូវប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

៦.៤. បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការវិនិយោគសាធារណៈ

ការលើកកម្ពស់ប្រសិទ្ធភាពនៃការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងថវិការដ្ឋ, ថវិកាដៃគូអភិវឌ្ឍន៍, និងទុនវិនិយោគឯកជន) និងគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ, ទាំងថ្នាក់ក្រោមជាតិ, សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, និងអង្គភាពសាធារណៈប្រហាក់ប្រហែល) នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង គឺជាវិធានការជាយុទ្ធសាស្ត្រគន្លឹះមួយ ក្នុងចំណោមវិធានការនានា ក្នុងការកាត់បន្ថយសម្ពាធបំណុលសាធារណៈកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវអនុវត្ត «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥» ដោយ ***ប្រយ័ត្នប្រយែង, ឈរលើគោលការណ៍ប្រាកដនិយម, និងមានភាពទន់ភ្លន់***។ ដោយឡែក ចំពោះការខ្ចីឥណទានសម្រាប់ការអភិវឌ្ឍទីក្រុង និងទីប្រជុំជន ត្រូវបំពេញឱ្យបាននូវបុព្វលក្ខខណ្ឌ (Pre-conditions) ចម្បងៗ ចំនួន ៣ រួមមាន៖ ១) ផែនការមេសម្រាប់អភិវឌ្ឍន៍ទីក្រុង ឬទីប្រជុំជន, ២) ផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, និង ៣) ផែនការរំលស់ប្លែដើមវិនិយោគ សំដៅធានាបង្កើនប្រសិទ្ធិភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាពនៃចំណាយវិនិយោគសាធារណៈ ព្រមទាំងធានាបាននូវចីរភាពនៃការអភិវឌ្ឍ។ ទន្ទឹមនេះ ចំពោះគម្រោងវិនិយោគសាធារណៈធំៗ និងមានលក្ខណៈស្មុគស្មាញ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ពង្រឹងបន្ថែមលើដំណាក់កាល៖ ១) ការធ្វើអត្ថសញ្ញាណកម្មនិងការរៀបចំគម្រោងបឋម, ២) ការសិក្សាសមិទ្ធិលទ្ធភាព ការរៀបចំគម្រោង និងការវាយតម្លៃសំណើគម្រោង, និង ៣) ការត្រួតពិនិត្យសំណើគម្រោង ដោយក្រសួង-ស្ថាប័នឯករាជ្យរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ក៏ត្រូវបន្តពង្រឹង និងពង្រីកយន្តការត្រួតពិនិត្យនិងតាមដានគម្រោង ក្នុងដំណាក់កាលនៃការអនុវត្ត លើគ្រប់គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទាំងអស់ ផងដែរ។

៦.៥. បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យទូលំទូលាយជាងមុន

ក្នុងបរិការណ៍សេដ្ឋកិច្ចថ្មីរបស់កម្ពុជា រាជរដ្ឋាភិបាលមានភាពចាំបាច់ត្រូវបន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន ឱ្យបានទូលំទូលាយជាងមុន ដើម្បីបំពេញតម្រូវការហិរញ្ញប្បទានវិនិយោគសាធារណៈសរុប ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច សង្គម និងលើកស្ទួយកម្រិតជីវភាពប្រជាជន។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវបន្តកៀរគរ ហិរញ្ញប្បទានពីគ្រប់ប្រភព រួមមានដូចខាងក្រោម៖

៦.៥.១. ដៃគូអភិវឌ្ឍន៍

តាមរយៈការបន្តពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាល នឹងបន្តខិតខំ កៀរគរឱ្យអស់លទ្ធភាពនូវហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌ អនុគ្រោះខ្ពស់ ស្របតាមលក្ខខណ្ឌវិនិច្ឆ័យនៃការអនុវត្តជាអន្តរជាតិ ដើម្បីបំពេញតម្រូវការហិរញ្ញប្បទានវិនិយោគ សាធារណៈសរុប និងជួយសម្រាលបន្ទុកសេវាបំណុល។

ក្នុងបរិការណ៍នៃការធ្លាក់ចុះឥណទានដែលមានកម្រិតសម្បទានខ្ពស់ពីដៃគូអភិវឌ្ឍន៍ ដោយសារកម្ពុជា បានចាកផុតពីឋានៈជាប្រទេសដែលមានចំណូលទាប ក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប រាជរដ្ឋាភិបាល នឹងពិនិត្យលទ្ធភាពទទួលយកឥណទានដែលមានកម្រិតសម្បទានមធ្យម ឬទាប អាស្រ័យតាមស្ថានភាព ជាក់ស្តែងនៃសេដ្ឋកិច្ច, លទ្ធភាពចរិកាជាតិ, និងករណីគម្រោងវិនិយោគសាធារណៈនីមួយៗ។

ទន្ទឹមនេះ បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ជាប្រពៃណី និងពង្រីកកិច្ចសហ-ប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ថ្មីៗបន្ថែមទៀត។

រាជរដ្ឋាភិបាល ក៏នៅបន្តរក្សាភាពទន់ភ្លន់ក្នុងការប្រើប្រាស់ឥណទានសម្បទាន ក្នុងទំហំសមស្រប សម្រាប់ហិរញ្ញប្បទានគម្រោងក្នុងវិស័យសង្គមកិច្ច ក្នុងគោលដៅទាក់ទាញ និងកៀរគរហិរញ្ញប្បទាន ឥតសំណង។

៦.៥.២. ទីផ្សារមូលបត្រ

ការអភិវឌ្ឍទីផ្សារមូលបត្រក្នុងប្រទេស មានសារៈសំខាន់ចំពោះការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ការ គ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុ, និងការពង្រឹងភាពជាម្ចាស់លើប្រភពហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល សម្រាប់ បំពេញតម្រូវការវិនិយោគសាធារណៈសរុប។ ការបោះផ្សាយមូលបត្ររដ្ឋ ជាមូលដ្ឋានគ្រឹះក្នុងការជួយជំរុញការ អភិវឌ្ឍមូលបត្រមហាជន, ជាមធ្យោបាយគន្លឹះក្នុងការកៀរគរហិរញ្ញប្បទានក្នុងស្រុក សម្រាប់បំពេញឱនភាព ថវិការដ្ឋ, និងជាឧបករណ៍វិនិយោគដែលមានហានិភ័យទាបសម្រាប់វិនិយោគិន។

តាមរយៈការបោះផ្សាយមូលបត្ររដ្ឋជារូបិយវត្ថុជាតិ រាជរដ្ឋាភិបាលអាចកាត់បន្ថយការប្រឈម នឹងហានិភ័យនៃអត្រាប្តូរប្រាក់ ដែលជាឫសគល់នៃវិបត្តិហិរញ្ញវត្ថុក្នុងតំបន់មួយចំនួននៅលើសកលលោក ដូចជា៖ វិបត្តិហិរញ្ញវត្ថុក្នុងតំបន់អាមេរិកឡាទីនកាលពីឆ្នាំ១៩៩៤ និងក្នុងតំបន់អាស៊ីឆ្នាំ១៩៩៧ ជាដើម។ ជាមួយគ្នានេះ ទីផ្សារមូលបត្រក្នុងប្រទេស ក៏ផ្តល់នូវភាពបត់បែន និងឯករាជ្យភាពដល់ធនាគារកណ្តាលក្នុងការ អនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីគ្រប់គ្រងអត្រាប្តូរប្រាក់ និងអត្រាការប្រាក់នៅទីផ្សារ ប្រកបដោយ ប្រសិទ្ធភាព ផងដែរ។

ក្នុងន័យនេះ រាជរដ្ឋាភិបាល ពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មច្បាប់ស្តីពីមូលបត្ររដ្ឋ, អនុក្រឹត្យស្តីពី ការគ្រប់គ្រងបំណុលសាធារណៈ, ព្រមទាំងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ឱ្យស្របតាមគោលការណ៍នៃ ការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា និងឧត្តមានុវត្តជាអន្តរជាតិ ដើម្បីឈានទៅបោះផ្សាយសាកល្បង មូលបត្ររដ្ឋ នៅពេលវេលាសមស្របណាមួយ។ ក្នុងគោលបំណងពង្រឹងទំនុកចិត្តពីវិនិយោគិន, ប្រតិបត្តិការ ចំណូល - ចំណាយពាក់ព័ន្ធនឹងមូលបត្ររដ្ឋ នឹងត្រូវដាក់ឱ្យស្ថិតក្រោមក្របខ័ណ្ឌគណនីទោលរតនាគារ (Treasury Single Account - TSA)។ ទុនដែលទទួលបានពីការបោះផ្សាយមូលបត្ររដ្ឋ នឹងត្រូវប្រើប្រាស់សម្រាប់តែ ហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព ដែលមានផលិតភាពសេដ្ឋកិច្ច ឬផលិតភាព

ផលិតកម្មខ្ពស់ (អាចជាគម្រោងវិនិយោគសាធារណៈរបស់សហគ្រាសសាធារណៈ ដែលមានចំណូលខ្ពស់)។

៦.៥.៣. វិស័យឯកជន

ការចូលរួមរបស់វិស័យឯកជន ក្នុងគម្រោងវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយប្រភពហិរញ្ញប្បទានចម្រុះ និងតាមយន្តការ PPP គឺជាមធ្យោបាយគន្លឹះមួយ ក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានបន្ថែមលើប្រភពហិរញ្ញប្បទានជាប្រពៃណី ដែលរួមមាន ថវិកាជាតិ និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងពង្រឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈដោយប្រភពហិរញ្ញប្បទានចម្រុះ តាមរយៈការអនុវត្តវិធានការជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥។

ទន្ទឹមនេះ ដើម្បីទាក់ទាញការចូលរួមពីវិស័យឯកជននៅក្នុងការវិនិយោគសាធារណៈ តាមយន្តការ PPP ឱ្យកាន់តែខ្លាំងក្លាថែមទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងហានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវបន្តដឹកមុខក្នុងការជំរុញអនុវត្តវិធានការដែលបានដាក់ចេញ នៅក្នុងឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការ PPP សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦ - ២០២០ និងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដើម្បីឈានទៅអនុវត្តបានពេញលេញនូវយន្តការ PPP ឱ្យបានឆាប់ និងឈានទៅបញ្ឈប់ការប្រើប្រាស់យន្តការចំពោះកិច្ច សំដៅពង្រឹងប្រសិទ្ធភាព និងគ្រប់គ្រងហានិភ័យ នៃគម្រោងវិនិយោគសាធារណៈ តាមយន្តការ PPP។ ចំពោះមុខ ត្រូវពង្រឹងយន្តការច្រកចេញ-ចូលតែមួយ នៅអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះរាល់សំណើគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP។

៦.៦. បន្តពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ

រាជរដ្ឋាភិបាលយល់ថា ក្នុងចំណោមហានិភ័យបំណុលពាក់ព័ន្ធទាំងអស់ ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ នៅតែជាហានិភ័យចម្បងបំផុត ដែលអាចប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈ និងបន្ថែមសម្ពាធដល់ថវិកាជាតិ ឬប្រសិនបើធ្ងន់ធ្ងរជាងនេះ ដល់ស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ដោយក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន កាតព្វកិច្ចបំណុលជាយថាហេតុ អាចកើតចេញពីប្រភព ឬកត្តាសំខាន់ចំនួន ២ គឺៈ ១) ការធានាទូទាត់របស់រដ្ឋ ចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលអនុវត្តដោយសហគ្រាសសាធារណៈ និងគម្រោងវិនិយោគសាធារណៈ តាមយន្តការ PPP និង ២) វិស័យធនាគារ និងហិរញ្ញវត្ថុ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគន្លឹះៗ ដូចខាងក្រោមៈ

១) បន្តមិនផ្តល់ការធានាឥណទានចំពោះវិស័យឯកជន។

២) បន្តវិភាជន៍ថវិកា ក្នុងរង្វង់ **៥ ភាគរយ នៃសេវាបំណុលសរុបប្រចាំឆ្នាំ** ទៅក្នុង**មូលនិធិបម្រុង (Contingency Fund)** សម្រាប់ត្រៀមដោះស្រាយការធានាទូទាត់របស់រដ្ឋ ដែលនឹងអាចកើតឡើងជាយថាហេតុ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏អាចយកមូលនិធិនេះទៅវិនិយោគ ដើម្បីបានចំណូលជាគុណប្រយោជន៍ថវិកាជាតិ ផងដែរ។

៣) កំណត់ពិដានៃការធានាទូទាត់សរុប សម្រាប់គម្រោងថ្មី មិនឱ្យលើសពី **១០ ភាគរយ នៃចំណូលថវិកាជាតិ**។ ពិដាននេះ នឹងត្រូវបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម ជារៀងរាល់ឆ្នាំ ដើម្បីធានាបាននូវសង្គតិភាពជាមួយក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។

៤) ធនាគារជាតិនៃកម្ពុជា ត្រូវបន្តសិក្សា និងតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់

វិស័យឯកជន និងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីវិស័យធនាគារនិងហិរញ្ញវត្ថុ ហើយចែករំលែកព័ត៌មាននិងទិន្នន័យទាំងនោះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងត្រូវពង្រឹងការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ, និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ប្រកបដោយភាពម៉ឺងម៉ាត់ និងប្រសិទ្ធភាពខ្ពស់។

៥) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័នមួយ ដើម្បី៖
   ១) សិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសនានា ក្នុងគោលបំណងបន្តពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ និង
   ២) ចងក្រងព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ សម្រាប់ជាគុណប្រយោជន៍នៃការវិភាគ និងគ្រប់គ្រងហានិភ័យ។

បន្ថែមលើនេះ រាជរដ្ឋាភិបាលដឹងច្បាស់ថា ការទទួលយកនូវឥណទានដែលមានអត្រាការប្រាក់ប្រែប្រួល (Floating Rate) ពីដៃគូអភិវឌ្ឍន៍ នឹងអាចបណ្តាលឱ្យកើតមានហានិភ័យអត្រាការប្រាក់។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគន្លឹះបន្ថែម សម្រាប់គ្រប់គ្រងហានិភ័យអត្រាការប្រាក់ដូចខាងក្រោម៖

១) បន្តអនុវត្តវិធានការកំណត់ពិដានអត្រាការប្រាក់ (Interest Rate Cap) ចំពោះឥណទានដែលមានអត្រាការប្រាក់ប្រែប្រួល។

២) បន្តអនុវត្តវិធានការបំប្លែងឥណទានដែលមានអត្រាការប្រាក់ប្រែប្រួល ឱ្យទៅជាឥណទានដែលមានអត្រាការប្រាក់ថេរ (Fixed Rate) នៅថ្ងៃដកសាច់ប្រាក់ជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងពិចារណាលើជម្រើសដកសាច់ប្រាក់ជាកញ្ចប់តែមួយដង (Single Disbursement) ពីដៃគូអភិវឌ្ឍន៍ ប្រសិនបើមានភាពអំណោយផលជាងជម្រើសដកសាច់ប្រាក់ច្រើនដង (Multiple Disbursements) ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចយកសាច់ប្រាក់ដែលបានដក និងមិនទាន់យកទៅប្រើប្រាស់ទៅវិនិយោគ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីបានចំណូលមកជួយសម្រាលបន្ទុកការប្រាក់ និងកម្រៃផ្សេងៗ ដែលត្រូវទូទាត់ជូនដៃគូ។

ជាមួយគ្នានេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការអនុវត្តតាមវិធានការលម្អិតនីមួយៗ ដែលបានដាក់ចេញក្នុងក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៩ - ២០២៣ ដែលជាឧបសម្ព័ន្ធ ៤ នៃយុទ្ធសាស្ត្រនេះ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ជៀសវាងភាពចន្លោះប្រហោងជាយថាហេតុ ដែលនាំឱ្យមានការកើតឡើងនូវហានិភ័យធ្ងន់ធ្ងរហួសពីភាពដែលអាចគ្រប់គ្រងបាន។

៦.៧. បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ

រាជរដ្ឋាភិបាល នឹងបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមមាត្រា ៦៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមាត្រា ៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ គឺ *«មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ក្រោមការប្រទានសិទ្ធិពីនាយករដ្ឋមន្ត្រី ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ការបោះផ្សាយមូលបត្ររដ្ឋ, ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ, ការវិនិយោគ, ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា, ការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស, និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័នប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់*

ក្រោមជាតិ ឬមន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ឱ្យប្រាក់គេខ្ចី, ចេញលិខិតធានា, ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀតដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។»

៦.៨. បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី

ក្នុងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចកម្ពុជា តួនាទីរបស់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, ព្រមទាំងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ កាន់តែមានសារៈសំខាន់ ក្នុងការចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពរបស់រាជរដ្ឋាភិបាល ដែលធ្វើឱ្យទំហំនៃតម្រូវការខ្ចីឥណទានពីរដ្ឋ កាន់តែកើនធំជាងមុន។ ក្នុងន័យនេះ ដើម្បីបន្តពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- ពង្រឹងការអនុវត្តប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មប្រកាសនេះ ឱ្យស្របតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងធានាបាននូវសង្គតិភាពជាមួយរចនាសម្ព័ន្ធស្ថាប័នបច្ចុប្បន្ន។
- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមរយៈការអនុវត្ត «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»។

៦.៩. បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ

រាជរដ្ឋាភិបាលត្រូវបន្តអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយ និងកម្មវិធីកែទម្រង់ទាំងឡាយដែលបានដាក់ចេញរួចហើយ ហើយក៏ត្រូវបន្តដាក់ចេញនូវវិធានការនានាបន្ថែមទៀត ក្នុងរយៈពេលនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ សំដៅសម្រេចឱ្យបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម ក្នុងរង្វង់ **៧ ភាគរយ** និងកំណើនចំណូលថវិកាជាតិជាមធ្យមក្នុងរង្វង់ **០,៣ ពិន្ទុភាគរយ នៃ ផសស** ក្នុងមួយឆ្នាំ។

ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តសកម្មអនុវត្តកម្មវិធីកែទម្រង់ចំនួន ៣ ដែលជាមធ្យោបាយគន្លឹះក្នុងការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ច និងបង្កើនចំណូលថវិកាជាតិ រួមមាន៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, និង ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាល។

៦.១០. បន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តផែនការសកម្មភាពដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ ដែលជាឧបសម្ព័ន្ធ ៦ នៃយុទ្ធសាស្ត្រនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ដើម្បីគាំទ្រការអនុវត្តវិធានការជាយុទ្ធសាស្ត្រទាំងអស់ខាងលើ ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និងគណនេយ្យភាព, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកជាស្ថាប័ននាំមុខ ក្នុងការសម្របសម្រួលលើការអនុវត្តផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ៣។

ជំពូកទី៧
ការគាមជាន, ត្រួតពិនិត្យ, និង
ការវាយតម្លៃលើការអនុវត្ត
ទិធានការជាយុទ្ធសាស្ត្រ

ជំពូកទី៧
ការតាមដាន, ត្រួតពិនិត្យ, និងការវាយតម្លៃលើការអនុវត្តវិធានការជាយុទ្ធសាស្ត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលការអនុវត្តប្រព័ន្ធតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃលើការអនុវត្តវិធានការជាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

ប្រព័ន្ធរបាយការណ៍៖ ផែនការសកម្មភាពដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៣ នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (CAP ឬ GDAP ឬ MAP) ដែលជាកម្មវត្ថុនៃការរៀបចំអនុវត្ត របស់អគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា, សហគ្រាសសាធារណៈ, អគ្គនាយកដ្ឋានទ្រព្យរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្តាល, និងក្រុមការងារពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់គម្រោងវិនិយោគអនុវត្តតាមយន្តការ PPP ត្រូវផ្តល់របាយការណ៍ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈម នៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន មកលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ។

យន្តការដោះស្រាយបញ្ហាប្រឈម៖ គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានភារកិច្ចពិនិត្យ និងសម្រេចដាក់ចេញវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលបានកើតឡើងក្នុងពេលអនុវត្តវិធានការជាយុទ្ធសាស្ត្រ។ ក្នុងករណីមានវេទយិតភាព, ត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសម្តេចតេជោនាយករដ្ឋមន្ត្រី។

យន្តការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃអំពីវឌ្ឍនភាពជាប្រចាំ៖ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានភារកិច្ចតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ និងវិធានការដោះស្រាយបញ្ហាប្រឈម ដែលបានដាក់ចេញ និងរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ៕

សង្ខាតុក្រម

សន្ធានុក្រម
សម្រាប់ប្រើប្រាស់ក្នុង
យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣

កាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities) សំដៅដល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលក្នុងការទូទាត់សំណង ប្រសិនបើមានព្រឹត្តិការណ៍ជាក់លាក់ណាមួយកើតឡើងនាពេលអនាគត ដូចជា៖ ការធានា, ការរ៉ាប់រង, ការទូទាត់សំណងអន្តរាយ, ការបង់រំលោះទានដើម្បីធានាសមាជិកភាពកម្ពុជាក្នុងអង្គការនានា និងការផ្តល់សំណងតាមបណ្តឹងនីត្យានុកូល។

ការវិភាគចីរភាពបំណុល (Debt Sustainability Analysis – DSA) សំដៅដល់ការវាយតម្លៃលើសមត្ថភាពទូទាត់បំណុលរបស់ប្រទេសមួយ ក្នុងរយៈពេលមធ្យម និងវែង តាមរយៈការវាស់ស្ទង់កម្រិតបំណុលសាធារណៈបច្ចុប្បន្ន (ដោយរួមបញ្ចូលទាំងការធានា) បូករួមនឹងតម្រូវការខ្ចីថ្មីបន្ថែម ធៀបនឹងសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ រួមមាន៖ ផសស, ចំណូលថវិកាជាតិ, និងការនាំចេញ។ គេអាចសន្និដ្ឋានអំពីស្ថានភាពបំណុលសាធារណៈ និងកម្រិតហានិភ័យ នៃប្រទេសមួយបាន ដោយពិនិត្យទៅលើសូចនាករបំណុលគន្លឹះៗធៀបនឹងអនុបាតគោល។

តម្លៃបច្ចុប្បន្ននៃបំណុល (Present Value) សំដៅដល់ទំហំសន្និធិបំណុល ក្រោយដកតម្លៃអប្បហារ (កម្ពុជា ប្រើប្រាស់អត្រាអប្បហាររួម ៥ ភាគរយ តាមបទដ្ឋានបច្ចេកទេសរបស់ IMF)។ តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ក្នុងការគណនាអនុបាតបំណុល សម្រាប់ក្រុមប្រទេសដែលនៅទទួលបានឥណទានសម្បទាន គេមិនប្រើតម្លៃចារឹកនៃបំណុលទេ គឺគេប្រើតម្លៃបច្ចុប្បន្ននៃបំណុល។ ចំពោះកម្ពុជាក៏ដូចគ្នាដែរ គឺត្រូវប្រើតម្លៃបច្ចុប្បន្ននៃបំណុល ព្រោះថា ឥណទានដែលរដ្ឋខ្ចីពីក្រៅប្រទេសទាំងអស់ សុទ្ធសឹងជាឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។

ធាតុអំណោយ (Grant Element) សំដៅដល់ផលធៀបរវាង៖ ១) ផលដកនៃតម្លៃចារឹករបស់ឥណទាន និងតម្លៃបច្ចុប្បន្ននៃការទូទាត់សេវាបំណុល, និង ២) តម្លៃចារឹករបស់ឥណទាន។ ធាតុអំណោយ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការវាស់ស្ទង់កម្រិតសម្បទាននៃឥណទាន។

បំណុលសាធារណៈ (Public Debt) សំដៅដល់បំណុលរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត។ បំណុលសាធារណៈសរុប រួមបញ្ចូលនូវ៖ បំណុលសាធារណៈក្នុងប្រទេស និងបំណុលសាធារណៈក្រៅប្រទេស ដោយរួមទាំងបំណុលដែលមានការធានាពីរដ្ឋ។

បំណុលសាធារណៈក្នុងប្រទេស (Public Domestic Debt) សំដៅដល់បំណុលក្នុងប្រទេសរបស់រដ្ឋដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយគិតបញ្ចូលទាំងបំណុលដែលមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បំណុលនេះ មានតែសញ្ញាប័ណ្ណរដ្ឋមិនអាចជួញដូរបាន ដែលរាជរដ្ឋាភិបាលបានបោះផ្សាយដើម្បីបំពេញទុនឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលនូវសញ្ញាប័ណ្ណរដ្ឋដែលអាចជួញដូរបានផងដែរ ក្នុងករណី រាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។

បំណុលសាធារណៈក្រៅប្រទេស (Public External Debt) សំដៅដល់បំណុលក្រៅប្រទេសរបស់រដ្ឋដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយគិតបញ្ចូលទាំងបំណុលដែលមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បំណុលនេះមានតែការខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីក្រៅប្រទេសប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលផងដែរនូវឧបករណ៍បំណុលផ្សេងទៀត ដូចជា សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យជាដើម ក្នុងករណីរាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។

បំណុលមរតក (Old Debt) សំដៅដល់បំណុលដែលបន្សល់ទុកដោយរដ្ឋាភិបាលជំនាន់មុន។ ក្នុងបរិការណ៍កម្ពុជា បំណុលមរតក គឺជាបំណុលដែលបានកើតឡើងមុនឆ្នាំ១៩៩៣។ ភាគច្រើននៃបំណុលទាំងនេះត្រូវបានចរចាដោះស្រាយជាមួយដៃគូរួចរាល់ហើយ ក្នុងនោះ មួយចំនួនត្រូវបានទូទាត់សងរួចរាល់ជាស្ថាពរ និងមួយចំនួនកំពុងត្រូវបានទូទាត់តាមកម្មវិធីសងនៃកិច្ចព្រមព្រៀង។ ដោយឡែក ចំពោះបំណុលមរតកដែលនៅសេសសល់ បច្ចុប្បន្ន, រាជរដ្ឋាភិបាលបាននិងកំពុងខិតខំបន្តចរចាដោះស្រាយជាមួយដៃគូឱ្យបានជ្រះស្រឡះ។

មូលបត្ររដ្ឋ (Government Securities) សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល។ មូលបត្ររដ្ឋ រួមមាន៖

១- ប័ណ្ណរតនាគារដែលមានឥណទានប្រតិទានតិចជាងមួយឆ្នាំ

២- សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ

៣- សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់ជាមួយនឹងអត្រាអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ

៤- មូលបត្ររដ្ឋដែលមិនអាចជួញដូរបាន

៥- មូលបត្ររដ្ឋផ្សេងៗដទៃទៀត ដែលបោះផ្សាយស្របតាមច្បាប់អនុញ្ញាត។

រយៈពេលអនុគ្រោះ (Grace Period) សំដៅដល់រយៈពេលចន្លោះពីពេលដែលកិច្ចព្រមព្រៀងឥណទាន ឬកិច្ចព្រមព្រៀងការផ្តល់ឥណទានចូលជាធរមាន រហូតដល់ពេលត្រូវសងប្រាក់ដើមដំបូង ដោយក្នុងរយៈពេលនោះ មានតែការប្រាក់ប៉ុណ្ណោះ ដែលត្រូវទូទាត់។

សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ (Sovereign Bond) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលត្រូវបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលលើទីផ្សារអន្តរជាតិ។

សន្និធិបំណុល (Debt Outstanding/ Debt Stock) សំដៅដល់ទំហំបំណុលជាក់ស្តែង ដែលឥណទាយកមិនទាន់ទូទាត់ជូនឥណទាយក។ ជាទូទៅសន្និធិបំណុល ស្មើនឹងការដកសាច់ប្រាក់សរុប ដកឱ្យ៖ ការបង្វែរសាច់ប្រាក់ទៅដៃគូអភិវឌ្ឍន៍វិញ និងការទូទាត់ប្រាក់ដើមសរុប។ ជាករណីពិសេស សម្រាប់កម្ពុជា សន្និធិបំណុលសាធារណៈក្រៅប្រទេស ស្មើនឹង៖ ការដកសាច់ប្រាក់សរុប ដកឱ្យ ការបង្វែរសាច់ប្រាក់ទៅដៃគូអភិវឌ្ឍន៍វិញ, ការទូទាត់ប្រាក់ដើមសរុប, និងបំណុលដែលបានលុបដោយដៃគូអភិវឌ្ឍន៍ បូកនឹង បំណុលមរតកដែលបានចរចាដោះស្រាយរួច ហើយកំពុងសង និងបំណុលមរតកដែលកំពុងចរចាដោះស្រាយ។

សេវាបំណុល (Debt Service) សំដៅដល់ប្រាក់ដើម ការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀត។

ហិរញ្ញប្បទានឥតសំណង (Grant) សំដៅដល់ហិរញ្ញប្បទាន ក្រោមទម្រង់នានា ដូចជា៖ សាច់ប្រាក់, ទំនិញ, ឬសេវា ដែលមិននាំឱ្យកើតមានបន្ទុកសេវាបំណុល។

ឥណទាន (Loan) សំដៅដល់ហិរញ្ញប្បទាន ក្រោមទម្រង់នានា ដូចជា៖ សាច់ប្រាក់, ទំនិញ, ឬសេវា ដែលនាំឱ្យកើតមានបន្ទុកសេវាបំណុល។

ឥណទានពាណិជ្ជកម្ម (Commercial Loan) សំដៅដល់ឥណទានដែលហិរញ្ញប្បទានដោយធនាគារពាណិជ្ជ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត តាមលក្ខខណ្ឌឥណទានទីផ្សារ។

ឥណទានសម្បទាន (Concessional Loan) សំដៅដល់ឥណទានដែលមានលក្ខខណ្ឌអនុគ្រោះខ្ពស់ជាងលក្ខខណ្ឌឥណទានទីផ្សារ ឬលក្ខខណ្ឌឥណទានពាណិជ្ជកម្ម ដោយមានធាតុអំណោយចាប់ពី ៣៥ ភាគរយឡើងទៅ។

ឥណប្រតិទាន (Maturity) សំដៅដល់រយៈពេលខ្ចី ដោយគិតចាប់ពីពេលដែលកិច្ចព្រមព្រៀងឥណទាន ឬកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន ចូលជាធរមាន រហូតដល់បំណុលត្រូវបានសងអស់។ ឥណប្រតិទាន ស្មើនឹងរយៈពេលអនុគ្រោះ បូកនឹងរយៈពេលសងដើម។

ឥឌ្ឍនភាពនៃការអនុវត្ត យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង បំណុលសាធារណៈ ២០១៥ - ២០១៨

មាតិកា

១. ការខ្ចីប្រចាំឆ្នាំ ១
២. ការប្រើប្រាស់ឥណទានសម្បទានសម្រាប់វិស័យអាទិភាព ២
២.១. ការខ្ចីឥណទានសម្បទានតាមវិស័យ ២
២.២. ការដកសាច់ប្រាក់ពីឥណទានសម្បទានតាមវិស័យ ៣
៣. ការពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ៥
៣.១. ក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ ៥
៣.២. ក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ៦
៣.៣. ក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ៦
៣.៤. ក្របខ័ណ្ឌវិនិយោគសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៨
៤. ការសម្រិតសម្រាំងឥណទានសម្បទាន ៨
៥. ការអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ ៩
៦. ការអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ១០
៧. ការកៀរគរហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានពីប្រភពផ្សេងទៀត ១១
៧.១. ការកៀរគរហិរញ្ញប្បទានឥតសំណង ១១
៧.២. ការកៀរគរហិរញ្ញប្បទានពីវិស័យឯកជន តាមយន្តការ PPP ១៣
៧.៣. ការអភិវឌ្ឍទីផ្សារមូលបត្រ ១៤
៨. ការគ្រប់គ្រង និងតាមដានហានិភ័យបំណុល ១៤
៨.១. ហានិភ័យហិរញ្ញប្បទាននៃគម្រោង ឬ ហានិភ័យបុនហិរញ្ញប្បទាន (Project Funding Risk) ១៤
៨.២. ហានិភ័យទីផ្សារ (Market Risk) ១៤
៨.៣. ហានិភ័យឥណទាន (Credit Risk) ១៦
៨.៤. ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk) ១៦
៨.៥. ហានិភ័យប្រតិបត្តិការ (Operational Risk) ១៨
៨.៦. ហានិភ័យថវិកា (Fiscal Risk) ១៨
៨.៧. កាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities) ១៩
៨.៧.១. វិស័យធនាគារ និងហិរញ្ញវត្ថុ (Banking and Financial Sector) ១៩
៨.៧.២. ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលគ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ២០
៨.៧.៣. ការធានារបស់រដ្ឋ (Guarantee) ២០

៩. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២១
៩.១. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ២១
៩.២. ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ២១
១០. វឌ្ឍនភាពការងារពាក់ព័ន្ធផ្សេងទៀត ២១
១០.១. អតិរេកចរន្តសម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់ ២១
១០.២. ការដោះស្រាយបំណុលមរតក ២២
១០.៣. ការវាយតម្លៃគោលនយោបាយ និងស្ថាប័នប្រទេស ២៣
១០.៤. ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ ២៤

បញ្ជីតារាង៖

- តារាងទី១៖ ការខ្វីឥណទានសម្បទានឆ្នាំ២០១៥-២០១៨ ..... ១
- តារាងទី២៖ ការខ្វីឥណទានសម្បទានតាមវិស័យឆ្នាំ២០១៥-២០១៨ ..... ៣
- តារាងទី៣៖ ការដកសាច់ប្រាក់ពីឥណទានសម្បទានតាមវិស័យឆ្នាំ២០១៥-២០១៨ ..... ៤
- តារាងទី៤៖ សូចនាករថ្លៃដើម និងហានិភ័យឥណទានសម្បទានឆ្នាំ២០១៥-២០១៨ ..... ៩
- តារាងទី៥៖ ហិរញ្ញប្បទានឥតសំណងតាមវិស័យឆ្នាំ២០១៥-២០១៨ ..... ១២
- តារាងទី៦៖ គម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ១៣
- តារាងទី៧៖ ពិន្ទុនៃការវាយតម្លៃគោលនយោបាយនិងស្ថាប័នប្រទេសរបស់កម្ពុជា ឆ្នាំ២០០៩-២០១៨ ..... ២៣
- តារាងទី៨៖ ពិន្ទុនៃការវាយតម្លៃសូចនាករគោលនយោបាយបំណុលសម្រាប់កម្ពុជា ឆ្នាំ២០០៩-២០១៨ ..... ២៤

បញ្ជីក្រាហ្វ៖

- ក្រាហ្វទី១៖ ពិដានៃការខ្វីឥណទានសម្បទានប្រចាំឆ្នាំ ពីឆ្នាំ១៩៩៣ - ២០១៨ ..... ២
- ក្រាហ្វទី២៖ កំណើន ផសស ២០១៥ - ២០១៨ ..... ៩
- ក្រាហ្វទី៣៖ ចំណូលថវិកាជាតិ ២០១៥-២០១៨ ..... ១០
- ក្រាហ្វទី៤៖ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ធៀបនឹងចំណាយវិនិយោគសាធារណៈសរុប ២០០៩ - ២០១៨ ..... ១៣
- ក្រាហ្វទី៥៖ ប្រៀបធៀបសមាសភាគរូបិយប័ណ្ណបំណុលសាធារណៈក្រៅប្រទេស រវាងចុងឆ្នាំ២០១៤ និងចុងឆ្នាំ២០១៨ ..... ១៥
- ក្រាហ្វទី៦៖ កម្មវិធីទូទាត់សេវាបំណុលមុន និងក្រោយការអនុវត្តយុទ្ធសាស្ត្រ ១៧
- ក្រាហ្វទី៧៖ ព្យាករណ៍កម្មវិធីទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ..... ១៧
- ក្រាហ្វទី៨៖ ចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិធៀបនឹងអតិរេកចរន្តឆ្នាំ២០១៥ - ២០១៨ ..... ២២

វឌ្ឍនភាព
នៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨

រាជរដ្ឋាភិបាលបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការជាយុទ្ធសាស្ត្រទាំង ៩ ចំណុច ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗ និងវឌ្ឍនភាពតាមវិធានការជាយុទ្ធសាស្ត្រនីមួយៗ ដូចខាងក្រោម៖

១. ការខ្ចីប្រចាំឆ្នាំ

រាជរដ្ឋាភិបាលខិតខំកៀរគរឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍នានា មកបំពេញតម្រូវការវិនិយោគសាធារណៈសរុប បានចំនួនប្រមាណ **៣,១ ប៊ីលានអេសដេអ៊ែរ** សមមូលនឹងប្រមាណ **៤,៥ ប៊ីលានដុល្លារអាមេរិក** ព្រមទាំងរក្សាបាននូវទំហំនៃការខ្ចីឥណទានសម្បទានប្រចាំឆ្នាំ មិនឱ្យលើសពីពិដានដែលកំណត់ដោយច្បាប់។ ជាក់ស្តែង ការខ្ចីឥណទានសម្បទាន ក្នុងឆ្នាំ២០១៥ - ២០១៨ មានដូចតារាងទី១ ខាងក្រោម៖

តារាងទី១- ការខ្ចីឥណទានសម្បទានឆ្នាំ២០១៥ - ២០១៨

ឯកតា៖ ជាលាន

ឆ្នាំ	ច្បាប់អនុញ្ញាត	អនុវត្ត		អនុវត្តធៀបនឹងច្បាប់
	(អេសដេអ៊ែរ)	(អេសដេអ៊ែរ)	(ដុល្លារអាមេរិក)	
២០១៥	៦០០	៥៥៨	៧៧៨	៩៣,១%
២០១៦	៧០០	៦២៨	៨៤៦	៨៩,៨%
២០១៧	៧០០	៦៨៥	៩៧៨	៩៧,៨%
២០១៨	១ ៥១៤	១ ៣១៩	១ ៨៤៣	៨៧,១%
សរុប (២០១៥ - ២០១៨)	**៣ ៥១៤**	**៣ ១៩០**	**៤ ៤៤៦**	**៩០,៨%**
មធ្យមភាគ (២០១៥ - ២០១៨)	**៨៧៨,៥**	**៧៩៧**	**១ ១១២**	**៩០,៨%**
សរុប (១៩៩៣ - ២០១៨)	**៩ ៣៦៣**	**៨ ១៥០**	**១១ ៣៩១**	**៨៧,០%**

ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

តាមទិន្នន័យក្នុងតារាងទី១ ខាងលើ បង្ហាញថា ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលទទួល បានឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ ជាមធ្យមប្រមាណ **៨០០ លានអេសដេអ៊ែរ** សមមូលនឹងប្រមាណ **១,១ ប៊ីលានដុល្លារអាមេរិក** ក្នុងមួយឆ្នាំ ពោលគឺ សម្រេចបានប្រមាណ **៩១ ភាគរយ** នៃច្បាប់។ ការសម្រេចបាននូវសមិទ្ធផលនេះ សបញ្ជាក់ឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរឥណទានសម្បទាន និងការកើនឡើងនូវសមត្ថភាពខ្ចី សម្រាប់វិនិយោគសាធារណៈក្នុងវិស័យអាទិភាពនានា ព្រមទាំងឆ្លុះបញ្ចាំងពីគុណភាពនៃការព្យាករតម្រូវការវិនិយោគសាធារណៈសរុប ផងដែរ។


ជារួម បើគិតចាប់ពីដើមឆ្នាំ១៩៩៣ រហូតមកដល់ដំណាច់ឆ្នាំ២០១៨ រាជរដ្ឋាភិបាលទទួលបានឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ សរុបប្រមាណ **៨,២ ប៊ីលានអេសដេអ៊ែរ** សមមូលនឹងប្រមាណ **១១,៤ ប៊ីលានដុល្លារអាមេរិក** ពោលគឺ សម្រេចបានប្រមាណ **៨៧ ភាគរយ** នៃច្បាប់។

បើគិតចាប់ពីឆ្នាំ១៩៩៣ មក រាជរដ្ឋាភិបាលបានបង្កើនពិដាននៃការខ្ចីឥណទានសម្បទានប្រចាំឆ្នាំចំនួន ៤ ដំណាក់កាលធំៗ គឺ៖ **១) ដំណាក់កាលទី១** ពីក្រោម ២០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ នៅ

ឆ្នាំ១៩៩៣-១៩៩៧ ដល់ ២០០ លានអេសដៅអ៊ែរ ក្នុងមួយឆ្នាំ នៅឆ្នាំ១៩៩៨ - ២០០៨, **២) ដំណាក់កាលទី២** ដល់រង្វង់ ៤០០ លានអេសដៅអ៊ែរ ក្នុងមួយឆ្នាំ នៅឆ្នាំ២០០៩-២០១១, **៣) ដំណាក់កាលទី៣** ដល់រង្វង់ ៦០០លាន - ៧០០ លានអេសដៅអ៊ែរ ក្នុងមួយឆ្នាំ នៅឆ្នាំ២០១២-២០១៧, និង **៤) ដំណាក់កាលទី៤** រហូតដល់កម្រិតជាង ១,៥ ប៊ីលានអេសដៅអ៊ែរ ក្នុងមួយឆ្នាំ នៅឆ្នាំ២០១៨។

នៅដំណាក់កាលទី៣ និងទី៤ រាជរដ្ឋាភិបាលបានបង្កើនពិដានៃការខ្ចីឥណទានសម្បទានប្រចាំឆ្នាំជាគំហុក បើធៀបនឹងដំណាក់កាលមុនៗ ដោយហេតុថា៖ ១) កំណើនសេដ្ឋកិច្ច និងចំណូលថវិកាជាតិ សុទ្ធតែសម្រេចបានលើសពីគោលដៅរំពឹងទុក, ២) មានគម្រោងវិនិយោគសាធារណៈល្អៗច្រើនក្នុងវិស័យអាទិភាព, និង ៣) ផ្អែកតាមលទ្ធផលនៃការវិភាគចីរភាពបំណុល ប្រកបដោយភាពប្រយ័ត្នប្រយែង សមត្ថភាពខ្ចីឥណទានសម្បទានប្រចាំឆ្នាំពិតប្រាកដរបស់កម្ពុជា មានកម្រិតធំជាងទ្វេដង បើធៀបនឹងទំហំពិដានៃការខ្ចីឥណទានសម្បទានប្រចាំឆ្នាំដែលបានកំណត់ក្នុងច្បាប់។ ពិដានៃការខ្ចីឥណទានសម្បទានប្រចាំឆ្នាំ ពីឆ្នាំ១៩៩៣ - ២០១៨ មានដូចក្រាហ្វទី១ ខាងក្រោម៖

ក្រាហ្វទី១- ពិដានៃការខ្ចីឥណទានសម្បទានប្រចាំឆ្នាំ ពីឆ្នាំ១៩៩៣ - ២០១៨



ប្រភព៖ ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២. ការប្រើប្រាស់ឥណទានសម្បទានសម្រាប់វិស័យអាទិភាព

២.១. ការខ្ចីឥណទានសម្បទានតាមវិស័យ

ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានសម្បទានជាមួយដៃគូអភិវឌ្ឍន៍សរុបចំនួន **៨១ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់សរុបប្រមាណ **៤,៥ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ៖ វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានចំនួន **៦០ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់ប្រមាណ **៣,៨ ប៊ីលានដុល្លារអាមេរិក** និងវិស័យអាទិភាពចំពោះមុខផ្សេងទៀត មានចំនួន **២១ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់ប្រមាណ **៥៩៨ លានដុល្លារអាមេរិក**។

ការខ្ចីឥណទានសម្បទានជាក់ស្តែងពីដៃគូអភិវឌ្ឍន៍តាមវិស័យក្នុងឆ្នាំ ២០១៥ - ២០១៨ មានដូចតារាងទី២ ខាងក្រោម៖

តារាងទី២- ការខ្វីឥណទានសម្បទានតាមវិស័យឆ្នាំ២០១៥ - ២០១៨

ឯកតា៖ ជាលានដុល្លារអាមេរិក

វិស័យ	២០១៥	២០១៦	២០១៧	២០១៨	សរុប (២០១៥-២០១៨)	មធ្យមភាគ (២០១៥-២០១៨)	សរុប (១៩៩៣-២០១៨)
ក- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត							
ចំនួនគម្រោង/កម្មវិធី	១៤	១៤	១៣	១៩	៦០	១៥	២៣១
ទំហំឥណទាន	៧៣៩	៦២៥	៨៧៨	១ ៦០៦	៣ ៨៤៨	៩៦២	៩ ៨៩៩
ភាគរយ	*៩៥,០%*	*៧៣,៩%*	*៨៩,៨%*	*៨៧,១%*	*៨៦,៦%*	*៨៦,៦%*	*៨៦,៩%*
ខ- អាទិភាពចំពោះមុខផ្សេងទៀត							
ចំនួនគម្រោង/កម្មវិធី	២	១១	៣	៥	២១	៥	៨១
ទំហំឥណទាន	៣៩	២២១	១០០	២៣៧	៥៩៨	១៤៩	១ ៤៩៣
ភាគរយ	*៥,០%*	*២៦,១%*	*១០,២%*	*១២,៩%*	*១៣,៤%*	*១៣,៤%*	*១៣,១%*
សរុប							
ទំហំឥណទាន	**៧៧៨**	**៨៤៦**	**៩៧៨**	**១ ៨៤៣**	**៤ ៤៤៦**	**១ ១១២**	**១១ ៣៩១**
ចំនួនគម្រោង/កម្មវិធី	**១៦**	**២៥**	**១៦**	**២៤**	**៨១**	**២០**	**៣១២**

ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

តាមទិន្នន័យក្នុងតារាងទី២ ខាងលើ បង្ហាញថា ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ឥណទានសម្បទានដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងខ្ចីពីដៃគូអភិវឌ្ឍន៍ ភាគច្រើនលើសលុបប្រមាណ **៨៧ ភាគរយ** ជាគម្រោង/កម្មវិធីវិនិយោគសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវថ្នល់, ស្ពាន, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការផ្គត់ផ្គង់ទឹកស្អាត, និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ និងប្រមាណ **១៣ ភាគរយ** ទៀត ជាគម្រោង/កម្មវិធីវិនិយោគសាធារណៈក្នុងវិស័យអាទិភាពចំពោះមុខផ្សេងទៀត ដូចជា៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, អប់រំ, ទេសចរណ៍, សេវាសាធារណៈ, សុខាភិបាល, ជីធ្លី, និងកសិកម្ម។ តួលេខទាំងនេះ បញ្ជាក់ថា ការខ្វីឥណទានសម្បទានក្នុងឆ្នាំ២០១៥ - ២០១៨ គឺបានអនុវត្តស្របតាមវិធានការដោយុទ្ធសាស្ត្រ នៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដែលកំណត់ឱ្យខ្វីសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងបង្កើនផលិតភាពផលិតកម្ម។

ជារួម បើគិតចាប់ពីដើមឆ្នាំ១៩៩៣ រហូតមកដល់ដំណាច់ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានសម្បទានជាមួយដៃគូអភិវឌ្ឍន៍សរុបចំនួន **៣១២ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់សរុបប្រមាណ **១១,៤ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, អាកាសយានដ្ឋាន, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការផ្គត់ផ្គង់ទឹកស្អាត, និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ មានចំនួន **២៣១ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់សរុបប្រមាណ **៩,៩ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៨៧ ភាគរយ** និងវិស័យអាទិភាពចំពោះមុខផ្សេងទៀត ដូចជា៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, ជីធ្លី, និងកសិកម្ម មានចំនួន **៨១ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់សរុបប្រមាណ **១,៥ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **១៣ ភាគរយ**។

២.២. ការដកសាច់ប្រាក់ពីឥណទានសម្បទានតាមវិស័យ

ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់

ជាក់ស្តែងសរុបប្រមាណ **២,៥ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ ប្រមាណ **២,៣ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៩០ ភាគរយ** ត្រូវបានប្រើប្រាស់ដើម្បីវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រមាណ **២៤៧ លានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **១០ ភាគរយ** ទៀត ត្រូវបានប្រើប្រាស់ដើម្បីវិនិយោគសាធារណៈលើវិស័យអាទិភាពចំពោះមុខផ្សេងទៀត។

ការដកសាច់ប្រាក់ពីឥណទានសម្បទានតាមវិស័យជាក់ស្តែងក្នុងឆ្នាំ២០១៥ - ២០១៨ មានដូចតារាងទី៣ ខាងក្រោម៖

តារាងទី៣- ការដកសាច់ប្រាក់ពីឥណទានសម្បទានតាមវិស័យឆ្នាំ២០១៥ - ២០១៨

ឯកតា៖ ជាលានដុល្លារអាមេរិក

ការដកសាច់ប្រាក់តាមវិស័យ	២០១៥	២០១៦	២០១៧	២០១៨	សរុប (២០១៥-២០១៨)	មធ្យមភាគ (២០១៥-២០១៨)	សរុប (១៩៩៣-២០១៨)
ក- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត	៥៥២	៤៦៦	៦៣៥	៦០៦	២ ២៦០	៥៦៥	៦ ៣៤៨
ភាគរយ	*៩៣%*	*៨៦%*	*៨៨%*	*៩៤%*	*៩០%*	*៩០%*	*៨៧%*
ខ- វិស័យអាទិភាពចំពោះមុខផ្សេងទៀត	៤៣	៧៧	៨៧	៤០	២៤៧	៦២	៩៤៣
ភាគរយ	*៧%*	*១៤%*	*១២%*	*៦%*	*១០%*	*១០%*	*១៣%*
សរុប (ក+ខ)	**៥៩៥**	**៥៤៣**	**៧២២**	**៦៤៦**	**២ ៥០៧**	**៦២៧**	**៧ ២៩១**
បម្រែបម្រួលប្រចាំឆ្នាំ	**-៨%**	**-៩%**	**+៣៣%**	**-១១%**	**-**	**១%****	**-**
ការខ្វែឥណទានសម្បទានសរុប							**១១ ៣៩១**
ការដកសាច់ប្រាក់សរុបធៀបនឹងការខ្វែសរុប							**៦៤%**

** ការដកសាច់ប្រាក់ក្នុងឆ្នាំ២០១៤ មានចំនួនសរុបប្រមាណ ៦៤៩ លានដុល្លារអាមេរិក*

*** បម្រែបម្រួលជាមធ្យមក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៥-២០១៨*

ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

តាមទិន្នន័យក្នុងតារាងទី៣ ខាងលើ បង្ហាញថា ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍ជាមធ្យមប្រមាណ **៦៣០ លានដុល្លារអាមេរិក** ក្នុងមួយឆ្នាំ ពោលគឺ ជាមធ្យម ការដកសាច់ប្រាក់ មានការកើនឡើងប្រមាណ **១ ភាគរយ** ក្នុងមួយឆ្នាំ។ សាច់ប្រាក់ដែលបានដកទាំងនេះភាគច្រើនលើសលុបប្រមាណ **៩០ ភាគរយ** ត្រូវបានប្រើប្រាស់ដើម្បីហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, កំពង់ផែ, ការផ្គត់ផ្គង់ទឹកស្អាត, និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ និងប្រមាណ **១០ ភាគរយ** ទៀត ត្រូវបានប្រើប្រាស់ដើម្បីហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាពចំពោះមុខផ្សេងទៀត ដូចជា៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, ជីធ្លី, និងកសិកម្ម។

ជារួម បើគិតចាប់ពីដើមឆ្នាំ១៩៩៣ រហូតដល់ត្រឹមដំណាច់ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់ជាក់ស្តែងសរុបប្រមាណ **១១,៤ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៦៤ ភាគរយ** នៃទំហំឥណទានសម្បទានសរុបដែលបានចុះកិច្ចព្រមព្រៀង។ សាច់ប្រាក់ដែលបានដកទាំងនេះ ប្រមាណ **៦,៣ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៨៧ ភាគរយ** ត្រូវបានប្រើប្រាស់ដើម្បីហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការផ្គត់ផ្គង់ទឹកស្អាត, និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់

និងប្រមាណ **៩៤៣ លានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **១៣ ភាគរយ** ទៀតត្រូវបានប្រើប្រាស់ ដើម្បីហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាពចំពោះមុខផ្សេងទៀត ដូចជា៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, ជីផ្លី, និងកសិកម្ម។

៣. ការពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ

ជាការពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន និងគ្រប់កម្រិតរដ្ឋបាល រាជរដ្ឋាភិបាលបានជំរុញរៀបចំឯកសារដ៏មានសារៈសំខាន់មួយគឺ «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»។ ទន្ទឹមនេះ ក៏សម្រេចបាននូវវឌ្ឍនភាព គួរឱ្យកត់សម្គាល់ជាច្រើន ក្នុងការពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ តាមប្រភពហិរញ្ញប្បទាននីមួយៗ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានដូចខាងក្រោម៖

៣.១. ក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ

ស្របតាមទិសដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ បានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តនូវឯកសារគតិយុត្តសំខាន់ៗជាច្រើន ក្នុងការបន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ (គម្រោងវិនិយោគផ្ទាល់) ដូចខាងក្រោម៖

– បានរៀបចំ និងដាក់ឱ្យអនុវត្តនូវសារាចរសំខាន់ៗចំនួន ២ ក្នុងឆ្នាំ២០១៦ រួមមាន៖ ១) សារាចរស្តីពីការផ្តល់ថវិកាបុរេប្រទានសម្រាប់ចំណាយថវិកាវិនិយោគសាធារណៈ ជួសជុល និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានអនុវត្តដោយអង្គភាពរដ្ឋ ក្នុងគោលបំណងគ្រប់គ្រង, ចាត់ចែង, ប្រើប្រាស់ និងទូទាត់ថវិកាបុរេប្រទាន ឱ្យមានប្រសិទ្ធភាព ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន; និង ២) សារាចរណែនាំស្តីពីបែបបទរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពអនុវត្តគម្រោងហិរញ្ញវត្ថុ ដោយថវិការដ្ឋ ក្នុងគោលបំណងដាក់ចេញនូវបែបបទរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់អង្គភាពអនុវត្តគម្រោងហិរញ្ញប្បទានដោយថវិកាជាតិ ដើម្បីប្រសិទ្ធភាពក្នុងការអនុវត្តថវិកា, ការកត់ត្រាចំណាយ, ការអនុវត្តនិងតាមដានគម្រោង ដោយរួមទាំងការធ្វើសវនកម្មគម្រោង។

– បានរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីបែបបទ និងនីតិវិធីចំណាយលើការជួសជុលអន្តរាគមន៍បន្ទាន់ផ្លូវថ្នល់, ស្ពាន, និងលូ ក្រោមអាណាប័កក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្នុងឆ្នាំ២០១៧។ ប្រកាសនេះ មានគោលបំណងសំខាន់ ក្នុងការបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការ ប្រើប្រាស់ចំណាយអន្តរាគមន៍បន្ទាន់។

– បានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពីនីតិវិធី និងបែបបទត្រួតពិនិត្យចំណាយវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់)។ គោលការណ៍ណែនាំនេះមានគោលបំណង ដើម្បីលើកកម្ពស់ និងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការចំណាយវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) ស្របតាមបទដ្ឋានគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុពាក់ព័ន្ធ ជាធរមាន។

– បានរៀបចំ និងដាក់ឱ្យអនុវត្តនូវឯកសារទស្សនាទានស្តីពីចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់)។ ឯកសារទស្សនាទាននេះ មានគោលបំណងសំខាន់ ក្នុងការរៀបចំគោលការណ៍ណែនាំលម្អិត នៃដំណាក់កាលនៃវដ្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយ

ថវិកាជាតិ (គម្រោងវិនិយោគផ្ទាល់)។

ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញនូវវិធានការគត់មត់មួយចំនួន ដើម្បីជំរុញការបង្កើនតម្លៃនៃលុយ (Value for Money) និងការពង្រឹងស្តង់ដាបច្ចេកទេសនៃគម្រោងស្ថាបនា និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងបានគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍សំខាន់ៗ នៃការអនុវត្តឥណទានថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) សំដៅរួមចំណែកធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា។

៣.២. ក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍

ជាការបន្តពង្រឹងយន្តការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ បាន៖

– អនុម័ត និងដាក់ឱ្យអនុវត្តឯកសារណែនាំលម្អិតស្តីពី៖ ១) ដំណើរការធ្វើអត្តសញ្ញាណកម្ម រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសារធារណៈ, ២) កិច្ចដំណើរការលទ្ធកម្ម, និង ៣) កិច្ចដំណើរការពិនិត្យសំណើសុំថវិកា ក្រោមក្របខ័ណ្ឌកម្មវិធី/គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ តាមរយៈប្រកាសលេខ ៧២៤ សហវ-ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨។

– បន្តជំរុញ និងចរចាជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីមួយចំនួន ឱ្យចូលរួមអនុវត្តប្រព័ន្ធរបស់ប្រទេស ក្រោមក្របខ័ណ្ឌនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោង រួមមាន៖ ១) មូលនិធិសកល (Global Fund), ២) សហភាពអឺរ៉ុប (European Union), ៣) ធនាគារវិនិយោគអឺរ៉ុប (European Investment Bank), និង ៤) ភាគីចិន លើគម្រោងអាទិភាពមួយចំនួន។

– បន្តផ្តល់វគ្គបណ្តុះបណ្តាលជូនមន្ត្រីអនុវត្តគម្រោងក្រោមហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ស្តីពី នីតិវិធីរួមបច្ចុប្បន្នកម្ម ដែលរួមមាន៖ ការគ្រប់គ្រងរដ្ឋបាល, ការគ្រប់គ្រងហិរញ្ញវត្ថុ, និងកិច្ចលទ្ធកម្មគម្រោង ក្រោមកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។

៣.៣. ក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)

រាជរដ្ឋាភិបាលបានអនុម័តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការ PPP សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦ - ២០២០ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ និងបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ សំដៅសម្រេចបាននូវចក្ខុវិស័យក្នុងការបង្កើត និងអនុវត្តឱ្យបានពេញលេញ នូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការ PPP ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព, និងភាពប្រទាក់ក្រឡា។

តាមរយៈគោលនយោបាយនេះ រាជរដ្ឋាភិបាល បានដាក់ចេញនូវផែនការសកម្មភាពស្តីពីការអភិវឌ្ឍយន្តការ PPP សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦ - ២០២០ ដែលមានវិធានការជាយុទ្ធសាស្ត្រជាអាទិភាពសំខាន់ៗ ចំនួន ៤ រួមមាន៖ ១) ការពិនិត្យ និងរៀបចំក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, ២) ការរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុ, ៣) ការរៀបចំ និងកំណត់យន្តការស្ថាប័ន, និង ៤) ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស។ វឌ្ឍនភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រនីមួយៗមានដូចខាងក្រោម៖

ក) ការពិនិត្យ និងរៀបចំក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ

– បានពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំង

បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពី PPP ឱ្យស្របតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងឧត្តមានុវត្ត ជាអន្តរជាតិ។ សេចក្តីព្រាងច្បាប់ថ្មីនេះ គ្រោងនឹងអនុម័ត និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩ ស្របតាមផែនការ សកម្មភាពដែលបានដាក់ចេញនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី៣។

– បាននិងកំពុងរៀបចំសេចក្តីព្រាងនីតិវិធីរួមប្រតិបត្តិការ (SOP) សម្រាប់គ្រប់គ្រងវដ្តគម្រោង PPP។ សេចក្តីព្រាងឯកសារទាំងនេះ នឹងត្រូវលើកយកមកពិនិត្យពិភាក្សា, អនុម័ត, និងដាក់ឱ្យអនុវត្ត បន្ទាប់ពីច្បាប់ថ្មី ស្តីពី PPP ត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ។

ខ) ការរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុ

– បានអនុម័ត និងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility - PDF)។ ទោះជាយ៉ាងនេះក្តី មូលនិធិនេះនៅពុំទាន់មានថវិកានៅឡើយ ដែលនេះជាបញ្ហាប្រឈមមួយ ក្នុងការសិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងនៅក្នុងបញ្ជីគម្រោងវិនិយោគ សាធារណៈតាមយន្តការ PPP រហូតដល់មានលទ្ធភាពចូលទៅដំណាក់កាលលទ្ធកម្ម។ ការសិក្សាសមិទ្ធិលទ្ធភាព ឬបុរេសមិទ្ធិលទ្ធភាព ជាតម្រូវការចាំបាច់ក្នុងការសម្រេចធ្វើកិច្ចលទ្ធកម្មតាមយន្តការ PPP។ ជាពិសេស ចំពោះ បញ្ហាគ្រប់គ្រងបំណុលសាធារណៈ ការសិក្សាសមិទ្ធិលទ្ធភាព អាចរំលេចនូវកាតព្វកិច្ចហិរញ្ញវត្ថុរបស់រដ្ឋ និង ហានិភ័យហិរញ្ញវត្ថុសាធារណៈផ្សេងៗ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី អង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់ កណ្តាល (អ.រ.ជ.) បាននិងកំពុងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗដូចជា Asia Pacific Project Preparation Facility (AP3F) ដើម្បីស្នើជំនួយ សម្រាប់គាំទ្រការរៀបចំសិក្សាសមិទ្ធិលទ្ធភាពគម្រោង PPP ណា ដែលមានសក្តានុពល។ មកដល់ពេលនេះ អ.រ.ជ. បានដាក់ស្នើគម្រោងចំនួន ៤ ជូន AP3F ដើម្បីពិនិត្យ និងសម្រេចផ្តល់ជំនួយសិក្សា និងរៀបចំគម្រោង។

– ចំពោះការរៀបចំមូលនិធិសម្រាប់បំពេញផលចំណេញហិរញ្ញវត្ថុ (Viability Gap Fund - VGF) គោលការណ៍ណែនាំសម្រាប់គ្រប់គ្រងមូលនិធិនេះ គឺជាផ្នែកមួយនៃសេចក្តីព្រាងនីតិវិធីប្រតិបត្តិការរួម ដែល កំពុងមានការកែសម្រួល និងត្រៀមដាក់ចេញឱ្យអនុវត្តក្រោយពីពេលច្បាប់ថ្មីស្តីពី PPP ត្រូវបានអនុម័ត។ ទោះជាយ៉ាងនេះក្តី គោលនយោបាយស្តីពីការអនុវត្តយន្តការ PPP ឆ្នាំ២០១៦ - ២០២០ មិនទាន់លើកទឹកចិត្ត ឱ្យប្រើប្រាស់មូលនិធិនេះ ឬវិធីគាំទ្ររបស់រដ្ឋផ្សេងទៀតមុនឆ្នាំ២០២០ ទេ។

គ) ការរៀបចំ និងកំណត់យន្តការស្ថាប័ន

– បានបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល ដែលសរសេរជាអក្សរកាត់ថា អ.រ.ជ. និងសរសេរជាភាសាអង់គ្លេសថា «Central Public Private Partnership Unit» ស្ថិតក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ជាសេនាធិការ និងជាទាយាទនៃគណៈកម្មាធិការអន្តរក្រសួងដឹកនាំ ការងារអនុវត្តនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ អ.រ.ជ. មានបេសកកម្មជំរុញ, សម្របសម្រួល, និងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច រយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

– បានបង្កើត និងធ្វើសមាហរណកម្មមុខងារនៃអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតាម បណ្តាក្រសួង-ស្ថាប័នមួយចំនួនតាមវិស័យ។

៣.៤. ក្របខ័ណ្ឌវិនិយោគសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ស្របតាមទិសដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី៣ និងកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងប្រសិទ្ធភាពចំណាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានបង្កើតមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (Sub-National Investment Fund - SNIF) និងក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (ក.វ.ក) តាមរយៈអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ ដោយផ្តល់ហិរញ្ញប្បទានទៅដល់គម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈយុទ្ធសាស្ត្រ និងផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការបំពេញភារកិច្ច និងការគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែប្រសើរ។ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាយន្តការសម្រាប់ផ្តល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងទម្រង់ជាការផ្ទេរថវិកាមានភ្ជាប់លក្ខខណ្ឌ ដែលមានលក្ខណៈជាការប្រកួតប្រជែងក្នុងគោលបំណងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តថវិកា និងពង្រឹងប្រសិទ្ធភាពចំណាយ។

ដើម្បីអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំឯកសារគតិយុត្តមួយចំនួន ដូចខាងក្រោម៖

– អនុម័ត និងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលស្រុក តាមរយៈសេចក្តីសម្រេចលេខ ០០៤ សសរ/ក.វ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧។ គោលការណ៍ណែនាំនេះ គឺជាមូលដ្ឋាន ដែលលេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន ក.វ.ក) ប្រើប្រាស់ដើម្បីវាយតម្លៃការបំពេញភារកិច្ចរបស់រដ្ឋបាលស្រុក និងជាឯកសាររស់ដែលអាចកែតម្រូវតាមការចាំបាច់។

– ចេញសេចក្តីណែនាំលេខ ០០១ ស.ណ.ន/ក.វ.ក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំគម្រោងវិនិយោគជូនរដ្ឋបាលស្រុក ដែលទទួលបានហិរញ្ញប្បទានពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

– ប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីនីតិវិធីហិរញ្ញវត្ថុនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានសម្រាប់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន ក.វ.ក។

៤. ការសម្រិតសម្រាំងឥណទានសម្បទាន

ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការបន្តអនុវត្តនូវគោលនយោបាយពិពិធកម្មប្រភពហិរញ្ញប្បទាន រាជរដ្ឋាភិបាលនៅតែអាចកៀរគរ និងសម្រិតសម្រាំងបាននូវឥណទានដែលមានកម្រិតសម្បទានខ្ពស់ និងហានិភ័យទាប បានទាន់ពេលវេលា និងគ្រប់គ្រាន់តាមផែនការ សម្រាប់បំពេញនូវតម្រូវការវិនិយោគសាធារណៈសរុបក្នុងវិស័យអាទិភាពរបស់ខ្លួន។

ជាក់ស្តែង ឥណទានដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀង ក្នុងឆ្នាំ២០១៥ - ២០១៨ កន្លងមក សុទ្ធសឹងជាឥណទានសម្បទានកម្រិតខ្ពស់ ដែលមានធាតុអំណោយចាប់ពី **៣៥ ភាគរយ** ឡើងទៅ ដោយមានៈអត្រាការប្រាក់ពី **សូន្យ** ទៅ **២ ភាគរយ** ក្នុងមួយឆ្នាំ, រយៈពេលខ្ចីពី **២០** ទៅ **៤០ឆ្នាំ,** និង រយៈពេលអនុគ្រោះពី **៧** ទៅ **១៥ឆ្នាំ**។ សូចនាករថ្លៃដើម និងហានិភ័យនៃឥណទានពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ មានដូចតារាងទី៤ ខាងក្រោម៖

តារាងទី៤ - សូចនាករប្លែដើម និងហានិភ័យនៃឥណទានសម្បទានឆ្នាំ២០១៥ - ២០១៨


សូចនាករ / Indicators	២០១៥	២០១៦	២០១៧	២០១៨	មធ្យមភាគ
រយៈពេលមធ្យមដល់ឥណប្រតិទាន (ឆ្នាំ) / Average Time to Maturity - "ATM" (Years)	១១	១០	១០	១០	១១
អត្រាការប្រាក់មធ្យម (ក្នុងមួយឆ្នាំ) / Weighted Average Interest Rate (p.a)	១,១%	១,១%	០,៦%	១,៣%	១.១%
ឥណប្រតិទានមធ្យម (ឆ្នាំ) / Weighted Average Maturity (Years)	២៩	២៩	៣៣	២៧	២៩
រយៈពេលអនុគ្រោះមធ្យម (ឆ្នាំ) / Weighted Average Grace Period (Years)	៩	៩	៩	៨	៩
ធាតុអំណោយមធ្យម / Weighted Average Grant Element	៤៨,៣%	៤៨,៣%	៥៥,០%	៤៣,៥%	៤៨.០%

ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥. ការអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ


ដើម្បីឆ្លើយតបទៅនឹងគោលដៅដែលបានដាក់ចេញ ក្នុងការសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម ក្នុងរង្វង់ **៧ ភាគរយ** និងកំណើនចំណូលថវិកាជាតិក្នុងរង្វង់ **០,៥ ពិន្ទុភាគរយ នៃ ផសស** ក្នុងមួយឆ្នាំ រាជរដ្ឋាភិបាលបានបន្តសកម្មអនុវត្តនូវកម្មវិធីកែទម្រង់ និងយុទ្ធសាស្ត្រគន្លឹះៗជាអាទិភាពនានា ដូចជា៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល, និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤ - ២០១៨។ ជាលទ្ធផលនៃការអនុវត្តជាក់ស្តែង ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងកំណើនចំណូលថវិកាជាតិខ្ពស់ គួរឱ្យកត់សម្គាល់ ដូចមានក្នុងក្រាហ្វទី២ និង ទី៣ ខាងក្រោម៖

ក្រាហ្វទី២៖ កំណើន ផសស ២០១៥ - ២០១៨



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រាហ្វទី៣៖ ចំណូលថវិកាជាតិ ២០១៥ - ២០១៨



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តាមក្រាហ្វទី២ និងទី៣ ខាងលើ បង្ហាញថា ជារួម ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ទាំង ២ សុទ្ធតែសម្រេចបាននូវកំណើនខ្ពស់ ទៅតាម ឬលើសពីគោលដៅកំណត់ ដោយក្នុងនោះ៖ **ផសស** សម្រេចបានកំណើនជាមធ្យមក្នុងរង្វង់ **៧ ភាគរយ** ក្នុងមួយឆ្នាំ ដូចការគ្រោងទុក និងចំណូលថវិកាជាតិ សម្រេចបានលើសការរំពឹងទុកទ្វេដង ពោលគឺ សម្រេចបានកំណើនជាមធ្យមក្នុងរង្វង់ **១ ពិន្ទុភាគរយ នៃ ផសស** ក្នុងមួយឆ្នាំ ធៀបនឹងគោលដៅ **០,៥ ពិន្ទុភាគរយ នៃ ផសស** ក្នុងមួយឆ្នាំ។ ការសម្រេចបាននូវសមិទ្ធផលដ៏ធំធេងនេះ បញ្ជាក់ថា សម្រាប់ឆ្នាំ២០១៥ - ២០១៨ សមត្ថភាពខ្ចីឥណទានសម្បទាន ជាក់ស្តែងរបស់កម្ពុជា មានកម្រិតលើសពី **៨០០ លានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ ទៅទៀត ហើយកម្ពុជាក៏អាចបង្កើនសមត្ថភាពខ្ចីឥណទានសម្បទានបានច្រើនជាងនេះថែមទៀត ចាប់ពីឆ្នាំ២០១៩ ទៅ ប្រសិនបើនៅតែអាចបន្តរក្សាកំណើននៃសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ទាំង ២ តាមនិន្នាការបែបនេះ។

៦. ការអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ

ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលបានបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍ និងយន្តការនានាពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដូចមានចែងក្នុងមាត្រា៦៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមាត្រា៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ៖ *«មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ក្រោមការប្រទានសិទ្ធិពីនាយករដ្ឋមន្ត្រី ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ការបោះផ្សាយមូលបត្ររដ្ឋ, ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ, ការវិនិយោគ, ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា, ការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស, និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ឱ្យប្រាក់គេខ្ចី, ចេញលិខិតធានា, ឬ ក៏ធ្វើទង្គើណាផ្សេងៗទៀតដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។»*

ការអនុវត្តតាមគោលការណ៍មជ្ឈការដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈនេះ បាននិងកំពុងបង្កលទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការកំណត់ការ

ប្រើប្រាស់ឥណទានសម្បទានចំគោលដៅអាទិភាព និងអាចគ្រប់គ្រងទិន្នន័យបំណុលសាធារណៈប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងភាពជឿទុកចិត្តបាន ដើម្បីជាមូលដ្ឋានក្នុងការវិភាគចីរភាពបំណុល សំដៅកំណត់សមត្ថភាពខ្ចីថ្មី និងការធានារបស់រដ្ឋសម្រាប់ឆ្នាំបន្តបន្ទាប់ ក្នុងទំហំដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន។

៧. ការកៀរគរហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានពីប្រភពផ្សេងទៀត

៧.១. ការកៀរគរហិរញ្ញប្បទានឥតសំណង

បើទោះបីជាប្រភពហិរញ្ញប្បទានឥតសំណងសម្រាប់កម្ពុជា កាន់តែរឹងសួតទៅៗ ក្នុងបរិការណ៍ដែលកម្ពុជាបានឡើងឋានៈពីប្រទេសដែលមានចំណូលទាប មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក៏ពិតមែន ក៏ប៉ុន្តែ តាមរយៈកិច្ចខិតខំប្រឹងប្រែង ក្នុងរយៈពេល ៤ឆ្នាំ (២០១៥ - ២០១៨) នេះ រាជរដ្ឋាភិបាលនៅតែអាចកៀរគរហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ បានសរុបប្រមាណ **២,៦ ប៊ីលានដុល្លារអាមេរិក** សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈក្នុងវិស័យអាទិភាពនានា រួមមានៈ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, សេដ្ឋកិច្ច, សង្គមកិច្ច, និងវិស័យអាទិភាពចំពោះមុខផ្សេងទៀត។

ក្នុងការកៀរគរហិរញ្ញប្បទានឥតសំណងនេះ រាជរដ្ឋាភិបាលបានបន្តខិតខំរក្សាភាពទន់ភ្លន់ក្នុងការប្រើប្រាស់ឥណទានសម្បទាន ធ្វើជាគ្រាប់ពូជ ឬជាធ្នាក់ ដើម្បីទាក់ទាញ និងកៀរគរហិរញ្ញប្បទានឥតសំណងសម្រាប់ហិរញ្ញប្បទានគម្រោងក្នុងវិស័យសង្គមកិច្ច ដូចជាៈ វិស័យអប់រំ, សុខាភិបាល, និងអភិវឌ្ឍន៍ជនបទ។ ជាក់ស្តែង ក្នុងទឹកប្រាក់ហិរញ្ញប្បទានឥតសំណងខាងលើ ទឹកប្រាក់ចំនួនប្រមាណ **១៥០ លានដុល្លារអាមេរិក** ត្រូវបានកៀរគរតាមរយៈការប្រើប្រាស់ឥណទានសម្បទានដែលជាគ្រាប់ពូជ (Seed Money) ចំនួនប្រមាណ **៥៦១ លានដុល្លារអាមេរិក**។

ហិរញ្ញប្បទានឥតសំណងដែលទទួលបានជាក់ស្តែង តាមវិស័យក្នុងឆ្នាំ២០១៥ - ២០១៨ មានដូចតារាងទី៥ ខាងក្រោមៈ

តារាងទី៥៖ ហិរញ្ញប្បទានឥតសំណងតាមវិស័យឆ្នាំ២០១៥ - ២០១៨

ឯកតា៖ ជាលានដុល្លារអាមេរិក

វិស័យ	២០១៥	២០១៦	២០១៧	២០១៨	សរុប (២០១៥-២០១៨)	មធ្យមភាគ (២០១៥-២០១៨)
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត	២១៥	១៩៦	១៧៧	១៨៨	៧៧៧	១៩៤
ភាគរយ	*២៨%*	*២៩%*	*២៨%*	*៣៣%*	*៣០%*	*៣០%*
- សេដ្ឋកិច្ច	១៧០	១៣០	១៤០	១៣១	៥៧១	១៤៣
ភាគរយ	*២២%*	*១៩%*	*២២%*	*២៣%*	*២២%*	*២២%*
- សង្គមកិច្ច	២៨៤	២៦០	២០៨	១១១	៨៦៣	២១៦
ភាគរយ	*៣៨%*	*៣៩%*	*៣៣%*	*១៩%*	*៣៣%*	*៣២%*
- វិស័យអាទិភាពចំពោះមុខផ្សេងទៀត	៨៧	៨៦	១០១	១៤៥	៤១៩	១០៥
ភាគរយ	*១១%*	*១៣%*	*១៦%*	*២៥%*	*១៦%*	*១៦%*
សរុប	**៧៥៥**	**៦៧២**	**៦២៧**	**៥៧៥**	**២ ៦២៩**	**៦៥៧**
បម្រែបម្រួលប្រចាំឆ្នាំ	**-៥%**	**-១១%**	**-៧%**	**-៨%**	-	**-៨%****

**ហិរញ្ញប្បទានឥតសំណងក្នុងឆ្នាំ២០១៣ មានចំនួនសរុបប្រមាណ ៨៦៤ លានដុល្លារអាមេរិក*


*** កំណើនជាមធ្យមក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៥ - ២០១៨*

ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ / ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

តាមទិន្នន័យដូចមានក្នុងតារាងទី៥ ខាងលើ បង្ហាញថា ក្នុងឆ្នាំ២០១៥ - ២០១៨ រាជរដ្ឋាភិបាលបានកៀរគរហិរញ្ញប្បទានឥតសំណងជាមធ្យមប្រមាណ **៦៦០ លានដុល្លារអាមេរិក** ក្នុងមួយឆ្នាំ ដោយក្នុងនោះ ទឹកប្រាក់ប្រមាណ **៥០ ភាគរយ** ត្រូវបានប្រើប្រាស់សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេដ្ឋកិច្ច ហើយប្រមាណ **៥០ ភាគរយ** ទៀត ក្នុងវិស័យសង្គមកិច្ច និងអាទិភាពផ្សេងទៀត។

គួរកត់សម្គាល់ថា បើគិតបញ្ចូលទាំងឥណទានសម្បទាន ក្នុងរយៈពេល ១០ឆ្នាំ កន្លងមក រាជរដ្ឋាភិបាលបានកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ សម្រាប់យកមកប្រើប្រាស់ជាក់ស្តែង ក្នុងការវិនិយោគសាធារណៈសរុបប្រមាណ **១០,១ ប៊ីលានដុល្លារអាមេរិក** (ក្នុងនោះ **៥៥ ភាគរយ** ជាហិរញ្ញប្បទានឥតសំណង និង **៤៥ ភាគរយ** ជាឥណទានសម្បទាន) ពោលគឺ ស្មើនឹងប្រមាណ **៧៣ ភាគរយ** ធៀបនឹងចំណាយវិនិយោគសាធារណៈសរុប ដែលមានប្រមាណ **១៣,៨ ប៊ីលានដុល្លារអាមេរិក**។ ការដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍ជាក់ស្តែងឆ្នាំ២០០៩ - ២០១៨ ធៀបនឹងចំណាយវិនិយោគសាធារណៈសរុប មានដូចក្រាហ្វទី៤ ខាងក្រោម៖

ក្រាហ្វទី៤ - ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ធៀបនឹងចំណាយវិនិយោគសាធារណៈសរុប ២០០៩ - ២០១៨



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៧.២. ការកៀរគរហិរញ្ញប្បទានពីវិស័យឯកជន តាមយន្តការ PPP

ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលបានរួមចំណែកកៀរគរធនធានហិរញ្ញប្បទានពីវិស័យឯកជនមកវិនិយោគសាធារណៈតាមយន្តការ PPP សរុបបានចំនួន **៧ គម្រោង** ដែលមានទឹកប្រាក់សរុបប្រមាណ **៣,៧ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ៖ វិស័យថាមពល ចំនួន **៦ គម្រោង** ស្មើនឹងទឹកប្រាក់ប្រមាណ **២ ប៊ីលានដុល្លារអាមេរិក** និង វិស័យដឹកជញ្ជូន ចំនួន **១ គម្រោង** ស្មើនឹងទឹកប្រាក់ប្រមាណ **១,៧ ប៊ីលានដុល្លារអាមេរិក**។ បើគិតជាមធ្យម ក្នុងមួយឆ្នាំ រាជរដ្ឋាភិបាល កៀរគរធនធានហិរញ្ញប្បទានពីវិស័យឯកជនបានប្រមាណ **១ ប៊ីលានដុល្លារអាមេរិក** មកបំពេញតម្រូវការវិនិយោគសាធារណៈសរុប។

តារាងទី ៦- គម្រោងវិនិយោគសាធារណៈតាមយន្តការ PPP

ឯកតា៖ ជាលានដុល្លារអាមេរិក

វិស័យ	២០១៥	២០១៦	២០១៧	២០១៨	សរុប (២០១៥-២០១៨)	មធ្យមភាគ (២០១៥-២០១៨)
ក-ថាមពល						
- ចំនួនគម្រោង	*គ្មាន*	*១*	*៣*	*២*	*៦*	*២*
- ទំហំគម្រោង		*២២,៧*	*៥៩៧,៧*	*១ ៣៤៨,៧*	*១ ៩៦៩,២*	*៦៥៦,៣*
ខ-ដឹកជញ្ជូន						
- ចំនួនគម្រោង	*គ្មាន*	*គ្មាន*	*គ្មាន*	*១*	*១*	*១*
- ទំហំគម្រោង				*១ ៧០០*	*១ ៧០០*	*១ ៧០០*
សរុប (ក+ខ)						
ចំនួនគម្រោង	*គ្មាន*	*១*	*៣*	*៣*	*៧*	*៣*
ទំហំគម្រោង		*២២,៧*	*៥៩៧,៧*	*៣ ០៤៨,៧*	*៣ ៦៦៨,២*	*៩១៧,១*

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៧.៣. ការអភិវឌ្ឍទីផ្សារមូលបត្រ

រហូតមកទល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលពុំទាន់សម្រេចធ្វើការបោះផ្សាយមូលបត្ររដ្ឋ (ដែលអាចជួញដូរបាន) ឬសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យនៅឡើយទេ ដោយហេតុថា កម្ពុជានៅតែអាចមានលទ្ធភាពក្នុងការកៀរគរហិរញ្ញប្បទានឥតសំណងមួយចំនួន និងឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់ពីដៃគូអភិវឌ្ឍន៍។

ក្នុងបរិការណ៍នៃសេដ្ឋកិច្ចកាន់តែរីកចម្រើនលូតលាស់ជាលំដាប់ រាជរដ្ឋាភិបាលយល់ថា ជាកាលានុវត្តភាពដ៏ប្រសើរ សម្រាប់កម្ពុជាក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានកាន់តែទូលំទូលាយជាងមុន ដើម្បីបំពេញតម្រូវការវិនិយោគសាធារណៈសរុប ក្នុងនោះ ទីផ្សារមូលបត្រទាំងក្នុងប្រទេស និងក្រៅប្រទេស គឺជាប្រភពទុនដ៏សំខាន់។

តាមរយៈនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បាននិងកំពុងត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការអភិវឌ្ឍទីផ្សារមូលបត្រក្នុងប្រទេស ដោយបានបន្តខិតខំអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ព្រមទាំងបានបង្កើតក្រុមការងារបច្ចេកទេសមួយ ដើម្បីសិក្សា និងត្រួតពិនិត្យឡើងវិញលើបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ទន្ទឹមនេះ ក៏មានការគិតគូរក្នុងការសិក្សាអំពីលទ្ធភាពបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ដើម្បីកៀរគរទុនវិនិយោគពីទីផ្សារមូលបត្រក្រៅប្រទេស ផងដែរ។

៨. ការគ្រប់គ្រង និងតាមដានហានិភ័យបំណុល

ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលបានបន្តពង្រឹងការតាមដាន និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើហានិភ័យបំណុលពាក់ព័ន្ធ ស្របតាមវិធានការជាយុទ្ធសាស្ត្រដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ និងវិធានការលម្អិតក្នុងគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ដោយជាលទ្ធផលរួម ពុំមានហានិភ័យបំណុលពាក់ព័ន្ធធំដុំកើតឡើងដែលធ្វើឱ្យប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈរបស់កម្ពុជាទេ។ វឌ្ឍនភាពនៃការគ្រប់គ្រង និងតាមដានហានិភ័យបំណុលនីមួយៗ មានដូចខាងក្រោម៖

៨.១. ហានិភ័យហិរញ្ញប្បទាននៃគម្រោង ឬ ហានិភ័យបុនហិរញ្ញប្បទាន (Project Funding Risk)

តាមរយៈការបន្តប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍គ្រឹះសំខាន់ៗចំនួន ៤ ក្នុងការគ្រប់គ្រងគម្រោង គឺ៖ ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ស្របតាមនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ព្រមទាំងគោលនយោបាយ, គោលការណ៍ណែនាំ, និងនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍ ព្រមទាំងតាមរយៈការបន្តពង្រឹងយន្តការកិច្ចសន្ទនាក្នុងកម្រិតគោលនយោបាយ និងទំនាក់ទំនងល្អជាប្រពៃណីជាមួយដៃគូអភិវឌ្ឍន៍ ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ពុំមានហានិភ័យនេះកើតឡើងទេ។

៨.២. ហានិភ័យទីផ្សារ (Market Risk)


– ហានិភ័យរូបិយប័ណ្ណ (Currency Risk)

ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងកិច្ចសហការគ្នា តាមរយៈការចែករំលែកព័ត៌មានគ្នាទៅវិញទៅមកជាប្រចាំ ក្នុងការតាមដានលើបម្រែបម្រួលសមាសភាគរូបិយប័ណ្ណបំណុល ជាពិសេស រូបិយប័ណ្ណដែលមានចំណែកធំនៅក្នុងចង្កោមបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា និងដែលមានអត្រាប្តូរប្រាក់ប្រែប្រួលខ្លាំង សំដៅរក្សាទុកនូវទុនបម្រុងជារូបិយប័ណ្ណបំណុលដែលត្រូវទូទាត់ជូនដៃគូអភិវឌ្ឍន៍ ស្របតាមទំហំនិងកម្មវិធីទូទាត់សេវាបំណុល និងរៀបចំយន្តការបង្ការ

ឬបញ្ចៀសការខាតបង់តម្លៃហិរញ្ញវត្ថុ (Hedging Mechanism) នៃបំណុលសាធារណៈ។

ជាលទ្ធផល ហានិភ័យរូបិយប័ណ្ណនៅក្នុងចង្កោមបំណុលសាធារណៈក្រៅប្រទេស ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ដែលស្តែងចេញតាមរយៈការប្រែប្រួលជាវិជ្ជមាននៃសមាសភាគរូបិយប័ណ្ណបំណុលធំៗ ចំនួន ៣ គឺ៖ អេសដេអ៊ែរ, យ័នចិន, និងដុល្លារអាមេរិក ក្នុងនោះ សមាសភាគរូបិយប័ណ្ណអេសដេអ៊ែរ និងយ័នចិន ដែលជារូបិយប័ណ្ណបំណុលមានហានិភ័យកម្រិតមធ្យម និងបង្ហូរមានការថយចុះ ខណៈដែលសមាសភាគរូបិយប័ណ្ណដុល្លារអាមេរិក ដែលជារូបិយប័ណ្ណបំណុលមានហានិភ័យកម្រិតតិចតួចបំផុត មានការកើនឡើង ធៀបនឹងសមាសភាគរូបិយប័ណ្ណបំណុលនៅដំណាច់ឆ្នាំ២០១៤ ដូចមានលម្អិតក្នុងក្រាហ្វទី៥ ខាងក្រោម៖

ក្រាហ្វទី៥ - ប្រៀបធៀបសមាសភាគរូបិយប័ណ្ណបំណុលសាធារណៈក្រៅប្រទេស រវាងចុងឆ្នាំ២០១៤ និងចុងឆ្នាំ២០១៨



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តាមក្រាហ្វទី៥ ខាងលើ បង្ហាញថា រូបិយប័ណ្ណបំណុលជាអេសដេអ៊ែរ បានថយចុះប្រមាណ **៤ ភាគរយ** គឺពីប្រមាណ **៣១ ភាគរយ** នៅត្រឹមដំណាច់ឆ្នាំ២០១៤ មកប្រមាណ **២៧ ភាគរយ** នៅត្រឹមដំណាច់ឆ្នាំ២០១៨ ខណៈដែលរូបិយប័ណ្ណបំណុលជាយ័នចិន បានថយចុះប្រមាណ **២ ភាគរយ** គឺពីប្រមាណ **១៧ ភាគរយ** មកប្រមាណ **១៥ ភាគរយ** នៅក្នុងរយៈពេលដូចគ្នានេះ។ ទន្ទឹមនឹងការថយចុះនៃរូបិយប័ណ្ណបំណុលជាអេសដេអ៊ែរ និងយ័នចិន រូបិយប័ណ្ណដុល្លារអាមេរិក បានកើនប្រមាណ **៣ ភាគរយ** គឺពីប្រមាណ **៤១ ភាគរយ** នៅត្រឹមដំណាច់ឆ្នាំ២០១៤ មកដល់ប្រមាណ **៤៤ ភាគរយ** នៅត្រឹមដំណាច់ឆ្នាំ២០១៨ ខណៈដែលរូបិយប័ណ្ណបំណុលជាយេនជប៉ុន និងអឺរ៉ូ មានការកើនឡើងក្នុងរង្វង់ **២ ភាគរយ**។ ទោះជាយ៉ាងនេះក្តី គិតត្រឹមដំណាច់ឆ្នាំ២០១៨ រូបិយប័ណ្ណបំណុលជាយេនជប៉ុន មានចំនួនតែប្រមាណ **៥ ភាគរយ** និងជាអឺរ៉ូ មានចំនួនតែប្រមាណ **៣ ភាគរយ** ប៉ុណ្ណោះ។ ចំណែកឯសមាសភាពរូបិយប័ណ្ណបំណុលជាវ៉ុនកូរ៉េ និងជាបាតថៃ ស្ថិតក្នុងកម្រិតដដែល គឺ **៥ ភាគរយ** ក្នុងរង្វង់ **១ ភាគរយ** តាមលំដាប់ក្នុងរយៈពេលដូចគ្នានេះ។

ទន្ទឹមនេះ ដើម្បីបង្ការ/បញ្ចៀស នូវហានិភ័យរូបិយប័ណ្ណ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់ឥណទានបន្តជូនឥណទាយិក ជារូបិយប័ណ្ណនៃឥណទានដើមដែលរដ្ឋខ្ចីពីដៃគូអភិវឌ្ឍន៍ ហើយឥណទាយិក

ដែលទទួលបានឥណទានបន្តពីរដ្ឋ ក៏បានទូទាត់សេវាបំណុលជូនរដ្ឋតាមអត្រាប្តូរប្រាក់ដែលរដ្ឋទូទាត់ជូនដៃគូអភិវឌ្ឍន៍ដែរ។

– ហានិភ័យអត្រាការប្រាក់ (Interest Rate Risk)

រាជរដ្ឋាភិបាលយល់ច្បាស់អំពីផលប៉ះពាល់នៃហានិភ័យនេះ មកលើចង្កោមបំណុលសាធារណៈកម្ពុជា ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលតែងមានភាពប្រយ័ត្នប្រយែងខ្ពស់ ដោយធ្វើការវិភាគគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសម្រេចចិត្តទទួលយកលក្ខខណ្ឌឥណទានពីដៃគូអភិវឌ្ឍន៍ណាមួយ ជាពិសេស គឺលក្ខខណ្ឌអត្រាការប្រាក់។

ជាក់ស្តែង ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ឥណទានដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងភាគច្រើនលើសលុបជាឥណទានដែលមានអត្រាការប្រាក់ថេរ (Fixed Rate)។ ដោយឡែកចំពោះ ឥណទានពីដៃគូអភិវឌ្ឍន៍មួយចំនួន ដែលជាប្រភេទឥណទានមានអត្រាការប្រាក់ប្រែប្រួល ក៏ត្រូវបានចាត់វិធានការបញ្ចៀសហានិភ័យរួចហើយ តាមរយៈ៖ ១) ការកំណត់អត្រាការប្រាក់អតិបរមា (Interest Rate Cap) ឱ្យស្ថិតក្នុងកម្រិតមួយដែលមានជាតុអំណោយខ្ពស់អាចទទួលយកបាន, ២) ការបំប្លែងឱ្យទៅជាអត្រាការប្រាក់ថេរ នៅថ្ងៃដកសាច់ប្រាក់, និង ៣) វិធានការពាក់ព័ន្ធមួយចំនួនទៀត។ ដូច្នេះ មានន័យថា ក្នុងចង្កោមបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន ពុំមានហានិភ័យអត្រាការប្រាក់ទេ។

គួរកត់សម្គាល់ថា វិធានការខាងលើនេះត្រូវបានទទួលស្គាល់ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗមួយចំនួនថា ជាវិធានការដ៏ប្រសើរមួយ ដែលបណ្តាប្រទេសជាឥណទាយិកទាំងឡាយអាចយកទៅធ្វើជាគំរូ ក្នុងការរក្សាកម្រិតសម្បទាននៃឥណទាន និងបញ្ចៀសហានិភ័យអត្រាការប្រាក់។

៨.៣. ហានិភ័យឥណទាន (Credit Risk)

ជាការអនុវត្តកន្លងមក ដើម្បីជាការជួយស្រោចស្រង់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈមួយចំនួនពីភាពក្សីយធន ព្រមទាំងជាការអនុវត្តវិធានការជាយុទ្ធសាស្ត្រជួយសម្រាលបន្ទុកជីវភាពប្រជាពលរដ្ឋ និងកាត់បន្ថយថ្លៃដើមនៃការប្រកបធុរកិច្ចនៅកម្ពុជា ក៏ដូចជាពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ការអនុគ្រោះដល់សហគ្រាសសាធារណៈក្នុងវិស័យអាទិភាពសំខាន់ៗមួយចំនួន រួមមាន៖ អគ្គិសនី, ផ្គត់ផ្គង់ទឹកស្អាត, ឡូជីស្ទីក, ទូរគមនាគមន៍, និងជំរុញស្រូវអង្គរ តាមរយៈការអនុញ្ញាតឱ្យពន្យារពេលទូទាត់សេវាបំណុលជូនរដ្ឋ និងបន្ទូរបន្ថយអត្រាការប្រាក់ នៃឥណទានដែលបានផ្តល់ជូនសហគ្រាសសាធារណៈទាំងនោះខ្ចី ក្នុងក្របខ័ណ្ឌនៃការឱ្យខ្ចីដោយប្រើប្រាស់ថវិការដ្ឋ និងការឱ្យខ្ចីបន្តក្រោមហិរញ្ញប្បទានពីដៃគូ។


ការអនុវត្តនូវវិធានការផ្តល់ភាពអនុគ្រោះបែបនេះ បានបណ្តាលឱ្យចំណូលសេវាបំណុលរបស់រដ្ឋ ក្នុងក្របខ័ណ្ឌនៃការឱ្យខ្ចីដោយប្រើប្រាស់ថវិការដ្ឋ និងការឱ្យខ្ចីបន្តពីឥណទានសម្បទានរបស់ដៃគូ មានការធ្លាក់ចុះទាបជាងផែនការដែលបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ។

៨.៤. ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk)

សម្រាប់ឥណទានសម្បទានដែលបានចុះកិច្ចព្រមព្រៀងក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តខិតខំចរចាជាមួយដៃគូអភិវឌ្ឍន៍ ដោយបានស្នើរៀបចំកម្មវិធីទូទាត់សេវាបំណុលសម្រាប់ការខ្ចីថ្មី មិនឱ្យស្ថិតក្នុងខែណាដែលមានទំហំសេវាបំណុលច្រើនរួចហើយ ដូចជា៖ ខែកុម្ភៈ, មីនា, សីហា, និងកញ្ញា ដើម្បីឱ្យទំហំសេវាបំណុលជាមធ្យមប្រចាំខែស្ថិតក្នុងរង្វង់ប្រមាណ **៨ ភាគរយ** ដែលជាកម្រិតឧត្តមានុពល (Optimum Level)។


តាមរយៈកិច្ចខិតខំទាំងនេះ បានធ្វើឱ្យកម្មវិធីទូទាត់សេវាបំណុលបច្ចុប្បន្នមានភាពប្រសើរឡើង បើធៀបនឹងស្ថានភាពមុនពេលអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដូចមានក្នុងក្រាហ្វទី៦ និងទី៧ ខាងក្រោម៖

ក្រាហ្វទី៦៖ កម្មវិធីទូទាត់សេវាបំណុលមុន និងក្រោយការអនុវត្តយុទ្ធសាស្ត្រ



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រាហ្វទី៧៖ ព្យាករណ៍កម្មវិធីទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៩ - ២០២៣



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តពង្រឹងការកត់ត្រា និងផ្ទៀតផ្ទាត់ទិន្នន័យបំណុលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីបង្កើនសុក្រឹត្យភាព ក្នុងការព្យាករសេវាបំណុល ព្រមទាំងបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុងរវាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អង្គភាពគ្រប់គ្រងបំណុលសាធារណៈ) និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងក្របខ័ណ្ឌនៃការទូទាត់សេវាបំណុលផងដែរ ដោយអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល តែងបានផ្តល់របាយការណ៍ស្តីពីការព្យាករការទូទាត់សេវាបំណុលប្រចាំសប្តាហ៍ជូនអគ្គនាយកដ្ឋានរតនាគារជាតិ និងធ្វើបច្ចុប្បន្នកម្មជាប់ជាប្រចាំ សំដៅរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងសាច់ប្រាក់។

តាមរយៈកិច្ចសហប្រតិបត្តិការល្អប្រសើររវាងអង្គភាពទាំងពីរនេះ ក្នុងឆ្នាំ២០១៥ - ២០១៨ កន្លងទៅ រាល់ប្រតិបត្តិការទូទាត់សេវាបំណុលទាំងអស់បានប្រព្រឹត្តិទៅដោយរលូន និងពុំមានបញ្ហារាំងស្ទះ ឬហានិភ័យកើតឡើងទេ។

៨.៥. ហានិភ័យប្រតិបត្តិការ (Operational Risk)

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការលម្អិតនានា ដែលបានដាក់ចេញនៅក្នុងគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ដោយសម្រេចបាននូវសមិទ្ធផល និងវឌ្ឍនភាព ដូចខាងក្រោម៖

- បានអនុម័ត និងដាក់ឱ្យអនុវត្តនីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈប្រកាសលេខ ៥៤៦ សហវ-ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨។
- បានអនុម័ត និងដាក់ឱ្យអនុវត្តឯកសារណែនាំលម្អិតស្តីពី ១) ដំណើរការធ្វើអត្តសញ្ញាណកម្ម រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ២) កិច្ចដំណើរការលទ្ធកម្ម, និង ៣) កិច្ចដំណើរការពិនិត្យសំណើសុំថវិកា ក្រោមក្របខ័ណ្ឌកម្មវិធី/គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ តាមរយៈប្រកាសលេខ៧២៤ សហវ-ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨។
- បានអនុម័ត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យរួម សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ដែលជាឧបករណ៍ជំនួយដ៏សំខាន់សម្រាប់សម្រួលដល់ប្រតិបត្តិការការងារប្រចាំថ្ងៃ និងការងារវិភាគផ្សេងៗ តាមរយៈប្រកាសលេខ ១៦២០ សហវ-ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។
- បានបន្តជំរុញ និងចរចាជាមួយបណ្តាដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីផ្សេងទៀត ឱ្យចូលរួមអនុវត្តប្រព័ន្ធរបស់ប្រទេស ក្រោមក្របខ័ណ្ឌនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោង។
- បានបន្តពង្រឹងសមត្ថភាពធនធានមនុស្សទាំងគុណភាព ទាំងបរិមាណ ឱ្យស្របទៅនឹងតម្រូវការនៃការងារ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធ និងការជ្រើសរើសមន្ត្រីថ្មី។
- បានរៀបចំសេចក្តីព្រាងនីតិវិធីរួមបច្ចុប្បន្នកម្មលើកទី២ សម្រាប់ការគ្រប់គ្រង និងអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ រួមមាន៖ i) នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងរដ្ឋបាលគម្រោង, ii) នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង, និង iii) នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងកិច្ចលទ្ធកម្មគម្រោង ដោយបានដាក់ឆ្លងកិច្ចពិគ្រោះយោបល់ជាមួយគ្រប់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ជាច្រើនលើករួចមកហើយ។
- និងសម្រេចបាននូវសមិទ្ធផលពាក់ព័ន្ធបន្ទាប់បន្សំជាច្រើនផ្សេងទៀត។

ជារួម ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ពុំមានហានិភ័យប្រតិបត្តិការធំដុំកើតឡើងទេ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលនឹងបន្តខិតខំកែលម្អបន្ថែមទៀត ដើម្បីឱ្យការគ្រប់គ្រងហានិភ័យប្រតិបត្តិការ កាន់តែមានភាពគ្រប់ជ្រុងជ្រោយ ស្របតាមគោលការណ៍ណែនាំជាអន្តរជាតិ។

៨.៦. ហានិភ័យថវិកា (Fiscal Risk)

ផ្អែកតាមគោលការណ៍ប្រយ័ត្នប្រយែងក្នុងការវិភាគចីរភាពបំណុលសម្រាប់ឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីថ្មីបន្ថែម ក្នុងរង្វង់ **៧០០ លាន** ទៅ **៨០០ លានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៦ - ២០១៨ ក្នុងលក្ខខណ្ឌដែល៖ ១) ឥណទានទាំងអស់ត្រូវមានកម្រិតសម្បទានខ្ពស់ ដោយមានធាតុអំណោយ ចាប់ពី **៣៥ ភាគរយ** ឡើងទៅ, ២) កំណើនផសស សម្រេចបានជាមធ្យមក្នុងរង្វង់ **៧ ភាគរយ**,

៣) ការនាំចេញ សម្រេចបានកំណើនជាមធ្យមក្នុងរង្វង់ **១០ ភាគរយ** ក្នុងមួយឆ្នាំ, និង ៤) ចំណូលថវិកាជាតិ សម្រេចបានកំណើនក្នុងរង្វង់ **០,៥ ពិន្ទុភាគរយ នៃ ផសស** ក្នុងមួយឆ្នាំ។

ជាការអនុវត្តជាក់ស្តែង ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ រាជរដ្ឋាភិបាលសម្រិតសម្រាំងបាននូវឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដោយមានធាតុអំណោយខ្ពស់ចាប់ពី **៣៥ ភាគរយ** ឡើងទៅ។ ទន្ទឹមនេះ សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗទាំង ៣ សុទ្ធតែសម្រេចបាននូវកំណើនខ្ពស់ ទៅតាម ឬលើសពីគោលដៅកំណត់ និងស្របទៅតាមការព្យាករនៅចុងឆ្នាំ២០១៤។ ការសម្រេចបានសមិទ្ធផលដ៏គាប់ប្រសើរទាំងនេះ មានន័យថា សម្រាប់ឆ្នាំ២០១៥ - ២០១៨ កម្ពុជាមិនត្រឹមតែអាចមានសមត្ថភាពខ្ចីឥណទានសម្បទានក្នុងរង្វង់ ៧០០ លាន ទៅ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ ប៉ុណ្ណោះទេ តែជាសមត្ថភាពពិតប្រាកដ ដោយផ្អែកលើលទ្ធផលនៃការវិភាគចីរភាពបំណុល តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ កម្ពុជាអាចខ្ចីឥណទានសម្បទានបានច្រើនជាងនេះក្នុងកម្រិតទ្វេដង។ ដូច្នេះ ការបង្កើនពិជានៃការខ្ចីបន្ថែមសម្រាប់ឆ្នាំ២០១៨ រហូតដល់ជាង ១,៥ ប៊ីលានអេសដេអ៊ែរ ពុំធ្វើឱ្យប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈកម្ពុជា នោះទេ។

៨.៧. កាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities)

៨.៧.១. វិស័យធនាគារ និងហិរញ្ញវត្ថុ (Banking and Financial Sector)

ក្នុងគោលបំណងបង្ការ/បញ្ចៀស នូវហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ សំដៅបន្តពង្រឹងភាពគ្រប់គ្រាន់នៃដើមទុន, សន្ទនីយភាព, និងគុណភាពទ្រព្យសកម្ម រាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ជាសេនាធិការ បាន៖

- កំពុងបន្តអនុវត្តគោលនយោបាយមិនផ្តល់ការធានាលើហានិភ័យក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ, ការរក្សាបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច។
- អនុម័ត និងដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព និងប្រកាសស្តីពីក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
- អនុម័ត និងដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមា។
- អនុម័ត និងដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុន។
- អនុម័ត និងដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិន។
- អនុម័ត និងដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីសវនកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- លើកកម្ពស់សមត្ថភាព, ភាពធន់, និងភាពរឹងមាំ នៃវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងជាប្រចាំ។
- រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា ក្នុងគោលបំណងបង្កើតយន្តការគ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុ ដើម្បីទប់ស្កាត់ និងគ្រប់គ្រងវិបត្តិហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព សំដៅធានាបាននូវស្ថិរភាព និងចីរភាពនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

ជារួម ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ពុំមានកាតព្វកិច្ចបំណុលជាយថាហេតុក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុទេ ពោលគឺ ពុំមានវិបត្តិវិស័យហិរញ្ញវត្ថុដែលធ្វើឱ្យប៉ះពាល់ដល់បំណុលសាធារណៈទេ។ ទន្ទឹមនេះ

អនុបាតសោធនភាពនៃគ្រឹះស្ថានធនាគារមានកម្រិតជាមធ្យមប្រមាណ ២៥ ភាគរយ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **២១ ភាគរយ** (កម្រិតអប្បបរមា **១៥ ភាគរយ**)។ ចំណែកឯអនុបាតសន្ទនីយភាពមានកម្រិតជាមធ្យមប្រមាណ **១៦០ ភាគរយ** សម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និង **១៥៨ ភាគរយ** សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (កម្រិតអប្បបរមា **៣០ ភាគរយ**)។ ជាមួយគ្នានេះ ឥណទានមិនដំណើរការមានកម្រិតទាបប្រមាណ **២,៩ ភាគរយ** សម្រាប់គ្រឹះស្ថានធនាគារ និង **៥ ភាគរយ** សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ទាំងនេះ គឺជាសូចនាករគន្លឹះមួយចំនួន ដែលបង្ហាញអំពីភាពរឹងមាំនៃវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

លើសពីនេះ រាជរដ្ឋាភិបាលបានបន្តជំរុញការកសាងសមត្ថភាពជាប្រចាំទៅលើការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបានយកចិត្តទុកដាក់និងវាយតម្លៃជាប្រចាំទៅលើហានិភ័យមួយចំនួនដូចជា៖ ១) ស្ថានភាពកំណើនឥណទាន, ២) ភាពប្រទាក់ក្រឡារវាងវិស័យអចលនទ្រព្យនិងវិស័យធនាគារ, ៣) ការពឹងផ្អែកលើកម្ចីមូលនិធិបរទេស, និង ៤) ស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៨.៧.២. ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលគ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

តាមរយៈការបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍មជ្ឈការ នៃការគ្រប់គ្រងបំណុលសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ, អនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ, និងបទដ្ឋានគតិយុត្តជាធរមាន ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ពុំមានហានិភ័យនេះកើតឡើងទេ ពោលគឺ *«មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ក្រោមការប្រទានសិទ្ធិពីនាយករដ្ឋមន្ត្រី ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ការបោះផ្សាយមូលបត្ររដ្ឋ, ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ, ការវិនិយោគ, ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា, ការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស, និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ឱ្យប្រាក់គេខ្ចី, ចេញលិខិតធានា, ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។»*

៨.៧.៣. ការធានារបស់រដ្ឋ (Guarantee)

ជារួម ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ពុំមានហានិភ័យដែលកើតចេញពីការធានារបស់រដ្ឋនោះទេ ព្រោះថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ ដោយបាន៖

- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សា និងវិភាគស៊ីជម្រៅលើលទ្ធភាពនៃការកើតមានបន្ទុកកាតព្វកិច្ចបំណុលជាយថាហេតុ មុននឹងសម្រេចផ្តល់ការធានាទូទាត់លើគម្រោងថ្មីណាមួយ។
- បន្តសហការគ្នាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការតាមដានជាប់ជាប្រចាំលើសកម្មភាពអាជីវកម្ម និងស្ថានភាពហិរញ្ញវត្ថុរបស់អគ្គិសនីកម្ពុជា ដែលជាលទ្ធផលបង្ហាញថា ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ អគ្គិសនីកម្ពុជាមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងបានទូទាត់ថ្លៃអគ្គិសនី និងថ្លៃឈ្នួល

ខ្សែបញ្ជូនអគ្គិសនី ជូនក្រុមហ៊ុនឯកជនបានទាន់ពេលវេលា និងគ្រប់ចំនួន។

- បង្កើតមូលនិធិបម្រុង នៅដើមឆ្នាំ២០១៦ ដើម្បីត្រៀមដោះស្រាយការធានាទូទាត់របស់រដ្ឋ នៅពេលដែលមានកាតព្វកិច្ចបំណុលជាយថាហេតុកើតឡើង ដោយបានវិភាជន៍ថវិកាចូលមូលនិធិនេះក្នុងមួយឆ្នាំ រង្វង់ **៥ ភាគរយ** នៃសេវាបំណុលសរុបប្រចាំឆ្នាំ។

៩. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស

រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធទាំងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈ និងទាំងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយសម្រេចបាននូវវឌ្ឍនភាពសំខាន់ៗ ដូចខាងក្រោម៖

៩.១. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន

–មានការកែសម្រួលរចនាសម្ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបានដំឡើងអង្គភាពគ្រប់គ្រងបំណុលសាធារណៈពីកម្រិតនាយកដ្ឋាន ទៅកម្រិតអគ្គនាយកដ្ឋាន និងបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល។

–ទន្ទឹមនេះ រចនាសម្ព័ន្ធនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏បាននិងកំពុងត្រូវបានកែសម្រួលជាបណ្តើរៗ ដើម្បីឆ្លើយតបនឹងគោលបំណង និងគោលដៅនៃការគ្រប់គ្រងបំណុលសាធារណៈ។

–មានការជ្រើសរើសមន្ត្រីថ្មី ដែលមានសមត្ថភាពជំនាញ និងឆន្ទៈវិជ្ជាជីវៈខ្ពស់បន្ថែមទាំងក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទាំងក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នពាក់ព័ន្ធ។

៩.២. ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស

–តាមរយៈការអនុវត្តតាមវិធានការ ដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ធនធានមនុស្សពាក់ព័ន្ធនឹងការងារគ្រប់គ្រងបំណុលសាធារណៈ និងការងារគ្រប់គ្រងវិនិយោគសាធារណៈ ក្នុងក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភាពរីកចម្រើនជាលំដាប់ ដែលអាចធ្វើកិច្ចការសំខាន់ៗដោយខ្លួនឯងបាន ដូចជា៖ ១) ការកសាងបទដ្ឋានគតិយុត្ត; ២) ការរៀបចំឯកសារគោលនយោបាយ, យុទ្ធសាស្ត្រ, នីតិវិធី, និងទស្សនាទាន; ៣) ការផលិតរបាយការណ៍និងព្រឹត្តិបត្រស្ថិតិបំណុល; ៤) ការវិភាគចីរភាពបំណុល, ចង្កោមបំណុល, ធាតុអំណោយ, ហានិភ័យបំណុលពាក់ព័ន្ធ ដោយរួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ; និង ៥) កិច្ចការពាក់ព័ន្ធសំខាន់ជាច្រើនផ្សេងទៀត។

–ទន្ទឹមនេះ ធនធានមនុស្សនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរតាមរយៈការចូលរួមសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, វេទិកា, សន្និសីទនានា ទាំងក្នុង និងក្រៅប្រទេស។

១០. វឌ្ឍនភាពការងារពាក់ព័ន្ធផ្សេងទៀត


ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានតាមវិធានការជាយុទ្ធសាស្ត្រគន្លឹះទាំង ៩ចំណុច ខាងលើ រាជរដ្ឋាភិបាលក៏សម្រេចបាននូវវឌ្ឍនភាពលើកិច្ចការសំខាន់ៗផ្សេងទៀត ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈផងដែរ ដែលរួមមានដូចខាងក្រោម៖

១០.១. អតិរេកចរន្តសម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់

បើទោះជារាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តគោលនយោបាយ ជាអាទិភាពសំខាន់ចំនួន ២ គឺ៖ ១) គោលនយោបាយដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ឱ្យបានជាង ១ លានរៀល ក្នុងមួយខែ នៅឆ្នាំ២០១៨ និង ២) គោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥ ក្តី ក៏ប៉ុន្តែ

តាមរយៈការបន្តពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤ - ២០១៨ ប្រកបដោយប្រសិទ្ធភាព និងការធ្វើវិចារណកម្មចំណាយ រាជរដ្ឋាភិបាលនៅតែអាចសម្រេចបាននូវអតិរេកចរន្ត សម្រាប់យកមកហិរញ្ញប្បទានគម្រោងវិនិយោគផ្ទាល់។ ជាក់ស្តែង សម្រាប់ឆ្នាំ២០១៥ - ២០១៨ រាជរដ្ឋាភិបាលសម្រេចបាននូវអតិរេកចរន្តសរុបចំនួន **១៧ ១៨៧ ប៊ីលានរៀល** សមមូលនឹងប្រមាណ **៤ ប៊ីលានដុល្លារអាមេរិក** ដោយក្នុងនោះ ទឹកប្រាក់ចំនួន **៧ ១០៤ ប៊ីលានរៀល** សមមូលនឹងប្រមាណ **១,៧ ប៊ីលានដុល្លារអាមេរិក** ត្រូវបានប្រើប្រាស់សម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់។ តួលេខលម្អិត មានដូចក្នុងក្រាហ្វទី៨ ខាងក្រោម៖

ក្រាហ្វទី៨ - ចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិធៀបនឹងអតិរេកចរន្ត ២០១៥-២០១៨



	2015	2016	2017	2018e	សរុប	មធ្យម
អតិរេកចរន្ត	3,689	3,748	4,022	5,728	17,187	4,297
ចំណាយវិនិយោគសាធារណៈដោយប្រើប្រាស់ថវិកាជាតិ	1,401	1,470	1,934	2,299	7,104	1,776

សម្គាល់៖ ឆ្នាំ២០១៨ ជាតួលេខប៉ាន់ស្មាន
ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តាមទិន្នន័យនៅក្នុងក្រាហ្វទី៨ ខាងលើ បង្ហាញថា ក្នុងរយៈពេល ៤ឆ្នាំនេះ រាជរដ្ឋាភិបាលសម្រេចបាននូវអតិរេកចរន្តជាមធ្យមប្រមាណ **៤ ២៩៧ ប៊ីលានរៀល** ក្នុងមួយឆ្នាំ សមមូលនឹងប្រមាណ **១ ប៊ីលានដុល្លារអាមេរិក** ក្នុងមួយឆ្នាំ ក្នុងនោះ ប្រមាណ **១ ៧៧៦ ប៊ីលានរៀល** សមមូលនឹងប្រមាណ **៤៣៩ លានដុល្លារអាមេរិក** ពោលគឺ ប្រមាណ **៤១ ភាគរយ** ត្រូវបានប្រើប្រាស់សម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់។

១០.២. ការដោះស្រាយបំណុលមរតក

រាជរដ្ឋាភិបាលបានបន្តខិតខំប្រឹងប្រែងក្នុងការចរចាដោះស្រាយបំណុលមរតកជាមួយដៃគូ ដោយសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងនោះ៖ ជាមួយដៃគូមួយ មានការយោគយល់គ្នាច្រើន ដោយបានឯកភាពគ្នាលើលក្ខខណ្ឌមួយចំនួនរួចហើយ ដោយឡែកចំពោះលក្ខខណ្ឌដែលនៅសេសសល់ ក៏សង្ឃឹមថា អាចនឹងស្វែងរកដំណោះស្រាយរួមមួយ ដែលភាគីទាំងសងខាងអាចទទួលយកបាន ក្នុងពេលឆាប់ៗ ផងដែរ។ ចំពោះដៃគូមួយទៀត បើទោះជាមិនទាន់មានវឌ្ឍនភាពជាដុំកំភួនក្តី ក៏រាជរដ្ឋាភិបាលនៅតែបន្តឆន្ទៈក្នុងការដោះស្រាយឱ្យបានជ្រះស្រឡះ ដើម្បីរក្សាទំនាក់ទំនងជាប្រពៃណីដ៏ល្អប្រសើរ និងបើកផ្លូវឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅបន្ថែមទៀត។ ជារួម ការដោះស្រាយបំណុលមរតកជាមួយដៃគូ លែងជាកង្វល់ចំពោះកាតព្វកិច្ចបំណុលជាយថាហេតុសម្រាប់កម្ពុជាទៀតហើយ ដោយកិច្ចការនេះស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន និងមិនជះឥទ្ធិពលអវិជ្ជមាន ដល់ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានោះទេ។

១០.៣. ការវាយតម្លៃគោលនយោបាយ និងស្ថាប័នប្រទេស (Country Policy and Institutional Assessment – CPIA)

យោងតាមការវាយតម្លៃគោលនយោបាយនិងស្ថាប័នប្រទេស របស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ បង្ហាញថា ពីមួយឆ្នាំទៅមួយឆ្នាំ កម្ពុជាទទួលបានចំណាត់ថ្នាក់ល្អប្រសើរជាលំដាប់។ សមិទ្ធផលទាំងនេះ ស្តែងចេញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកែទម្រង់លើវិស័យអាទិភាពនានា ដូចជា៖ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កែទម្រង់រដ្ឋបាលសាធារណៈ, និងកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាល ជាដើម ដែលជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការរក្សាចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ពិន្ទុនៃការវាយតម្លៃគោលនយោបាយនិងស្ថាប័នប្រទេសរបស់កម្ពុជា ក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយ (២០០៩ - ២០១៨) មានដូចតារាងទី៧ ខាងក្រោម៖

តារាងទី៧៖ ពិន្ទុនៃការវាយតម្លៃគោលនយោបាយនិងស្ថាប័នប្រទេសរបស់កម្ពុជា (ឆ្នាំ២០០៩ - ២០១៨)

ឆ្នាំ	ធនាគារអភិវឌ្ឍន៍អាស៊ី	ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ
២០០៩	៣,៩	៣,៣
២០១០	៤,០	៣,៤
២០១១	៤,០	៣,៤
២០១២	៤,២	៣,៤
២០១៣	៤,១	៣,៤
២០១៤	៤,២	៣,៤
២០១៥	៤,២	៣,៤
២០១៦	៤,១	៣,៤
២០១៧	-	៣,៤
២០១៨	៤,១	-

ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ

ក្នុងការវាយតម្លៃគោលនយោបាយនិងស្ថាប័នប្រទេស ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗបានពិនិត្យទៅលើសូចនាករគន្លឹះចំនួន ១៦ ដោយដាក់ពិន្ទុពី ១ (អប្បបរមា) ទៅ ៦ (អតិបរមា) ដែលក្នុងនោះក៏មានសូចនាកគោលនយោបាយបំណុលមួយផងដែរ។ ជាមោទនភាពនៅក្នុងការគ្រប់គ្រងបំណុលសាធារណៈសូចនាកគោលនយោបាយបំណុលទទួលបានពិន្ទុខ្ពស់ជាងគេ ក្នុងចំណោមសូចនាករគន្លឹះទាំងអស់គឺ ៥,០ ពិន្ទុ (ធនាគារអភិវឌ្ឍន៍អាស៊ី) ដែលជាពិន្ទុខ្ពស់ជាងគេ ធៀបនឹងបណ្តាប្រទេសនានាក្នុងតំបន់ ដែលមានមធ្យមភាគត្រឹម ៣,៩ ពិន្ទុ។ ចំពោះធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ សូចនាកនេះទទួលបានពិន្ទុ ៤,៥។

ជាការកត់សម្គាល់ អាស្រ័យដោយការគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជា មាន៖ ១) ក្របខ័ណ្ឌគតិយុត្ត, គោលនយោបាយ, និងយុទ្ធសាស្ត្រ ច្បាស់លាស់; ២) រចនាសម្ព័ន្ធស្ថាប័នរឹងមាំ; ៣) ធនធានមនុស្សប្រកបដោយសមត្ថភាព; និង ៤) ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈគ្រប់ជ្រុងជ្រោយ ពិន្ទុនៃការវាយតម្លៃសូចនាករគោលនយោបាយបំណុលមានភាពល្អប្រសើរជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ពិន្ទុនៃការវាយតម្លៃសូចនាករគោលនយោបាយបំណុលសម្រាប់កម្ពុជា ក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយ (២០០៩ - ២០១៨) មានដូចតារាងទី៨ ខាងក្រោម៖

តារាងទី៨៖ ពិន្ទុនៃការវាយតម្លៃសូចនាករគោលនយោបាយបំណុលសម្រាប់កម្ពុជា (ឆ្នាំ២០០៩-២០១៨)

ឆ្នាំ	ធនាគារអភិវឌ្ឍន៍អាស៊ី	ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ
២០០៩	៤,០	៣,៥
២០១០	៤,០	៣,៥
២០១១	៤,៥	៣,៥
២០១២	៥,០	៤,០
២០១៣	៥,០	៤,០
២០១៤	៥,០	៤,០
២០១៥	៥,០	៤,៥
២០១៦	៥,០	៤,៥
២០១៧	-	៤,៥
២០១៨	៥,០	-

ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ

ជារួម វឌ្ឍនភាពទាំងអស់ខាងលើ សបញ្ជាក់ឱ្យឃើញថា តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ និងការបន្តប្រកាន់ខ្ជាប់ជានិច្ចនូវបទដ្ឋានបច្ចេកទេសអន្តរជាតិ, គោលការណ៍, និងវិន័យនៃការគ្រប់គ្រងបំណុលសាធារណៈ ស្ថានភាពនៃការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា កាន់តែវិឌ្ឍទៅរកភាពល្អប្រសើរឡើងជាលំដាប់។ ទន្ទឹមនេះ តាមលទ្ធផលនៃការវិភាគចីរភាពបំណុល ស្ថានភាពបំណុលសាធារណៈ កម្ពុជាបច្ចុប្បន្នមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»** ដែលលទ្ធផលនេះក៏ត្រូវបានវាយតម្លៃនិងទទួលស្គាល់ផងដែរ ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម។ សមិទ្ធផលទាំងនេះ ជាសក្ខីភាពបង្ហាញថា រាជរដ្ឋាភិបាលបាននិងកំពុងដើរនៅលើផ្លូវដ៏ត្រឹមត្រូវក្នុងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព។

១០.៤. ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ

ក្នុងគោលបំណងបន្តលើកកម្ពស់តម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តសិទ្ធិភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ បានរៀបចំព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ប្រចាំឆមាស និងបោះពុម្ពជាសៀវភៅចែកជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ, ស្ថានទូត, គ្រឹះស្ថានអប់រំ, ដៃគូអភិវឌ្ឍន៍, និងអង្គការក្រៅរដ្ឋាភិបាលនានា ព្រមទាំងបានផ្សព្វផ្សាយនៅលើគេហទំព័រផ្លូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាទៀងទាត់ មិនលើសពី ៣ខែ បន្ទាប់ពីដំណាច់ឆមាសនីមួយៗ តាំងពីឆ្នាំ២០១៦ មកម្ល៉េះ។

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ ត្រូវបានរៀបរៀងឡើងជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ដោយអនុលោមតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ដែលមានវិសាលភាពគ្របដណ្តប់លើទិន្នន័យស្តីពី៖ ១) បំណុលសាធារណៈក្រៅប្រទេស; ២) បំណុលសាធារណៈក្នុងប្រទេស; និង ៣) ការផ្តល់ឥណទានរបស់រដ្ឋដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ទិន្នន័យនៅក្នុងព្រឹត្តិបត្រនេះ ត្រូវបានបែងចែកជា ៤ ក្រុម គឺ៖ ១) ការខ្ចី, ២) ការដកសាច់ប្រាក់, ៣) សេវាបំណុល (ការទូទាត់ជូនឥណទាយក និងការប្រមូលពីឥណទាយិកក្រោមក្របខ័ណ្ឌនៃការផ្តល់ឥណទានរបស់រដ្ឋ), និង ៤) សន្និធិបំណុល ហើយដែលត្រូវបានចាត់ចំណាត់ប្រភេទទៅតាម៖ វិស័យ, ឥណទាយក/ឥណទាយិក, និងរូបិយប័ណ្ណ។

ព្រឹត្តិបត្រនេះ អាចទាញយកបានតាមរយៈ៖ *https://mef.gov.kh/public-debt-bulletin.html* ឬ *https://gdicdm.mef.gov.kh/en/cat/documents-and-publications/bulletins*។

ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣

ឧបសម្ព័ន្ធ ៣

ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣

ចង្កោមសកម្មភាព	សកម្មភាព	ពេលវេលា	អង្គភាពទទួលបន្ទុក
១) ពិនិត្យ និងរៀបចំក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ	- ពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់ស្តីពី «មូលបត្ររដ្ឋ» ព្រមទាំងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា	២០១៩ - ២០២១	កសហវ
	- ពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មអនុក្រឹត្យស្តីពី «ការគ្រប់គ្រងបំណុលសាធារណៈ»	២០២១ - ២០២២	កសហវ/ អសប
	- ពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ប្រកាសស្តីពី «គោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់តំណាងដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ»	២០២០ - ២០២១	កសហវ/ អសប
	- រៀបចំ និងដាក់ឱ្យអនុវត្ត «នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍»	២០១៩	កសហវ/ អសប
	- ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម «នីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ»	២០១៩ - ២០២១	កសហវ/ អសប
២) ពង្រឹងការគ្រប់គ្រងនិងតាមដានស្ថានភាព និងហានិភ័យបំណុលពាក់ព័ន្ធ	- បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័នមួយដើម្បីសិក្សា និងចងក្រងព័ត៌មាននិងទិន្នន័យ ពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ	២០១៩ - ២០២០	កសហវ/ អសប
	- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ	២០២០ - ២០២១	កសហវ/ អសប
	- ធ្វើបច្ចុប្បន្នកម្មការវិភាគចីរភាពបំណុល ជារៀងរាល់ឆ្នាំ	២០១៩ - ២០២៣	កសហវ/ អសប
	- រៀបចំ «ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា» រៀងរាល់ឆមាស មិនលើសពី ២ខែ បន្ទាប់ពីដំណាច់ឆមាសនីមួយៗ	២០២១ - ២០២៣	កសហវ/ អសប
	- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ	២០១៩ - ២០២៣	កសហវ/ អសប
៣) ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស	- អនុវត្ត «ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»	២០១៩ - ២០២៣	កសហវ/ អសប

សម្គាល់៖

- កសហវ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អសប៖ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល

ក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៩ - ២០២៣

មាតិកា

ជំពូកទី១៖ សេចក្តីផ្តើម ១
ជំពូកទី២៖ គោលបំណង, គោលដៅ, និងវិសាលភាព ២
២.១. គោលបំណង ២
២.២. គោលដៅ ២
២.៣. វិសាលភាព ២
ជំពូកទី៣៖ ការវិភាគហានិភ័យពាក់ព័ន្ធ ៣
៣.១. ហានិភ័យចម្បងៗ ៣
៣.១.១. ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities) ៣
៣.១.២. ហានិភ័យថវិកា (Fiscal Risk) ៤
៣.១.៣. ហានិភ័យទីផ្សារ (Market Risk) ៥
៣.២. ហានិភ័យបន្ទាប់បន្សំ ៧
៣.២.១. ហានិភ័យប្រតិបត្តិការ (Operational Risk) ៧
៣.២.២. ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk) ៧
៣.២.៣. ហានិភ័យហិរញ្ញប្បទាននៃគម្រោង (Project Funding Risk) ៨
៣.២.៤. ហានិភ័យឥណទាន (Credit Risk) ៩
ជំពូកទី៤៖ វិធានការ ១០
៤.១. វិធានការចំពោះហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ១០
៤.២. វិធានការចំពោះហានិភ័យថវិកា ១០
៤.៣. វិធានការចំពោះហានិភ័យទីផ្សារ ១១
៤.៤. វិធានការចំពោះហានិភ័យប្រតិបត្តិការ ១២
៤.៥. វិធានការចំពោះហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល ១២
៤.៦. វិធានការចំពោះហានិភ័យហិរញ្ញប្បទាននៃគម្រោង ១២
៤.៧. វិធានការចំពោះហានិភ័យឥណទាន ១៣

បញ្ជីក្រាហ្វ៖

- ក្រាហ្វទី១៖ សន្និធិបំណុលសាធារណៈ ត្រឹមដំណាច់ឆ្នាំ២០១៨ ..... ៦
- ក្រាហ្វទី២៖ សន្និធិបំណុលសាធារណៈក្រៅប្រទេសតាមរូបិយប័ណ្ណ ត្រឹមដំណាច់ឆ្នាំ២០១៨ ..... ៦
- ក្រាហ្វទី៣៖ ព្យាករណ៍កម្មវិធីទូទាត់សេវាបំណុលប្រចាំខែ ឆ្នាំ២០១៩ - ២០២៣ ..... ៨

ជំពូកទី១
សេចក្តីផ្តើម

កន្លងមក, រាជរដ្ឋាភិបាលតែងប្រកាន់ខ្ជាប់នូវស្មារតីប្រយ័ត្នប្រយែងខ្ពស់ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដោយគ្រប់គ្រងទាំងលើការខ្ចីប្រាក់ពីគេ, ការឱ្យប្រាក់គេខ្ចី, ការធានា, និងជាពិសេស ហានិភ័យពាក់ព័ន្ធនានា ដោយរួមបញ្ចូលទាំងកាតព្វកិច្ចបំណុលជាយថាហេតុ។ ជាក់ស្តែង, ក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១ - ២០១៨ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រមួយចំនួនក្នុងការពង្រឹងការតាមដាន និងត្រួតពិនិត្យហានិភ័យបំណុលសាធារណៈ ហើយនៅដំណាក់កាលបន្ទាប់, រាជរដ្ឋាភិបាលបានកំណត់អត្តសញ្ញាណ និងវិភាគហានិភ័យបំណុលសាធារណៈពាក់ព័ន្ធ ដោយបានរៀបចំជាគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ភ្ជាប់ជាឧបសម្ព័ន្ធថ្មីមួយ នៃយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ តែម្តង ហើយដែលឧបសម្ព័ន្ធថ្មីនេះ គឺជាក្របខ័ណ្ឌរួមសម្រាប់គ្រប់គ្រង និងតាមដានហានិភ័យបំណុលសាធារណៈ ដែលបានដាក់ចេញនូវវិធានការគន្លឹះៗ ក្នុងការត្រៀមលក្ខណៈជាមុន ដើម្បីបង្ការ និងបញ្ចៀសហានិភ័យបំណុលនីមួយៗ ព្រមទាំងសម្រាលបន្ទុកនិងដោះស្រាយបានទាន់ពេលវេលា ប្រសិនបើមានហានិភ័យបំណុលកើតឡើង។

តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការគន្លឹះៗ ដែលបានដាក់ចេញទាំងនេះ, រហូតមកទល់បច្ចុប្បន្ន ពុំមានហានិភ័យបំណុលធំដុំកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈរបស់កម្ពុជាទេ ពោលគឺ ហានិភ័យបំណុលពាក់ព័ន្ធនីមួយៗ សុទ្ធតែស្ថិតក្នុងភាពអាចគ្រប់គ្រងបាន។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលយល់ថា ថ្វីត្បិតតែកម្ពុជាកំពុងស្ថិតក្នុងចំណាត់ថ្នាក់ជាប្រទេសមាន **«ហានិភ័យបំណុលកម្រិតទាប»** ក៏ពិតមែន ប៉ុន្តែ មិនមែនមានន័យថា កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលមានសុវត្ថិភាព ដែលត្រូវព្រងើយកន្តើយនោះឡើយ។ ការណ៍នេះ តម្រូវឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីនៃសេដ្ឋកិច្ច ដែលកាន់តែរីកលូតលាស់ ហើយការគ្រប់គ្រងបំណុលសាធារណៈ កាន់តែមានភាពស្មុគស្មាញជាងមុន។

ក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៩ - ២០២៣ គឺជាឧបករណ៍ជំនួយដ៏សំខាន់ និងជាសមាសធាតុដែលមិនអាចខ្វះបាន ក្នុងការរួមចំណែកអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព សំដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យមនិងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាប។

ក្របខ័ណ្ឌរួមនេះ ជា **«ឯកសាររស់»** ដែលអាចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។

ជំពូកទី២

គោលបំណង, គោលដៅ, និងវិសាលភាព

២.១. គោលបំណង

ក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៩ - ២០២៣ មានគោលបំណងធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការគ្រប់គ្រង និងតាមដានហានិភ័យបំណុលសាធារណៈពាក់ព័ន្ធ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាប។

២.២. គោលដៅ

ក្របខ័ណ្ឌរួមនេះ មានគោលដៅកំណត់វិធានការគន្លឹះៗក្នុងការគ្រប់គ្រង និងតាមដានហានិភ័យបំណុលសាធារណៈពាក់ព័ន្ធ ដែលរួមមាន៖ ការត្រៀមលក្ខណៈជាមុន ដើម្បីបង្ការ និងបញ្ចៀសហានិភ័យបំណុលនីមួយៗ ព្រមទាំងសម្រាលបន្ទុកនិងដោះស្រាយបានទាន់ពេលវេលា ប្រសិនបើមានហានិភ័យបំណុលកើតឡើង។

២.៣. វិសាលភាព

ក្របខ័ណ្ឌរួមស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៩ - ២០២៣ មានវិសាលភាពគ្របដណ្តប់លើហានិភ័យដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ, ការឱ្យប្រាក់គេខ្ចី, និងការធានា។

ជំពូកទី៣
ការវិភាគហានិភ័យពាក់ព័ន្ធ

រាជរដ្ឋាភិបាលយល់ថា ក្នុងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចដែលកាន់តែរីកលូតលាស់ ស្ថានភាពបំណុលសាធារណៈកម្ពុជា អាចនឹងទទួលរងនូវផលប៉ះពាល់ពីហានិភ័យចម្បងៗ និងហានិភ័យបន្ទាប់បន្សំមួយចំនួន ដូចខាងក្រោម៖

៣.១. ហានិភ័យចម្បងៗ

៣.១.១. ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities)

និយមន័យ៖ សំដៅដល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ឧបត្ថម្ភធន, ទូទាត់សំណង, ឬដោះស្រាយបន្ទាន់ ក្នុងករណីមានព្រឹត្តិការណ៍ជាក់លាក់ណាមួយកើតឡើងនាពេលអនាគត ដូចជា៖ ការធានា, ការរ៉ាប់រង, ការទូទាត់សំណងមហន្តរាយ, ការបង់វិភាគទានសម្រាប់សមាជិកភាពកម្ពុជាក្នុងអង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍ពហុភាគី និងអង្គការអន្តរជាតិនានា, ព្រមទាំងការផ្តល់សំណងតាមបណ្តឹងនីត្យានុកូលជាដើម។ កាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានបែងចែកជា ២ ប្រភេទគឺ៖ ១) កាតព្វកិច្ចបំណុលជាយថាហេតុដែលអាចប្រមើលឃើញបាន (Explicit) និង ២) កាតព្វកិច្ចបំណុលជាយថាហេតុដែលមិនអាចប្រមើលឃើញបាន (Implicit)។

ផលប៉ះពាល់៖ ក្នុងករណីមានព្រឹត្តិការណ៍ណាមួយដែលស្ថិតក្រោមកាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកើតឡើង នោះកាតព្វកិច្ចបំណុលជាយថាហេតុ នឹងក្លាយជាបំណុលសាធារណៈ ដែលបង្កើតឱ្យមានបន្ទុកបំណុលធ្ងន់ធ្ងរ ហើយបង្កជាការខាតបង់ហិរញ្ញវត្ថុ និងបន្ថែមសម្ពាធដល់ថវិកាជាតិ ឬប្រសិនបើធ្ងន់ធ្ងរជាងនេះ ដល់ស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច។

ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន កាតព្វកិច្ចបំណុលជាយថាហេតុអាចកើតចេញពីកត្តាធំៗ ចំនួន ២ ដូចខាងក្រោម៖

៣.១.១.១. ការធានា (Guarantee)

កាតព្វកិច្ចបំណុលជាយថាហេតុដែលកើតចេញពីការធានារបស់រដ្ឋ អាចបង្កឱ្យមានបន្ទុកហិរញ្ញវត្ថុ ឬបំណុលសាធារណៈដល់រាជរដ្ឋាភិបាល ក្នុងករណីដែលរាជរដ្ឋាភិបាលមានភាពចាំបាច់ត្រូវបញ្ចប់កិច្ចសន្យាវិនិយោគជាមួយវិស័យឯកជនមុនកាលកំណត់ហើយទិញគម្រោងត្រឡប់មកវិញ និងក្នុងករណីដែលសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ ឬនីតិបុគ្គលសាធារណៈ ដែលទទួលបានការធានាពីរដ្ឋ ពុំមានលទ្ធភាពទូទាត់ថ្លៃទំនិញ, សេវា, កម្រៃផ្សេងៗ, សេវាបំណុល, ឬបំពេញកាតព្វកិច្ចហិរញ្ញវត្ថុនានាផ្សេងទៀតតាមកិច្ចព្រមព្រៀងជូនក្រុមហ៊ុនវិនិយោគ ឬឥណទាយក។

ស្ថានភាពបច្ចុប្បន្ន៖ ក្នុងបរិការណ៍បច្ចុប្បន្ន កាតព្វកិច្ចបំណុលជាយថាហេតុ កើតចេញពីការធានារលើគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) ក្នុងវិស័យអគ្គិសនី ដែលគិតមកទល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានផ្តល់ការធានាទូទាត់ និង/ឬ ធានាទិញគម្រោង លើគម្រោងវិនិយោគតាមយន្តការ PPP/BOT/BOO ក្នុងវិស័យអគ្គិសនីចំនួន **២២ គម្រោង** ក្នុងនោះ៖ គម្រោងស្ថានីយវារីអគ្គិសនីចំនួន **៨ គម្រោង**, គម្រោងរោងចក្រអគ្គិសនីដុតធ្យូងថ្មចំនួន **៦ គម្រោង**, គម្រោងស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ

ចំនួន **៣ គម្រោង**, គម្រោងខ្សែបញ្ជូនអគ្គិសនីចំនួន **៥ គម្រោង**។

ក្នុងករណីដែលអគ្គិសនីកម្ពុជា ពុំមានលទ្ធភាពទូទាត់ជូនក្រុមហ៊ុនវិនិយោគ នោះកាតព្វកិច្ចបំណុលជាយថាហេតុ នឹងក្លាយជាបំណុលសាធារណៈ ដែលនឹងបន្ថែមសម្ពាធលើថវិកាជាតិ។ ទោះជាយ៉ាងនេះក្តី បើវិភាគលើស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុជាក់ស្តែង របស់អគ្គិសនីកម្ពុជាបច្ចុប្បន្ន លទ្ធភាពដែលកាតព្វកិច្ចបំណុលជាយថាហេតុនឹងក្លាយជាបំណុលសាធារណៈ គឺមានកម្រិតទាបបំផុត។

៣.១.១.២. វិស័យធនាគារ និងហិរញ្ញវត្ថុ (Banking and Financial Sector)

ជាទូទៅ កាតព្វកិច្ចបំណុលជាយថាហេតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ អាចកើតចេញពីកត្តាចម្បងៗមួយចំនួន ដូចជា៖ វិបត្តិនៃប្រតិបត្តិការរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក, ផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុក្នុងតំបន់ ឬសកលលោក, អតិផរណា, ការប្រែប្រួលដ៏គំហុកនៃអត្រាប្តូរប្រាក់, ការផ្តល់ឥណទានដ៏ច្រើនសន្ធឹកសន្ធាប់របស់ធនាគារលើវិស័យអចលនទ្រព្យ, ទំហំបំណុលអាក្រក់ច្រើនពេក (Bad debts), ការដកសាច់ប្រាក់ដ៏គំហុកពីធនាគារ, និងការធ្លាក់ចុះដ៏គំហុកនូវទំហំប្រាក់បញ្ញើ។ល។ ភាគច្រើននៃកាតព្វកិច្ចបំណុលជាយថាហេតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ គឺជាប្រភេទកាតព្វកិច្ចបំណុលជាយថាហេតុដែលមិនអាចប្រមើលឃើញបាន។

ស្ថានភាពបច្ចុប្បន្ន៖ តាមរយៈរបាយការណ៍ឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា បានឱ្យដឹងថា វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា មានភាពរឹងមាំល្អ ដែលឆ្លុះបញ្ចាំងតាមរយៈសូចនាករគន្លឹះៗ មួយចំនួនរួមមាន៖ ១) អនុបាតសោធនភាពនៃគ្រឹះស្ថានធនាគារមានកម្រិតជាមធ្យមប្រមាណ **២៤,២ ភាគរយ** និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **១៩,៨ ភាគរយ** ធៀបនឹងកម្រិតអប្បបរមា **១៥ ភាគរយ**, ២) អនុបាតសន្ទនីយភាពមានកម្រិតជាមធ្យមប្រមាណ **១៥៨,៨ ភាគរយ** សម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និង **២១៣,៦ ភាគរយ** សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ធៀបនឹងកម្រិតអប្បបរមា **៧០ ភាគរយ**, និង ៣) ឥណទានមិនដំណើរការមានកម្រិតទាបប្រមាណ **២,២ ភាគរយ** សម្រាប់គ្រឹះស្ថានធនាគារ និង **១,៣ ភាគរយ** សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ទោះជាយ៉ាងនេះក្តី អត្រាការប្រាក់ខ្ពស់ និងការកើនឡើងបំណុលរបស់គេហជន នៅតែជាបញ្ហាប្រឈមចម្បង នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។

៣.១.២. ហានិភ័យថវិកា (Fiscal Risk)

និយមន័យ៖ សំដៅដល់ហានិភ័យដែលកើតឡើងដោយសារសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ ដែលជាធាតុចូលសំខាន់សម្រាប់ការវិភាគចីរភាពបំណុល ដូចជា៖ កំណើន ផសស, ចំណូលថវិកាជាតិ, ការនាំចេញ, អត្រាប្តូរប្រាក់ ពុំសម្រេចបានតាមគោលដៅរំពឹងទុក។ ការវិភាគចីរភាពបំណុល គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការកំណត់ពិដានៃការខ្ចីបន្ថែម នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយធានាបាននូវចីរភាពបំណុលរយៈពេលមធ្យម និងវែង ព្រមទាំងរក្សាកម្រិតហានិភ័យបំណុលឱ្យនៅទាប។

ផលប៉ះពាល់៖ ប្រសិនបើហានិភ័យនេះកើតឡើង នឹងបណ្តាលឱ្យប៉ះពាល់ដល់សុក្រឹត្យភាពលទ្ធផលនៃការវិភាគចីរភាពបំណុល ដែលមានន័យថា ពិដាននៃការខ្ចីប្រចាំឆ្នាំមិនសមស្របតាមបរិការណ៍សេដ្ឋកិច្ចជាក់ស្តែង។ លើសពីនេះទៀត ក៏អាចនឹងប៉ះពាល់ដល់ស្ថានភាពបំណុលសាធារណៈផងដែរ ក្នុងករណីដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានជាមួយដៃគូអភិវឌ្ឍន៍ ដោយផ្អែកតាមពិដាននៃការខ្ចីដែលបានកំណត់រួចហើយនោះ។

ស្ថានភាពបច្ចុប្បន្ន៖ ក្នុងរយៈកាលកន្លងទៅ (២០១៥ - ២០១៨) សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ

ដែលធាតុចូលសំខាន់សម្រាប់ការវិភាគចីរភាពបំណុល សុទ្ធតែសម្រេចបានលទ្ធផលល្អប្រសើរតាមគោលដៅរំពឹងទុក ក្នុងនោះ៖ ផសស សម្រេចបានកំណើនជាមធ្យមក្នុងរង្វង់ **៧ ភាគរយ** ក្នុងមួយឆ្នាំ, និង ចំណូលថវិកាជាតិសម្រេចបានកំណើនជាមធ្យមក្នុងរង្វង់ **១ ពិន្ទុភាគរយ នៃ ផសស** ក្នុងមួយឆ្នាំ។ ទន្ទឹមនេះ ការនាំចេញ សម្រេចបានកំណើនជាមធ្យមក្នុងរង្វង់ **១១ ភាគរយ**, និងអត្រាប្តូរប្រាក់ស្ថិតក្នុងរង្វង់ជាមធ្យម **៤ ០៥០ រៀល** ក្នុងមួយដុល្លារអាមេរិក។

ទោះជាយ៉ាងនេះក្តី ក្នុងករណីប្រសិទ្ធភាពនៃការអនុវត្តវិធានការជាកញ្ចប់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដើម្បីទប់ទល់នូវការគំរាមកំហែងពីខាងក្រៅ មានកម្រិត នោះសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ សម្រាប់ឆ្នាំ២០១៩ - ២០២៣ អាចនឹងពុំសម្រេចបានតាមគោលដៅដែលបានរំពឹងទុក ហើយអាចនឹងប៉ះពាល់ដល់ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា។

៣.១.៣. ហានិភ័យទីផ្សារ (Market Risk)

សំដៅដល់ហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុ ដែលបណ្តាលមកពីការប្រែប្រួលតម្លៃទីផ្សារនៃធាតុចូលពាក់ព័ន្ធ រួមមាន៖ ហានិភ័យរូបិយប័ណ្ណ និងហានិភ័យអត្រាការប្រាក់។

៣.១.៣.១. ហានិភ័យរូបិយប័ណ្ណ (Currency Risk)


និយមន័យ៖ សំដៅដល់ហានិភ័យដែលកើតឡើងដោយសារការធ្លាក់ចុះតម្លៃរូបិយវត្ថុជាតិធៀបនឹងរូបិយប័ណ្ណបំណុល។ ប៉ុន្តែ សម្រាប់កម្ពុជា អាចមានពីរករណីគឺ៖ ១) ការធ្លាក់ចុះតម្លៃរូបិយវត្ថុជាតិធៀបនឹងដុល្លារអាមេរិក និង ២) ការធ្លាក់ចុះតម្លៃដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណបំណុល ព្រោះថា បច្ចុប្បន្ន ក្នុងការទូទាត់សេវាបំណុលសាធារណៈក្រៅប្រទេស ក្នុងករណីរូបិយប័ណ្ណបំណុលជារូបិយប័ណ្ណផ្សេងក្រៅពីដុល្លារអាមេរិក នោះរាជរដ្ឋាភិបាលត្រូវយករូបិយវត្ថុជាតិទៅប្តូរជាដុល្លារអាមេរិកជាមុនសិន រួចទើបយកដុល្លារអាមេរិកទៅទិញរូបិយប័ណ្ណបំណុល ដើម្បីទូទាត់ជូនដៃគូអភិវឌ្ឍន៍។

ផលប៉ះពាល់៖ ប្រសិនបើហានិភ័យនេះកើតឡើង នោះក្នុងក្របខ័ណ្ឌនៃការខ្វីប្រាក់ពីគេ នឹងបណ្តាលឱ្យសន្និធិបំណុល និងបន្ទុកសេវាបំណុលមានទំហំធំជាងមុន ដែលអាចមានសម្ពាធដល់លទ្ធភាពទូទាត់សេវាបំណុលរបស់រាជរដ្ឋាភិបាល។


ស្ថានភាពបច្ចុប្បន្ន៖ ដោយហេតុថា រាជរដ្ឋាភិបាលពុំទាន់បានចាប់ផ្តើមកៀរគរទុនហិរញ្ញវត្ថុពីទីផ្សារមូលបត្រក្នុងប្រទេសមកបំពេញតម្រូវការវិនិយោគសាធារណៈនៅឡើយ ហើយពឹងផ្អែកខ្លាំងលើការខ្វីឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដូច្នេះ ក្នុងចង្កោមបំណុលសាធារណៈរបស់កម្ពុជាបច្ចុប្បន្ន ភាគច្រើនលើសលុប គឺជារូបិយប័ណ្ណបំណុលបរទេស[1] ដែលគិតត្រឹមដំណាច់ឆ្នាំ២០១៨ មានប្រមាណ **៩៩,៩៦ ភាគរយ** ក្នុងនោះ៖ ដុល្លារអាមេរិក **៤៤ ភាគរយ**, អេសដេអ៊ែរ **២៧ ភាគរយ**, យ័នចិន **១៥ ភាគរយ**, យ៉េនជប៉ុន **៥ ភាគរយ**, វ៉ុនកូរ៉េ **៥ ភាគរយ**, អឺរ៉ូ **៣ ភាគរយ,** និងបាតថៃ **១ ភាគរយ**។

[1] *បំណុលជារូបិយវត្ថុជាតិ មានចំនួន **១១,១៨ ប៊ីលានរៀល** កើតចេញពីការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋមិនអាចជួញដូរបាន ដើម្បីបំពេញទុនឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ។*

ក្រាហ្វទី១៖ សន្និធិបំណុលសាធារណៈ ត្រឹមដំណាច់ឆ្នាំ២០១៨



ក្រាហ្វទី២៖ សន្និធិបំណុលសាធារណៈក្រៅប្រទេសតាមរូបិយប័ណ្ណ ត្រឹមដំណាច់ឆ្នាំ២០១៨



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣.១.៣.២. ហានិភ័យអត្រាការប្រាក់ (Interest Rate Risk)

និយមន័យ៖ សំដៅដល់ហានិភ័យដែលកើតឡើងដោយសារការកើនឡើងនៃអត្រាការប្រាក់ឥណទាន។ ហានិភ័យនេះកើតឡើងតែទៅលើឥណទានទាំងឡាយណា ដែលមានអត្រាការប្រាក់ប្រែប្រួល (Floating Rate) ប៉ុណ្ណោះ។

ផលប៉ះពាល់៖ ប្រសិនបើហានិភ័យនេះកើតឡើង នឹងបណ្តាលឱ្យបន្ទុកការប្រាក់ដែលត្រូវទូទាត់ជូនដៃគូអភិវឌ្ឍន៍កើនឡើង ដែលនឹងអាចប៉ះពាល់ដល់លទ្ធភាពទូទាត់សេវាបំណុលរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ កម្រិតសម្បទាននៃឥណទានក៏នឹងធ្លាក់ចុះផងដែរ។

ស្ថានភាពបច្ចុប្បន្ន៖ នៅក្នុងចង្កោមបំណុលសាធារណៈក្រៅប្រទេសបច្ចុប្បន្នរបស់កម្ពុជា ពុំមានហានិភ័យកើតចេញពីអត្រាការប្រាក់ទេ ដោយហេតុថា រាល់ឥណទានសម្បទានដែលរាជរដ្ឋាភិបាលខ្ចីកន្លងមកសុទ្ធសឹងជាឥណទានដែលមានអត្រាការប្រាក់ថេរ (Fixed Rate)។ ទន្ទឹមនេះ ចំពោះប្រភេទឥណទានមាន

អត្រាការប្រាក់ប្រៃប្រួល រាជរដ្ឋាភិបាលបានចាត់វិធានការបំប្លែងឱ្យទៅជាឥណទានដែលមានអត្រាការប្រាក់ថេរ រួចហើយ។ ទោះជាយ៉ាងនេះក្តី ក្នុងបរិការណ៍នៃការអភិវឌ្ឍថ្មី រាជរដ្ឋាភិបាល នឹងបន្តពិចារណាទទួលយកឥណទានប្រភេទនេះ បន្ទាប់ពីសិក្សាវិភាគថ្លឹងថ្លែងឱ្យបានស៊ីជម្រៅទៅលើហានិភ័យនៃបម្រែបម្រួលនៃអត្រាការប្រាក់។

៣.២. ហានិភ័យបន្ទាប់បន្សំ

៣.២.១. ហានិភ័យប្រតិបត្តិការ (Operational Risk)

និយមន័យ៖ សំដៅដល់ហានិភ័យ ដែលកើតឡើងដោយសារភាពចន្លោះប្រហោងនៃប្រព័ន្ធគ្រប់គ្រងការងារ, ការធ្វេសប្រហែសរបស់មន្ត្រីទទួលបន្ទុក, បច្ចេកវិទ្យាហួសសម័យ, កំហុសបច្ចេកទេស, ឬករណីប្រធានសក្តិ ដែលធ្វើឱ្យរាំងស្ទះ ឬអាក់រអួលដល់ប្រតិបត្តិការគ្រប់គ្រងបំណុលសាធារណៈ។ នៅក្នុងបរិការណ៍នៃការគ្រប់គ្រងបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន ហានិភ័យប្រតិបត្តិការអាចកើតចេញពីកត្តាចម្បងចំនួន ៣ គឺ៖ ប្រព័ន្ធគ្រប់គ្រងការងារ, មនុស្ស, និងបច្ចេកវិទ្យា។

ផលប៉ះពាល់៖ ប្រសិនបើហានិភ័យនេះកើតឡើង នឹងបណ្តាលឱ្យមានការរាំងស្ទះដល់កិច្ចដំណើរការអនុវត្តការងារពាក់ព័ន្ធ។

ស្ថានភាពបច្ចុប្បន្ន៖ ជារួម, តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់តាមវិធានការគន្លឹះៗ ដែលបានដាក់ចេញនៅក្នុងគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៥ - ២០១៨ ក្នុងរយៈពេល ៤ឆ្នាំនេះ ពុំមានហានិភ័យប្រតិបត្តិការធំដុំកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃគ្រប់គ្រងបំណុលសាធារណៈនោះទេ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលនឹងបន្តខិតខំកែលម្អបន្ថែមទៀត ដើម្បីឱ្យការគ្រប់គ្រងហានិភ័យប្រតិបត្តិការ កាន់តែមានភាពគ្រប់ជ្រុងជ្រោយ ស្របតាមគោលការណ៍ណែនាំជាអន្តរជាតិ។

៣.២.២. ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk)

និយមន័យ៖ សំដៅដល់ហានិភ័យដែលកើតឡើងដោយសារឱនភាពសាច់ប្រាក់ បណ្តាលមកពីមានតម្រូវការសាច់ប្រាក់គំហុក និងបន្ទាន់ សម្រាប់ទូទាត់សេវាបំណុល ដូចជា៖ ការដោះស្រាយកាតព្វកិច្ចបំណុលជាយថាហេតុ, ការដោះស្រាយបំណុលមរតកជាមួយដៃគូ, ការបង្គរបន្ទុកសេវាបំណុលច្រើនពេកក្នុងខែណាមួយ, ឬកត្តាផ្សេងទៀត។


ផលប៉ះពាល់៖ ប្រសិនបើហានិភ័យនេះកើតឡើង នឹងបណ្តាលឱ្យការទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍មានភាពយឺតយ៉ាវ ឬ ត្រូវបានពន្យារពេល។ ក្នុងករណីនេះ បន្ទុកសេវាបំណុលដែលត្រូវទូទាត់នឹងមានទំហំធំជាងមុន ដោយហេតុថា រាជរដ្ឋាភិបាលត្រូវទូទាត់ទាំងប្រាក់ពិន័យលើភាពយឺតយ៉ាវបន្ថែម និងក្នុងករណីធ្ងន់ធ្ងរជាងនេះ នៅពេលដែលបំណុលត្រូវបានបង្គរកាន់តែច្រើន នឹងអាចប៉ះពាល់ដល់លទ្ធភាពសង។

ស្ថានភាពបច្ចុប្បន្ន៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុងរវាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អង្គភាពគ្រប់គ្រងបំណុលសាធារណៈ) និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ តាមរយៈកិច្ចសហការចែករំលែកព័ត៌មាន និងធ្វើបច្ចុប្បន្នកម្មទិន្នន័យសេវាបំណុលជាប់ជាប្រចាំ។

ទន្ទឹមនេះ សម្រាប់ការខ្ចីថ្មី ក្នុងឆ្នាំ២០១៥ - ២០១៨ កន្លងទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តវិធានការបញ្ចៀសឱ្យបាននូវហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល ដោយរៀបចំកម្មវិធី

ទូទាត់សេវាបំណុល មិនឱ្យស្ថិតក្នុងខែដែលមានបន្ទុកសេវាបំណុលច្រើន ជាពិសេស ខែមីនា និងកញ្ញា។ តាមរយៈនេះ ទំហំសេវាបំណុលក្នុងខែមីនា និងកញ្ញា បានធ្លាក់ចុះបន្តិចម្តងៗ គួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងនេះក្តី តាមការព្យាករ បង្ហាញថា កម្មវិធីទូទាត់សេវាបំណុលប្រចាំខែសម្រាប់ឆ្នាំ២០១៩ - ២០២៣ នៅពុំទាន់មានភាពល្អប្រសើរនៅឡើយទេ ថ្វីត្បិតតែទំហំសេវាបំណុលក្នុងខែមីនា និងកញ្ញា មាននិន្នាការធ្លាក់ចុះបន្តិចម្តងៗ ពីរង្វង់ **១៨ ភាគរយ** មក **១៣ ភាគរយ** នៃទំហំសេវាបំណុលសរុបប្រចាំឆ្នាំ ក៏ពិតមែន ក៏ប៉ុន្តែ នៅតែស្ថិតក្នុងកម្រិតខ្ពស់ ហើយសេវាបំណុលក្នុងខែកុម្ភៈ និងសីហា ក៏មានទំហំធំខ្លាំងផងដែរ ក្នុងរង្វង់ពី **១៥ ភាគរយ** ទៅ **២១ ភាគរយ** ធៀបនឹងកម្រិតឧត្តមានុពល (Optimum Level) **៨ ភាគរយ** ដោយសារឥណទានសម្បទានធំៗដែលបានចុះកិច្ចព្រមព្រៀងកន្លងមក ត្រូវដល់ពេលសងប្រាក់ដើម។ ព្យាករណ៍កម្មវិធីទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៩ - ២០២៣ មានលម្អិតក្នុងក្រាហ្វទី៣ ខាងក្រោម៖

ក្រាហ្វទី៣៖ ព្យាករណ៍កម្មវិធីទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៩ - ២០២៣



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣.២.៣. ហានិភ័យហិរញ្ញប្បទាននៃគម្រោង (Project Funding Risk)

និយមន័យ៖ សំដៅដល់ហានិភ័យ ដែលកើតឡើងដោយសារដៃគូអភិវឌ្ឍន៍បញ្ឈប់ការផ្តល់ហិរញ្ញប្បទានភ្លាមៗ ដែលរាជរដ្ឋាភិបាលចាំបាច់ត្រូវស្វែងរកហិរញ្ញប្បទានពីប្រភពផ្សេងទៀតមកជំនួសតាមលក្ខខណ្ឌផ្សេងពីលក្ខខណ្ឌនៃហិរញ្ញប្បទានដើម។

ផលប៉ះពាល់៖ ប្រសិនបើហានិភ័យនេះកើតឡើង នឹងបង្កឱ្យមានការរាំងស្ទះដល់ដំណើរការអនុវត្តគម្រោង ឬអាចនឹងបង្កើតបន្ទុកចំណាយជាយថាហេតុក្នុងអំឡុងពេលនៃការអនុវត្តគម្រោងដែលតម្រូវឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវស្វែងរកហិរញ្ញប្បទានឥណទានពីដៃគូអភិវឌ្ឍន៍ ឬប្រភពផ្សេងទៀតមកជំនួសជាបន្ទាន់ដើម្បីបន្តអនុវត្តគម្រោងឱ្យបានជោគជ័យជាស្តាពរ។ ជារួម លក្ខខណ្ឌឥណទានដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ច្រើនតែមានលក្ខខណ្ឌអនុគ្រោះ ឬ កម្រិតសម្បទានទាបជាងឥណទានដើម ដែលវានឹងធ្វើឱ្យបន្ទុកសេវាបំណុលមានទំហំធំជាងមុន ហើយប៉ះពាល់ដល់លទ្ធភាពក្នុងការទូទាត់របស់រាជរដ្ឋាភិបាល។

ស្ថានភាពបច្ចុប្បន្ន៖ ក្នុងរយៈពេល ៤ឆ្នាំ កន្លងទៅ ពុំមានហានិភ័យនេះកើតឡើងទេ ពោលគឺ គ្មានការលុបចោលការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ណាមួយ លើគម្រោងដែលកំពុងអនុវត្តនោះឡើយ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល ក៏បាននិងកំពុងខិតខំបន្តពង្រឹងយន្តការកិច្ចសន្ទនាក្នុងកម្រិតគោលនយោបាយ និងទំនាក់ទំនងល្អជាប្រពៃណីជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ព្រមទាំងធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យមានលក្ខណៈទូលំទូលាយជាងមុន ផងដែរ។

៣.២.៤. ហានិភ័យឥណទាន (Credit Risk)

និយមន័យ៖ សំដៅដល់ហានិភ័យ ដែលកើតឡើងដោយសារឥណទាយិក ក្នុងក្របខ័ណ្ឌនៃការឱ្យខ្ចីដោយប្រើប្រាស់ថវិការដ្ឋ (Lending) ឬការឱ្យខ្ចីបន្តពីឥណទានសម្បទានរបស់ដៃគូ (On-Lending) ពុំមានលទ្ធភាពទូទាត់សេវាបំណុលជូនរដ្ឋ ទាន់ពេលវេលា។

ផលប៉ះពាល់៖ ប្រសិនបើហានិភ័យនេះកើតឡើង នឹងបណ្តាលឱ្យចំណូលដែលបានមកពីសេវាបំណុលធ្លាក់ចុះទាបជាងផែនការដែលបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលអាចនាំឱ្យមានឱនភាពថវិកាបន្ថែម។

ស្ថានភាពបច្ចុប្បន្ន៖ ក្នុងរយៈកាលកន្លងទៅ ការប្រមូលចំណូលសេវាបំណុលពីឥណទាយិក ត្រូវបានធ្វើឡើងជាទៀងទាត់ និងទាន់ពេលវេលា។ ទន្ទឹមនេះ ស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុរបស់ឥណទាយិក មានស្ថានភាពរឹងមាំ និងល្អប្រសើរ។ យ៉ាងណាមិញ ក៏នៅមានឥណទាយិកខ្លះ ពុំទាន់មានស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុនឹងនរនៅឡើយ បើទោះជារាជរដ្ឋាភិបាល បានអនុវត្តនូវវិធានការជួយសម្រាលបន្ទុកសេវាបំណុលរួចហើយក្តី ដែលនេះបង្កជាក្តីបារម្ភចំពោះលទ្ធភាពនៃការកើតមាននូវបំណុលអាក្រក់ (Bad debt)។

ជំពូកទី៤
វិធានការ

ដើម្បីត្រៀមលក្ខណៈជាមុន ក្នុងការបង្ការ និងបញ្ចៀសហានិភ័យបំណុលសាធារណៈពាក់ព័ន្ធ ព្រមទាំងសម្រាលបន្ទុក និងដោះស្រាយទាន់ពេលវេលា នៅពេលមានហានិភ័យបំណុលកើតឡើង រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគន្លឹះៗ សម្រាប់គ្រប់គ្រង និងតាមដានហានិភ័យនីមួយៗ ដូចខាងក្រោម៖

៤.១. វិធានការចំពោះហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ

- បន្តពង្រឹងការអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។
- បន្តអនុវត្តនីតិវិធី, គោលនយោបាយ, យុទ្ធសាស្ត្រ, និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ប្រកបដោយភាពម៉ឺងម៉ាត់ និងប្រសិទ្ធភាពខ្ពស់។
- បន្តមិនផ្តល់ការធានាឥណទានចំពោះវិស័យឯកជន។
- បន្តវិភាជន៍ថវិកា ក្នុងរង្វង់ **៥ ភាគរយ នៃសៀវភៅបំណុលសរុបប្រចាំឆ្នាំ** ទៅក្នុង**មូលនិធិបម្រុង** (Contingency Fund) សម្រាប់ត្រៀមដោះស្រាយការធានាទូទាត់របស់រដ្ឋ ដែលនឹងអាចកើតឡើងជាយថាហេតុ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏អាចយកមូលនិធិនេះទៅវិនិយោគដើម្បីបានចំណូលជាគុណប្រយោជន៍ថវិកាជាតិ ផងដែរ។
- កំណត់ពិដានៃការធានាទូទាត់សរុប សម្រាប់គម្រោងថ្មី មិនឱ្យលើសពី **១០ ភាគរយ នៃចំណូលថវិកាជាតិ**។ ពិដាននេះ នឹងត្រូវបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម ជារៀងរាល់ឆ្នាំ ដើម្បីធានាបាននូវសង្គតិភាពជាមួយក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។
- ពង្រឹងយន្តការច្រកចេញ - ចូលតែមួយ នៅអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះរាល់សំណើគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP។
- ធនាគារជាតិនៃកម្ពុជា ត្រូវបន្តសិក្សា និងតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន និងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីវិស័យធនាគារ និងហិរញ្ញវត្ថុ ហើយចែករំលែកព័ត៌មាននិងទិន្នន័យទាំងនោះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងត្រូវពង្រឹងការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ, និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ប្រកបដោយភាពម៉ឺងម៉ាត់ និងប្រសិទ្ធភាពខ្ពស់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័នមួយ ដើម្បី៖ ១) សិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសនានា ក្នុងគោលបំណងបន្តពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ និង ២) ចងក្រងព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ សម្រាប់ជាគុណប្រយោជន៍នៃការវិភាគ និងគ្រប់គ្រងហានិភ័យ។

៤.២. វិធានការចំពោះហានិភ័យថវិកា

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តតាមដានជាប្រចាំលើការប្រែប្រួលសូចនាករម៉ាក្រូសេដ្ឋកិច្ច

គន្លឹះៗ ដូចជា៖ កំណើន ផសស, ចំណូលថវិកាជាតិ, ការនាំចេញ, និងអត្រាប្តូរប្រាក់ ហើយលើកសំណើជាវិធានការគោលនយោបាយ ក្នុងករណីចាំបាច់។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើបច្ចុប្បន្នកម្មការវិភាគចីរភាពបំណុល ជារៀងរាល់ឆ្នាំ ហើយក្នុងករណីធាតុចូលសំខាន់ៗមានការប្រែប្រួលខ្លាំង ត្រូវធ្វើបច្ចុប្បន្នកម្មការវិភាគចីរភាពបំណុលភ្លាមៗ ដើម្បីកំណត់ពិដានខ្ចីប្រចាំឆ្នាំឡើងវិញ ។

៤.៣. វិធានការចំពោះហានិភ័យទីផ្សារ

○ ចំពោះហានិភ័យរូបិយប័ណ្ណ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអប្បមាទជាប់ជាប្រចាំលើរូបិយប័ណ្ណបំណុលដែលមានហានិភ័យខ្ពស់ ដើម្បីកុំឱ្យប៉ះពាល់ដល់លទ្ធភាពនៃការទូទាត់សេវាបំណុល និងភាពអាចទ្រាំទ្របាននៃថវិកា និងសេដ្ឋកិច្ចជាតិ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ត្រូវបន្តកិច្ចសហការ ក្នុងការចែករំលែកព័ត៌មាន និងតាមដានដោយប្រុងប្រយ័ត្នទៅលើបម្រែបម្រួលសមាសភាគរូបិយប័ណ្ណបំណុលជាពិសេស រូបិយប័ណ្ណដែលមានចំណែកធំ នៅក្នុងសន្និធិបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា ហើយដែលអត្រាប្តូរប្រាក់នៃរូបិយប័ណ្ណទាំងនោះមានការប្រែប្រួលខ្លាំង។ ទន្ទឹមនេះ ត្រូវរក្សាទុកទុនបម្រុងជារូបិយប័ណ្ណបំណុលដែលត្រូវទូទាត់ជូនដៃគូអភិវឌ្ឍន៍ ស្របតាមទំហំ និងកម្មវិធីទូទាត់សេវាបំណុល។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់ឥណទានបន្តជូនឥណទាយិក ជារូបិយប័ណ្ណនៃឥណទានដើមដែលរដ្ឋខ្ចីពីដៃគូអភិវឌ្ឍន៍។ ទន្ទឹមនេះ នៅក្នុងដំណាក់កាលទូទាត់ ឥណទាយិកដែលទទួលបានឥណទានពីរដ្ឋ ត្រូវទូទាត់សេវាបំណុលជូនរដ្ឋតាមអត្រាប្តូរប្រាក់ដែលរដ្ឋទូទាត់ជូនដៃគូអភិវឌ្ឍន៍។

○ ចំពោះហានិភ័យអត្រាការប្រាក់

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តសិក្សា និងវិភាគឱ្យបានស៊ីជម្រៅទៅលើបម្រែបម្រួលនៃអត្រាការប្រាក់ពាក់ព័ន្ធនានា មុននឹងសម្រេចទទួលយកឥណទានដែលមានអត្រាការប្រាក់ប្រែប្រួលណាមួយពីដៃគូអភិវឌ្ឍន៍ ដើម្បីជានាថា ក្នុងករណីដែលអត្រាការប្រាក់មានការប្រែប្រួល នោះហានិភ័យដែលអាចកើតឡើង មានកម្រិតទាបបំផុត ដែលនឹងមិនធ្វើឱ្យបន្ទុកការប្រាក់កើនឡើងខ្លាំង ហើយកម្រិតសម្បទាននៃឥណទានក៏មិនធ្លាក់ចុះខ្លាំង។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តចរចាជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកំណត់អត្រាការប្រាក់អតិបរមា (Interest Rate Cap) ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចទទួលយកបាន។
- បន្តអនុវត្តវិធានការបំប្លែងឥណទានដែលមានអត្រាការប្រាក់ប្រែប្រួល ឱ្យទៅជាឥណទានដែលមានអត្រាការប្រាក់ថេរ (Fixed Rate) នៅថ្ងៃដកសាច់ប្រាក់ជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងពិចារណាលើជម្រើសដកសាច់ប្រាក់ជាកញ្ចប់តែមួយដង (Single Disbursement) ពីដៃគូអភិវឌ្ឍន៍ ប្រសិនបើមានភាពអំណោយផលជាងជម្រើសដកសាច់ប្រាក់ច្រើនដង (Multiple Disbursements) ហើយអាចយកសាច់ប្រាក់ដែលបានដក និងមិនទាន់យកទៅប្រើប្រាស់ទៅវិនិយោគ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីបានចំណូលមកជួយសម្រាលបន្ទុកការប្រាក់ និងកម្រៃផ្សេងៗ ដែលត្រូវទូទាត់ជូនដៃគូ។

៤.៤. វិធានការចំពោះហានិភ័យប្រតិបត្តិការ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តពង្រឹងការអនុវត្តនីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ; នីតិវិធីរួមសម្រាប់ការគ្រប់គ្រង និងអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍; និងឯកសារណែនាំលម្អិតស្តីពី ១) ដំណើរការធ្វើអត្តសញ្ញាណកម្ម រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, ២) កិច្ចដំណើរការលទ្ធកម្ម, និង ៣) កិច្ចដំណើរការពិនិត្យសំណើសុំថវិកា ក្រោមក្របខ័ណ្ឌកម្មវិធី/គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ព្រមទាំងពិនិត្យ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យរួម សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ព្រមទាំងពិនិត្យ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តពង្រឹងសមត្ថភាពធនធានមនុស្សទាំងគុណភាព និងទាំងបរិមាណឱ្យសមស្របទៅនឹងតម្រូវការនៃការងារ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសិក្សាពិនិត្យលទ្ធភាពរៀបចំផែនការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។

៤.៥. វិធានការចំពោះហានិភ័យសន្ធនីយភាពក្នុងការទូទាត់សេវាបំណុល

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តចរចាជាមួយដៃគូ ដើម្បីរៀបចំកម្មវិធីទូទាត់សេវាបំណុលឱ្យកាន់តែឆ្លើយតបនឹងលក្ខខណ្ឌតម្រូវនៃគោលការណ៍គ្រប់គ្រងសាច់ប្រាក់ ប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តអនុវត្តការគ្រប់គ្រងប្រតិបត្តិការចំណូល-ចំណាយរបស់រដ្ឋ នៅក្នុងគណនីទោលរតនាគារ (Treasury Single Account - TSA) ដើម្បីជៀសវាងកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តជំរុញកិច្ចសហការផ្ទៃក្នុងរវាងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការចែករំលែកព័ត៌មាន ទៅវិញទៅមកឱ្យបានទាន់ពេលវេលា។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តការប្រយ័ត្នប្រយែងខ្ពស់ក្នុងការចរចារៀបចំកម្មវិធីសងបំណុលមរតកជាមួយដៃគូពាក់ព័ន្ធ ដើម្បីកុំឱ្យមានបន្ទុកសេវាបំណុលធ្ងន់ធ្ងរក្នុងឆ្នាំដែលមិនបានគ្រោងថវិកា និងមិនប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវព្យាយាមសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីស្នើសុំកែសម្រួលកម្មវិធីទូទាត់សេវាបំណុលឡើងវិញ ក្នុងករណីដែលមានបន្ទុកសេវាបំណុលធ្ងន់ធ្ងរក្នុងខែមួយចំនួន។ ទន្ទឹមនេះ ចំពោះឥណទានថ្មី ត្រូវចរចាឱ្យដៃគូអភិវឌ្ឍន៍មានភាពទន់ភ្លន់ ក្នុងការកំណត់កម្មវិធីទូទាត់សេវាបំណុល។

៤.៦. វិធានការចំពោះហានិភ័យហិរញ្ញប្បទានឆៃគម្រោង

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តពង្រឹងយន្តការកិច្ចសន្ទនាក្នុងកម្រិតគោលនយោបាយ និងពង្រឹងទំនាក់ទំនងល្អជាប្រពៃណីជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធឱ្យកាន់តែល្អប្រសើរថែមទៀត។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ស្របតាម

នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, គោលនយោបាយ, គោលការណ៍ណែនាំ, និងនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តធ្វើពិពិធកម្មប្រភពឥណទានសម្បទានឱ្យមានលក្ខណៈទូលំទូលាយជាងមុន ដើម្បីបង្កើនលទ្ធភាព ក្នុងការស្វែងរកហិរញ្ញប្បទានមកជំនួសភ្លាមៗ ក្នុងករណីដែលគម្រោងត្រូវបានផ្អាក ឬ បញ្ឈប់ដោយព្រឹត្តិហេតុណាមួយ ទន្ទឹមនេះ ក៏ត្រូវពិចារណាក្នុងការទទួលយកឥណទានជារូបិយប័ណ្ណផ្សេង ក្រៅពីរូបិយប័ណ្ណដែលខ្ចីបច្ចុប្បន្ន ក្នុងករណីពិនិត្យឃើញថា រូបិយប័ណ្ណ និងលក្ខខណ្ឌឥណទាននោះ មានហានិភ័យទាប និងជាតុអំណោយខ្ពស់អាចទទួលយកបាន។

៤.៧. វិធានការចំពោះហានិភ័យឥណទាន

- ពង្រឹងការអនុវត្តប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មប្រកាសនេះ ឱ្យស្របតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងជានាបាននូវសង្គតិភាពជាមួយរចនាសម្ព័ន្ធស្ថាប័នបច្ចុប្បន្ន។
- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដោយត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមគោលការណ៍នៃ «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥»៕

ការវិភាគចីរភាពបំណុល
២០១៩ - ២០២៩

មាតិកា

ជំពូកទី១៖ សេចក្តីផ្តើម ១
ជំពូកទី២៖ គោលបំណង, គោលដៅ, និងវិសាលភាព ២
២.១. គោលបំណង ២
២.២. គោលដៅ ២
២.៣. វិសាលភាព ២
ជំពូកទី៣៖ ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រឹមដំណាច់ឆ្នាំ២០១៨ ..... ៣
៣.១. ការខ្ចី ៣
៣.២. ការដកសាច់ប្រាក់ ៤
៣.៣. ការទូទាត់សេវាបំណុល ៤
៣.៤. សន្និធិបំណុល ៥
៣.៥. សូចនាករបំណុល ៥
ជំពូកទី៤៖ តម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈ ៧
ជំពូកទី៥៖ ការវិភាគ ៨
៥.១. សេណារីយ៉ូនៃការខ្ចីថ្មីបន្ថែម ៨
៥.២. បទដ្ឋានបច្ចេកទេសអន្តរជាតិក្នុងការវិភាគ ៨
៥.៣. សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ សម្រាប់ការវិភាគ ៩
៥.៣.១. សេណារីយ៉ូមូលដ្ឋាន (Baseline Scenario) ៩
៥.៣.២. សេណារីយ៉ូសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ មានកំណើនថមថយ (Customized Scenario) .. ១០
៥.៤. លទ្ធផលនៃការវិភាគ ១០
៥.៤.១. សេណារីយ៉ូទី១ ..... ១០
៥.៤.២. សេណារីយ៉ូទី២ ..... ១៣
៥.៤.៣. សេណារីយ៉ូទី៣ ..... ១៦
ជំពូកទី៦៖ សន្និដ្ឋាន ១៩

បញ្ជីតារាង៖

- តារាងទី១៖ អនុបាតគោលនៃបំណុល ៩
- តារាងទី២៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី១ ..... ១២
- តារាងទី៣៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី២ ..... ១៥
- តារាងទី៤៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី៣ ..... ១៨

បញ្ជីក្រាហ្វ៖

- ក្រាហ្វទី១៖ ការខ្ចី ត្រឹមដំណាច់ឆ្នាំ២០១៨ ..... ៣
- ក្រាហ្វទី២៖ ការដកសាច់ប្រាក់ ត្រឹមដំណាច់ឆ្នាំ២០១៨ ..... ៤
- ក្រាហ្វទី៣៖ ការទូទាត់សេវាបំណុលក្រៅប្រទេសសរុប ត្រឹមដំណាច់ឆ្នាំ២០១៨ ..... ៥
- ក្រាហ្វទី៤៖ ការព្យាករតម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈ ២០១៩ - ២០២៣ .... ៧
- ក្រាហ្វទី៥៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី១ ..... ១១
- ក្រាហ្វទី៦៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី២ ..... ១៤
- ក្រាហ្វទី៧៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី៣ ..... ១៧

ជំពូកទី១
សេចក្តីផ្តើម

នៅមុនឆ្នាំ២០១១ អាស្រ័យដោយសមត្ថភាពធនធានមនុស្សនៅមានកម្រិត កម្ពុជាតែងពឹងផ្អែកសំខាន់លើរបាយការណ៍ស្តីពីការវិភាគចីរភាពបំណុល និងយោបល់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ជាមូលដ្ឋានក្នុងការកំណត់ពិដានៃការខ្ចីប្រចាំឆ្នាំ។ ចាប់ពីឆ្នាំ២០១១ មក អាស្រ័យដោយមានភាពរីកចម្រើននៃធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលជំនាញនានាទាំងក្នុង និងក្រៅប្រទេសកម្ពុជាក៏ចាប់ផ្តើមធ្វើការវិភាគចីរភាពបំណុលដោយខ្លួនឯង។

ជាក់ស្តែង អនុលោមតាមមាត្រា ៣០ នៃអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ បានរៀបចំឯកសារផ្លូវការស្តីពីការវិភាគចីរភាពបំណុល ភ្ជាប់ជាឧបសម្ព័ន្ធនៃយុទ្ធសាស្ត្របំណុលចំនួន ២ លើករួចមកហើយ គឺ ទាំងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១ - ២០១៨ និងទាំងយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨។ ទន្ទឹមនេះ ការវិភាគចីរភាពបំណុល ក៏ត្រូវបានសង្ខេបបញ្ចូលនៅក្នុងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ ដែលបោះផ្សាយប្រចាំឆមាស ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផងដែរ។

ក្នុងការវិភាគចីរភាពបំណុលនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់វិធីសាស្ត្រ ដែលជាបទដ្ឋានបច្ចេកទេសអន្តរជាតិ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ដោយផ្អែកលើស្ថានភាពបំណុលសាធារណៈជាក់ស្តែងរបស់កម្ពុជា ព្រមទាំងអនុលោមតាមក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដូចជា៖ យុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល, ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, និង យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម។

ការវិភាគចីរភាពបំណុល គឺជាឧបករណ៍ជំនួយដ៏មានសារៈសំខាន់ សម្រាប់វាស់ស្ទង់ស្ថានភាពបំណុលសាធារណៈ និងសមត្ថភាពទូទាត់បំណុលរបស់កម្ពុជា បច្ចុប្បន្ន និងរយៈពេល ១០ឆ្នាំទៅមុខ ព្រមទាំងដើម្បីជាមូលដ្ឋានកំណត់ពិដាននៃការខ្ចី នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវឯកសារស្តីពី «**ការវិភាគចីរភាពបំណុល ២០១៩-២០២៩**» ភ្ជាប់ជាឧបសម្ព័ន្ធនៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ សំដៅបន្តរក្សាបាននូវចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាប។

ឯកសារស្តីពីការវិភាគចីរភាពបំណុលនេះ គឺជា **«ឯកសារស់»** ដែលនឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ដើម្បីធានាបាននូវសង្គតិភាពជាមួយការប្រែប្រួលនៃធាតុចូលសំខាន់ៗ ក្នុងការវិភាគ ដូចជា៖ សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ, តម្រូវការហិរញ្ញប្បទានវិនិយោគសាធារណៈ, និងលក្ខខណ្ឌឥណទាន។ល។

ជំពូកទី២
គោលបំណង, គោលដៅ, និងវិសាលភាព

២.១. គោលបំណង

ឯកសារស្តីពី **«ការវិភាគចីរភាពបំណុល ២០១៩ - ២០២៩»** នេះ មានគោលបំណងធានានូវចីរភាពបំណុលសាធារណៈ រយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យឱ្យនៅទាប។

២.២. គោលដៅ

ឯកសារនេះ មានគោលដៅវិភាគ និងវាយតម្លៃលើសមត្ថភាពខ្វីថ្មីបន្ថែមប្រចាំឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ដោយផ្អែកលើស្ថានភាពបំណុលសាធារណៈបច្ចុប្បន្ន, តម្រូវការវិនិយោគមូលធនសាធារណៈក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣, និងបរិការណ៍ម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែង សំដៅរួមចំណែកក្នុងការបន្តរក្សាស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា។

២.៣. វិសាលភាព


ឯកសារស្តីពី **«ការវិភាគចីរភាពបំណុល ២០១៩ - ២០២៩»** នេះ មានវិសាលភាពគ្របដណ្តប់លើបំណុលសាធារណៈក្នុងប្រទេស និងបំណុលសាធារណៈក្រៅប្រទេស ដោយរួមទាំងបំណុលដែលមានការធានាពីរដ្ឋ។

ជំពូកទី៣
ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រឹមដំណាច់ឆ្នាំ២០១៨

៣.១. ការខ្ចី

គិតចាប់ពីឆ្នាំ១៩៩៣ រហូតមកត្រឹមដំណាច់ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានសម្បទានជាមួយដៃគូអភិវឌ្ឍន៍សរុបចំនួន **៣១២ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់ចំនួនប្រមាណ **១១,៤ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ៖ ការចុះកិច្ចព្រមព្រៀងក្រោមក្របខ័ណ្ឌពហុភាគី មានចំនួន **១៧១ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់ប្រមាណ **៤,១ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៤០ ភាគរយ** និងក្រោមក្របខ័ណ្ឌទ្វេភាគីមានចំនួន **១៤១ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់ប្រមាណ **៧,៣ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៦០ ភាគរយ**។

ក្រាហ្វទី១៖ ការខ្ចី ត្រឹមដំណាច់ឆ្នាំ២០១៨



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


ឥណទានសម្បទានទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីបំពេញតម្រូវការវិនិយោគសាធារណៈលើវិស័យអាទិភាពនានារបស់រាជរដ្ឋាភិបាលក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែង និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ក្នុងនោះ៖ វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, អាកាសយានដ្ឋាន, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការផ្គត់ផ្គង់ទឹកស្អាត, និងស្ថានីយ៍ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់) មានចំនួន **២៣១ គម្រោង/កម្មវិធី** ដែលមានទឹកប្រាក់ចំនួនប្រមាណ **៩,៩ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៨៧ ភាគរយ** និងវិស័យអាទិភាពចំពោះមុខផ្សេងទៀត (ដូចជា៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, និងជីធ្លី) មានចំនួន **៨១ គម្រោង/ កម្មវិធី** ដែលមានទឹកប្រាក់ចំនួនប្រមាណ **១,៥ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **១៣ ភាគរយ**។

ជារួម ឥណទានដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងកន្លងមក ភាគច្រើនបំផុតជាឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដោយមានធាតុអំណោយចាប់ពី **៣៥ ភាគរយ** ឡើងទៅ។ លក្ខខណ្ឌនៃឥណទានទាំងនោះ រួមមាន៖ អត្រាការប្រាក់ពី **សូន្យ** ទៅ **២ ភាគរយ** ក្នុងមួយឆ្នាំ, រយៈពេលសងពី **២០** ទៅ **៤០ឆ្នាំ**, និងរយៈពេលអនុគ្រោះពី **៧** ទៅ **១៥ឆ្នាំ**។

៣.២. ការដកសាច់ប្រាក់

គិតចាប់ពីឆ្នាំ១៩៩៣ រហូតដល់ត្រឹមដំណាច់ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់ជាក់ស្តែងសរុបប្រមាណ **៧,៣ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៦៤ ភាគរយ** នៃទំហំឥណទានសម្បទានសរុបដែលបានចុះកិច្ចព្រមព្រៀង។ សាច់ប្រាក់ដែលបានដកទាំងនេះ ប្រមាណ **៦,៣ ប៊ីលានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **៨៧ ភាគរយ** ត្រូវបានប្រើប្រាស់ដើម្បីហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការផ្គត់ផ្គង់ទឹកស្អាត, និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ និងប្រមាណ **៩៤៣ លានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **១៣ ភាគរយ** ទៀត ត្រូវបានប្រើប្រាស់ដើម្បីហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាពចំពោះមុខផ្សេងទៀត ដូចជា៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, ជីធ្លី, និងកសិកម្ម។

ក្រាហ្វទី២៖ ការដកសាច់ប្រាក់ ត្រឹមដំណាច់ឆ្នាំ២០១៨




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


៣.៣. ការទូទាត់សេវាបំណុល

ដោយគិតបញ្ចូលទាំងបំណុលមរតកដែលបានរៀបចំកម្មវិធីសងឡើងវិញ ត្រឹមដំណាច់ឆ្នាំ២០១៨ កម្ពុជាបានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍សរុបចំនួនប្រមាណ **១,៤ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ៖ ប្រាក់ដើម មានចំនួនប្រមាណ **៨១៩ លានដុល្លារអាមេរិក** ហើយការប្រាក់និងកម្រៃពាក់ព័ន្ធផ្សេងៗ មានចំនួនប្រមាណ **៥៤៨ លានដុល្លារអាមេរិក** ដូចមានក្នុងក្រាហ្វទី៣ ខាងក្រោម៖


ក្រាហ្វទី៣ ៖ ការទូទាត់សេវាបំណុលសាធារណៈក្រៅប្រទេសសរុប ត្រឹមដំណាច់ឆ្នាំ២០១៨



តាមឥណទាយក



តាមរូបិយប័ណ្ណ



ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣.៤. សន្និធិបំណុល

ដោយគិតបញ្ចូលទាំងបំណុលមរកតកំពុងដោះស្រាយ ត្រឹមដំណាច់ឆ្នាំ២០១៨ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ **៧ ប៊ីលានដុល្លារអាមេរិក** ដោយភាគច្រើនលើសលុប (៩៩,៩៦ ភាគរយ) ជាបំណុលសាធារណៈក្រៅប្រទេស ខណៈដែលបំណុលសាធារណៈក្នុងប្រទេស (កើតចេញពីការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋមិនអាចជួញដូរបាន ដើម្បីបំពេញទុនឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋ) មានចំនួនតិចតួចបំផុតត្រឹមប្រមាណ **២,៨ លានដុល្លារអាមេរិក** ត្រូវនឹងប្រមាណ **០,០៤ ភាគរយ** នៃសន្និធិបំណុលសាធារណៈសរុប។

៣.៥. សូចនាករបំណុល

សម្រាប់ឆ្នាំ២០១៨ សូចនាករបំណុលគន្លឹះៗទាំង៥ របស់កម្ពុជាសុទ្ធតែស្ថិតក្រោមអនុបាតគោលនៃបទដ្ឋានបច្ចេកទេសអន្តរជាតិ ក្នុងនោះ៖ ១) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផសស មានត្រឹម **២១,៥ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **៥៥ ភាគរយ**, ២) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស មានត្រឹម **២១,៥ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **៤០**

ភាគរយ, ៣) អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ មានត្រឹម **២៨,៤ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **១៨០ ភាគរយ**, ៤) អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញមានត្រឹម **១,៤ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **១៥ ភាគរយ**, និង ៥) អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិមានត្រឹម **៤,៩ ភាគរយ** ធៀបនឹងអនុបាតគោលកម្រិត **១៨ ភាគរយ**។


ក្នុងស្ថានភាពបែបនេះ បញ្ជាក់ច្បាស់ថា បំណុលសាធារណៈកម្ពុជាបច្ចុប្បន្នមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»**។

ជំពូកទី៤
តម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈ

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ ដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ជាមូលដ្ឋាន រាជរដ្ឋាភិបាលត្រូវការទុនវិនិយោគសាធារណៈសរុបប្រមាណ **១៥ ប៊ីលានដុល្លារអាមេរិក** ក្នុងនោះ ហិរញ្ញប្បទានក្នុងស្រុកមានចំនួន **៧ ប៊ីលានដុល្លារអាមេរិក** ត្រូវនឹងប្រមាណ **៤៧ ភាគរយ** និង ហិរញ្ញប្បទានក្រៅប្រទេសមានចំនួន **៨ ប៊ីលានដុល្លារអាមេរិក** ត្រូវនឹងប្រមាណ **៥៣ ភាគរយ**។ ជារួម មានន័យថា រាជរដ្ឋាភិបាលចាំបាច់ត្រូវកៀរគរហិរញ្ញប្បទានពីប្រភពនានាក្រៅប្រទេស (ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន) ឱ្យបានជាមធ្យមក្នុងរង្វង់ **១,៦ ប៊ីលានដុល្លារអាមេរិក** ក្នុងមួយឆ្នាំ។

ទោះជាយ៉ាងនេះក្តី ប្រសិនបើគិតបញ្ចូលនូវតម្រូវការទាំងអស់នៃចំណាយវិនិយោគសាធារណៈដែលរាជរដ្ឋាភិបាលបានគ្រោងទុក ដូចមានក្នុងយុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៤ និងការប្តេជ្ញាចិត្តនៅក្នុងគោលនយោបាយដទៃទៀត ដូចជា៖ ការលើកកម្ពស់វិស័យអប់រំ, ការបង្កើតប្រព័ន្ធគាំពារសង្គម, ការគាំទ្រសមត្ថភាពបច្ចេកទេសរដ្ឋបាលនៃស្ថាប័នរាជរដ្ឋាភិបាល (រួមទាំងផែនការអភិវឌ្ឍន៍តាមវិស័យ ដែលត្រូវពិចារណាដោយ រាជរដ្ឋាភិបាលអាណត្តិទី៦នេះ នោះតម្រូវការហិរញ្ញប្បទានវិនិយោគសាធារណៈសរុប អាចនឹងត្រូវកើនប្រមាណ **៤៩ ភាគរយ** បន្ថែមទៀត។ ដូចនេះ ការកៀរគរហិរញ្ញប្បទានពីក្រៅប្រទេស ជាពិសេសគឺឥណទានសម្បទាន ក៏នឹងត្រូវបង្កើនទៅតាមនោះដែរ។

ក្រាហ្វទី៤ ៖ ការព្យាករតម្រូវការហិរញ្ញប្បទានវិនិយោគមូលធនសាធារណៈ ២០១៩ - ២០២៣



ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

ជំពូកទី៥
ការវិភាគ

៥.១. សេណារីយ៉ូនៃការខ្ចីថ្មីបន្ថែម

ឈរលើតម្រូវការហិរញ្ញប្បទានវិនិយោគសាធារណៈខាងលើ រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមពីក្រៅប្រទេសសម្រាប់ឆ្នាំ២០១៩ - ២០២៣ តាមសេណារីយ៉ូចំនួន ៣ ដូចខាងក្រោម៖

- **សេណារីយ៉ូទី១៖** ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ (សមមូលនឹងប្រមាណ ២,១ ប៊ីលាន ទៅ ២,៨ ប៊ីលានដុល្លារអាមេរិក)។
- **សេណារីយ៉ូទី២៖** ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី **២ ប៊ីលាន** ទៅ **៣ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ (សមមូលនឹង ២,៨ ប៊ីលាន ទៅ ៤,២ ប៊ីលានដុល្លារអាមេរិក)។
- **សេណារីយ៉ូទី៣៖** ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី **២,៥ ប៊ីលាន** ទៅ **៣,៥ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ (សមមូលនឹង ៣,៥ ប៊ីលាន ទៅ ៤,៩ ប៊ីលានដុល្លារអាមេរិក)។

៥.២. បទដ្ឋានបច្ចេកទេសអន្តរជាតិក្នុងការវិភាគ

ផ្អែកតាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ដែលទើបតែត្រូវបានកែសម្រួល និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ ការវាយតម្លៃលើស្ថានភាពបំណុលសាធារណៈក្រៅប្រទេសនៃប្រទេសមួយ ត្រូវបានកាត់បន្ថយពីការពិនិត្យលើសូចនាករបំណុលគន្លឹះៗចំនួន ៥ មក ៤ (ដោយលុបចោលនូវអនុបាតគោលតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងចំណូលថវិកាជាតិ) ហើយមូលដ្ឋានសម្រាប់កំណត់អនុបាតគោល មិនអាស្រ័យតែទៅលើពិន្ទុនៃការវាយតម្លៃគោលនយោបាយនិងស្ថាប័នប្រទេសទៀតទេ គឺអាស្រ័យលើសូចនាករបន្សំ (Composite Indicators - CI) ដែលត្រូវគណនាដោយផ្អែកលើទិន្នន័យរយៈពេល ១០ឆ្នាំ (៥ឆ្នាំ ជាតួលេខជាក់ស្តែង និង ៥ឆ្នាំ ជាតួលេខប៉ាន់ស្មាន និងព្យាករណ៍) នៃសូចនាករសំខាន់ៗចំនួន ៥ គឺ៖ ១- ពិន្ទុនៃការវាយតម្លៃគោលនយោបាយ និងស្ថាប័នប្រទេស (CPIA), ២- កំណើនផសស ពិត (Real GDP growth), ៣- ទុនបម្រុងធៀបនឹងការនាំចូល (Import coverage of reserves), ៤- ប្រាក់ទទួលបានពីបរទេស (Remittances), និង ៥- កំណើនសេដ្ឋកិច្ចពិភពលោក (World growth rate)។

ទន្ទឹមនេះ ចំពោះការវាយតម្លៃលើស្ថានភាពបំណុលសាធារណៈជារួមរបស់ប្រទេស គេត្រូវមើលទៅលើសូចនាករបំណុលគន្លឹះមួយទៀត គឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប (រួមបញ្ចូលនូវ៖ បំណុលសាធារណៈក្រៅប្រទេស, បំណុលសាធារណៈក្នុងប្រទេស, និងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹងផសស។

ជារួម គេត្រូវវិភាគស្ថានភាពបំណុលបច្ចុប្បន្ន និងរយៈពេល ១០ឆ្នាំ ទៅមុខ ដោយពិនិត្យលើសូចនាករបំណុលគន្លឹះៗចំនួន៥ ធៀបនឹងអនុបាតគោល ដែលមាន ៣ កម្រិត គឺ៖ ទាប, មធ្យម និងខ្ពស់ អាស្រ័យលើពិន្ទុនៃសូចនាករបន្សំ ដូចក្នុងតារាងខាងក្រោម៖

តារាងទី១៖ អនុបាតគោលនៃបំណុល

សូចនាករបំណុល	អនុបាតគោល		
	កម្រិតទាប CI < ២,៦៩	កម្រិតមធ្យម ២,៦៩ ≤ CI ≤ ៣,០៥	កម្រិតខ្ពស់ CI > ៣,០៥
- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប			
ធៀបនឹង ផសស	*៣៥%*	*៥៥%*	*៧០%*
- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស			
ធៀបនឹង ផសស	*៣០%*	*៤០%*	*៥៥%*
ធៀបនឹង ការនាំចេញ	*១៤០%*	*១៨០%*	*២៤០%*
- សេវាបំណុលនៃបំណុលសាធារណៈក្រៅប្រទេស			
ធៀបនឹង ការនាំចេញ	*១០%*	*១៥%*	*២១%*
ធៀបនឹង ចំណូលថវិកាជាតិ	*១៤%*	*១៨%*	*២៣%*

ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក - ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨

ផ្អែកតាមក្របខ័ណ្ឌនៃការវិភាគចីរភាពបំណុលថ្មីនេះ សូចនាករបន្សំ ត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាព ២ ដង ក្នុងមួយឆ្នាំ គឺនៅខែមេសា និងខែតុលា ហើយប្រទេសមួយអាចរំកិលការប្រើអនុបាតគោលពីកម្រិតមួយទៅកម្រិតមួយទៀត លុះត្រាតែមានពិន្ទុ CI ដែលស្ថិតក្នុងកម្រិតនោះចំនួន ២ដងជាប់គ្នា។ បន្ទាប់ពីមូលដ្ឋានក្នុងការកំណត់អនុបាតគោលត្រូវបានកែសម្រួលមក បច្ចុប្បន្ន កម្ពុជានៅតែប្រើប្រាស់អនុបាតគោល «**កម្រិតមធ្យម**» ដដែល។

៥.៣. សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ សម្រាប់ការវិភាគ

ធាតុចូលដ៏សំខាន់ដែលមិនអាចខ្វះបាន សម្រាប់ការវិភាគចីរភាពបំណុល គឺ សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ ដូចជា៖ កំណើន ផសស, ចំណូលថវិកាជាតិ, ការនាំចេញ, និងអត្រាប្តូរប្រាក់ ជាដើម។ ជាលក្ខខណ្ឌតម្រូវ ទិន្នន័យទាំងនេះត្រូវមាន៖ ១) ការអនុវត្តជាក់ស្តែងរយៈពេល ១០ឆ្នាំ ចុងក្រោយ, និង ២) ការប៉ាន់ស្មាន និងព្យាករណ៍រយៈពេល ២១ឆ្នាំ។

ដោយសារការព្យាករត្រូវបានធ្វើសម្រាប់រយៈពេលវែង ដូចនេះ សុក្រឹត្យភាពអាចនៅមានកម្រិត។ ទោះជាយ៉ាងនេះក្តី ក្នុងក្របខ័ណ្ឌនៃការវិភាគចីរភាពបំណុលនេះ រាជរដ្ឋាភិបាលបានព្យាករដោយឈរលើគោលការណ៍ប្រយ័ត្នប្រយែង និងមានសង្គតិភាពជាមួយក្របខ័ណ្ឌយុទ្ធសាស្ត្រនិងគោលនយោបាយពាក់ព័ន្ធនានា ព្រមទាំងបានធ្វើឯផ្ទាត់ជាមួយនឹងការព្យាកររបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ផងដែរ។

៥.៣.១. សេណារីយ៉ូមូលដ្ឋាន (Baseline Scenario)

ផ្អែកតាមក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩ - ២០២៣, និងក្នុងបរិការណ៍សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ សម្រាប់ឆ្នាំ២០១៩ - ២០៣៩ ដែលប្រើជាសេណារីយ៉ូមូលដ្ឋាន (Baseline Scenario) ក្នុងការវិភាគចីរភាពបំណុលត្រូវបានព្យាករ ដូចខាងក្រោម៖

- **កំណើន ផសស៖** ជាមធ្យម ក្នុងរង្វង់ ៧ ភាគរយ

- **ចំណូលថវិកាជាតិ៖** ជាមធ្យមកើនក្នុងរង្វង់ ០,៣ ពិន្ទុភាគរយ នៃ ផសស សម្រាប់ឆ្នាំ២០១៩ - ២០២៣ និងកើនក្នុងរង្វង់ ០,២ ពិន្ទុភាគរយ - ០,១ ពិន្ទុភាគរយ នៃ ផសស សម្រាប់ឆ្នាំ២០២៤ - ២០៣៩
- **ការនាំចេញ៖** ជាមធ្យមកើនក្នុងរង្វង់ ១០ ភាគរយ ក្នុងមួយឆ្នាំ
- **អត្រាប្តូរប្រាក់៖** ៤ ០៥៤ រៀល - ៤ ២០០ រៀល ក្នុងមួយដុល្លារអាមេរិក។

៥.៣.២. សេណារីយ៉ូសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ មានកំណើនថមថយ (Customized Scenario)

ទន្ទឹមនេះ ដោយឈរលើគោលការណ៍ប្រយ័ត្នប្រយែងក្នុងការវិភាគចីរភាពបំណុល រាជរដ្ឋាភិបាលបានបង្កើតនូវសេណារីយ៉ូសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ មានកំណើនថមថយ (Customized Scenario) មួយបន្ថែមទៀតគឺ ផសស, ចំណូលថវិកាជាតិ, និងការនាំចេញមានកំណើនទាប ដូចខាងក្រោម៖

- **កំណើន ផសស៖** ជាមធ្យម ក្នុងរង្វង់ ៦,៥% (២០១៩ - ២០២៣), ៦% (២០២៤ - ២០២៨), និង ៥% (២០២៩ - ២០៣៨), និង ៤% (២០៣៥ - ២០៣៩)
- **ចំណូលថវិកាជាតិ៖** ជាមធ្យមកើនក្នុងរង្វង់ ០,៣% ពិន្ទុភាគរយ នៃ ផសស សម្រាប់ឆ្នាំ២០១៩ - ២០២៣ និង កើនក្នុងរង្វង់ ០,០៥% - ០,១% ពិន្ទុភាគរយ នៃ ផសស សម្រាប់ឆ្នាំ២០២៤ - ២០៣៩
- **ការនាំចេញ៖** ជាមធ្យមកើនក្នុងរង្វង់ ៩,៥% (២០១៩ - ២០២៣), ៩% (២០២៤ - ២០២៨), ៨,៥% (២០២៩ - ២០៣៣), និង ៨% (២០៣៤ - ២០៣៩)

៥.៤. លទ្ធផលនៃការវិភាគ

លទ្ធផលនៃការវិភាគចីរភាពបំណុល សម្រាប់ឆ្នាំ២០១៩- ២០២៩ តាមសេណារីយ៉ូនៃការខ្ចីថ្មីបន្ថែមទាំង ៣ ខាងលើ មានដូចខាងក្រោម៖

៥.៤.១. សេណារីយ៉ូទី១ (ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី ១, ៥ ប៊ីលាន ទៅ ២ ប៊ីលានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣)


- លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូមូលដ្ឋាន (Baseline Scenario) និងការវិភាគវេទយិតភាព (Sensitivity Analysis) ដោយផ្អែកលើសន្និធិបំណុលសាធារណៈត្រឹមដំណាច់ឆ្នាំ២០១៨ (ដោយគិតទាំងបំណុលមរតក) បូកបន្ថែមនឹងការខ្ចីថ្មីតាមសេណារីយ៉ូទី១ បង្ហាញថា៖ ពុំមានសូចនាករណាមួយក្នុងចំណោមសូចនាករបំណុលសាធារណៈទាំង ៥ ខ្ពស់ជាងអនុបាតគោលទេ ក្នុងនោះ សូចនាករបំណុលសំខាន់ជាងគេ គឺអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស ឡើងខ្ពស់បំផុតត្រឹមរង្វង់ **៣៣ ភាគរយ** នៅឆ្នាំ២០២១ ធៀបនឹងអនុបាតគោលកម្រិត **៤០ ភាគរយ។**

- លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ មានកំណើនថមថយ (Customized Scenario) ដោយផ្អែកលើសន្និធិបំណុលសាធារណៈត្រឹមដំណាច់ឆ្នាំ២០១៨ (ដោយគិតបញ្ចូលទាំងបំណុលមរតក) បូកបន្ថែមនឹងការខ្ចីថ្មីតាមសេណារីយ៉ូទី១ បង្ហាញថា៖ នៅតែពុំមានសូចនាករណាមួយក្នុងចំណោមសូចនាករបំណុលសាធារណៈទាំង ៥ ឡើងខ្ពស់ជាងអនុបាតគោលនោះទេ ក្នុងនោះ សូចនាករបំណុលសំខាន់ជាងគេ គឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស សម្រាប់ឆ្នាំ២០១៩ - ២០២៩ មានខ្ពស់បំផុតត្រឹមរង្វង់ **២៦ ភាគរយ** នៅឆ្នាំ២០២៩ ធៀបនឹងអនុបាតគោលកម្រិត **៤០ ភាគរយ**។


ដូចនេះ លទ្ធផលនៃការវិភាគខាងលើ បញ្ជាក់ឱ្យឃើញថា កម្ពុជាមានសមត្ថភាពខ្ចីថ្មីបន្ថែមបាន ក្នុងរង្វង់ពី **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដៅអ៊ែរ** ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ដោយមិនប៉ះពាល់ដល់ស្ថានភាពបំណុលសាធារណៈនោះទេ ពោលគឺ នៅតែអាចបន្តរក្សាបាននូវ «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**»។

ក្រាហ្វទី៥- លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី១


ក- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុបធៀបនឹង ផសស




ខ- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស




គ- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ



ឃ- សេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ការនាំចេញ



ង- សេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ចំណូលចរិកាជាតិ





* *លទ្ធផលនៃការវិភាគនេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ*

តារាងទី២៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី១

សូចនាករបំណុល Debt Indicators		អនុបាតគោល Threshold	2019	2020	2021	2022	2023	2024	2025	2026	2027	2028	2029
អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប / PV of Total Public Debt													
ធៀបនឹងផលិតផលសរុបក្នុងស្រុក *to GDP*	Baseline	55%	21.3	21.2	21.1	21.4	20.5	21.4	22.2	22.8	23.1	23.3	23.5
	Sensitivity		21.3	22.5	24.6	26.0	26.0	28.0	29.9	31.4	32.6	33.7	34.8
	Customized		21.3	21.4	21.7	22.2	21.5	22.8	24.0	25.0	25.8	26.4	27.3
អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស/ PV of Public and Publicly Guaranteed External Debt													
ធៀបនឹងផលិតផលសរុបក្នុងស្រុក *to GDP*	Baseline	40%	21.3	21.2	21.1	21.3	20.4	21.4	22.1	22.6	22.9	23.0	23.2
	Sensitivity		21.3	25.5	33.1	32.6	30.5	31.0	31.2	31.2	31.0	30.6	29.8
	Customized		21.3	21.2	21.1	21.3	20.4	21.7	22.7	23.7	24.4	25.1	26.0
ធៀបនឹងការនាំចេញ *to Exports*	Baseline	180%	27.5	27.6	27.5	27.6	28.4	29.5	30.7	31.7	32.3	32.8	33.2
	Sensitivity		27.5	36.3	51.4	50.5	50.6	51.2	51.9	52.3	52.4	52.0	51.1
	Customized		27.5	27.6	27.5	27.6	28.4	30.0	31.9	33.6	35.0	36.3	38.2
អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស/ Public and Publicly Guaranteed External Debt Service													
ធៀបនឹងការនាំចេញ *to Exports*	Baseline	15%	1.5	1.6	1.7	1.8	1.8	1.8	1.8	1.8	1.9	1.9	1.9
	Sensitivity		1.5	1.8	2.2	2.6	2.6	2.5	2.5	2.4	2.6	2.8	3.3
	Customized		1.5	1.8	2.2	2.6	2.6	2.5	2.5	2.4	2.6	2.8	3.3
ធៀបនឹងចំណូលថវិកាជាតិ *to Revenue*	Baseline	18%	5.1	5.6	5.7	6.0	5.7	5.7	5.5	5.4	5.7	5.6	5.6
	Sensitivity		5.1	5.6	6.2	7.2	6.7	6.6	6.4	6.2	6.4	6.9	8.1
	Customized		5.1	5.6	6.2	7.2	6.7	6.6	6.4	6.2	6.4	6.9	8.1

៥.៤.២. សេណារីយ៉ូទី២ (ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី ២ ប៊ីលាន ទៅ ៣ ប៊ីលានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣)

- លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូមូលដ្ឋាន (Baseline Scenario) និងការវិភាគវេយិតភាព (Sensitivity Analysis) ដោយផ្អែកលើសន្និធិបំណុលសាធារណៈត្រឹមដំណាច់ឆ្នាំ២០១៨ (ដោយគិតទាំងបំណុលមរតក) បូកបន្ថែមនឹងការខ្ចីថ្មីតាមសេណារីយ៉ូទី២នេះ បង្ហាញថា៖ ពុំមានសូចនាករណាមួយក្នុងចំណោមសូចនាករបំណុលសាធារណៈទាំង ៥ ខ្ពស់ជាងអនុបាតគោលទេ ប៉ុន្តែ សូចនាករបំណុលសំខាន់ជាងគេ គឺអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស នឹងឡើងដល់រង្វង់ **៣៧ ភាគរយ** ចាប់ពីឆ្នាំ២០២៧ ទៅ ដែលកៀកនឹងអនុបាតគោលកម្រិត **៤០ ភាគរយ** ប្រសិនបើការនាំចេញរងការប៉ះទង្គិចខ្លាំង (Exports shock) [1]។

- លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ មានកំណើនថមថយ (Customized Scenario) ដោយផ្អែកលើសន្និធិបំណុលសាធារណៈត្រឹមដំណាច់ឆ្នាំ២០១៨ (ដោយគិតបញ្ចូលទាំងបំណុលមរតក) បូកបន្ថែមនឹងការខ្ចីថ្មីតាមសេណារីយ៉ូទី២នេះ បង្ហាញថា៖ នៅតែពុំមានសូចនាករណាមួយក្នុងចំណោមសូចនាករបំណុលសាធារណៈទាំង ៥ ឡើងខ្ពស់ជាងអនុបាតគោលនោះទេ ក្នុងនោះ សូចនាករបំណុលសំខាន់ជាងគេ គឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស សម្រាប់ឆ្នាំ២០១៩ - ២០២៩ មានខ្ពស់បំផុតត្រឹមរង្វង់ **៣៣ ភាគរយ** នៅឆ្នាំ២០២៩ ធៀបនឹងអនុបាតគោលកម្រិត **៤០ ភាគរយ**។


ដូចនេះ លទ្ធផលនៃការវិភាគខាងលើ បញ្ជាក់ឱ្យឃើញថា កម្ពុជាមានសមត្ថភាពខ្ចីថ្មីបន្ថែមបាន ក្នុងរង្វង់ពី **២ ប៊ីលាន** ទៅ **៣ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ដោយមិនប៉ះពាល់ដល់ស្ថានភាពបំណុលសាធារណៈនោះទេ ពោលគឺ នៅតែអាចបន្តរក្សាបាននូវ **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»** ប៉ុន្តែ ត្រូវប្រុងប្រយ័ត្នក្នុងករណីការនាំចេញរងការប៉ះទង្គិចខ្លាំង (Exports shock)។

---


[1] ជាបទដ្ឋានបច្ចេកទេសអន្តរជាតិ គេត្រូវពិនិត្យមើលបម្រែបម្រួលស្ថានភាពបំណុលសាធារណៈ ប្រសិនបើការនាំចេញរងការប៉ះទង្គិចខ្លាំង (Exports shock) ក្នុងរយៈពេល ២ឆ្នាំទៅមុខ គឺ ឆ្នាំ២០២០ - ២០២១។ ជាមួយ, Exports shock ត្រូវបានព្យាករដោយផ្អែកលើទិន្នន័យនៃការនាំចេញជាក់ស្តែងក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ (២០០៩ - ២០១៨) ដែលក្នុងនោះ៖ ការនាំចេញនៅឆ្នាំ២០២០ អាចនឹងធ្លាក់ចុះកម្រិត -១,១% និងនៅឆ្នាំ២០២១ អាចមានកំណើនត្រឹម ១,២%។

ក្រាហ្វទី៦- លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី២


ក- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ:សរុបធៀបនឹង ផសស




ខ- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹង ផសស




គ- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹងការនាំចេញ




ឃ- សេវាបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹង ការនាំចេញ



ង- សេវាបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹង ចំណូលចរិកាជាតិ





* *លទ្ធផលនៃការវិភាគនេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ*

តារាងទី៣៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី២

សូចនាករបំណុល Debt Indicator		អនុបាតគោល Threshold	2019	2020	2021	2022	2023	2024	2025	2026	2027	2028	2029
អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប/ PV of Total Public Debt													
ធៀបនឹងផលិតផលក្នុងស្រុក *to GDP*	Baseline	55%	21.4	21.5	22.0	22.8	22.7	24.5	26.2	27.7	28.8	29.7	30.5
	Sensitivity		21.4	22.9	25.5	27.6	28.3	31.4	34.2	36.8	38.8	40.6	42.3
	Customized		21.4	21.8	22.5	23.6	23.6	25.9	28.1	30.1	31.7	33.0	34.6
អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស/ PV of Public and Publicly Guaranteed External Debt													
ធៀបនឹងផលិតផលក្នុងស្រុក *to GDP*	Baseline	40%	21.4	21.5	22.0	22.8	22.6	24.4	26.1	27.5	28.6	29.4	30.1
	Sensitivity		21.4	25.9	34.0	34.1	32.7	34.1	35.2	36.2	36.7	36.9	36.8
	Customized		21.4	21.5	22.0	22.8	22.6	24.8	26.8	28.8	30.4	31.8	33.4
ធៀបនឹងការនាំចេញ *to Exports*	Baseline	180%	27.5	28.2	28.6	29.5	31.4	33.8	36.3	38.6	40.4	41.8	43.2
	Sensitivity		27.5	36.8	52.8	52.9	54.2	56.3	58.6	60.6	62.1	62.9	63.1
	Customized		27.5	28.2	28.6	29.5	31.4	34.4	37.6	40.8	43.5	46.0	49.1
អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស/ Public and Publicly Guaranteed External Debt Service													
ធៀបនឹងការនាំចេញ *to Exports*	Baseline	15%	1.5	1.6	1.7	1.8	1.9	1.9	1.9	2.0	2.2	2.2	2.3
	Sensitivity		1.5	1.8	2.2	2.6	2.7	2.7	2.7	2.7	2.9	3.2	3.8
	Customized		1.5	1.6	1.7	1.8	1.9	2.0	2.0	2.0	2.3	2.4	2.6
ធៀបនឹងចំណូលថវិកាជាតិ *to Revenue*	Baseline	18%	5.1	5.6	5.8	6.2	5.9	6.0	5.9	5.9	6.5	6.5	6.6
	Sensitivity		5.1	5.6	6.3	7.4	7.0	7.0	6.8	6.7	7.3	7.9	9.1
	Customized		5.1	5.6	5.8	6.2	5.9	6.1	6.1	6.1	6.9	7.0	7.3

៥.៤.៣. សេណារីយ៉ូទី៣ (ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី ២,៥ ប៊ីលាន ទៅ ៣,៥ ប៊ីលានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣)

- លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូមូលដ្ឋាន (Baseline Scenario) ដោយផ្អែកលើសន្និធិបំណុលសាធារណៈត្រឹមដំណាច់ឆ្នាំ២០១៨ (ដោយគិតទាំងបំណុលមរតក) បូកបន្ថែមនិងការខ្ចីថ្មីតាមសេណារីយ៉ូទី៣នេះ បង្ហាញថា៖ ពុំមានសូចនាករណាមួយក្នុងចំណោមសូចនាករបំណុលសាធារណៈទាំង ៥ ខ្ពស់ជាងអនុបាតគោលទេ ប៉ុន្តែ សូចនាករបំណុលសំខាន់ជាងគេ គឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនិង ផសស នឹងឡើងដល់រង្វង់ **៣៨ ភាគរយ** នៅឆ្នាំ២០២៨ ធៀបនឹងអនុបាតគោលកម្រិត **៤០ ភាគរយ**។ ទន្ទឹមនេះលទ្ធផលនៃការវិភាគវេទយិតភាព (Sensitivity Analysis) បង្ហាញថា៖ សូចនាករបំណុលសំខាន់ជាងគេ គឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស អាចនឹងឡើងផុតអនុបាតគោលកម្រិត **៤០ ភាគរយ** ក្នុងរង្វង់ពី **៤១ ភាគរយ** ទៅ **៤៦ ភាគរយ** ចាប់ពីឆ្នាំ២០២៤ ទៅ ប្រសិនបើកម្ពុជារងការប៉ះទង្គិច (Shock) ណាមួយ ក្នុងចំណោមករណីទាំង ៤ រួមមាន៖ ១) តម្លៃរូបិយវត្ថុជាតិនៅឆ្នាំបន្ទាប់ (២០២០) ធៀបនឹងរូបិយប័ណ្ណបំណុល ធ្លាក់ចុះ **៣០ ភាគរយ**, ២) ការនាំចេញរងការប៉ះទង្គិចខ្លាំង (Exports shock), ៣) កាតព្វកិច្ចបំណុលជាយថាហេតុ[2], និង ៤) កំណើនផសស ថមថយខ្លាំង[3]។

- លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ មានកំណើនថមថយ (Customized Scenario) ដោយផ្អែកលើសន្និធិបំណុលសាធារណៈត្រឹមដំណាច់ឆ្នាំ២០១៨ (ដោយគិតទាំងបំណុលមរតក) បូកបន្ថែមនឹងការខ្ចីថ្មីតាមសេណារីយ៉ូទី៣នេះ បង្ហាញថា៖ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស អាចនឹងឡើងដល់រង្វង់ **៤១ ភាគរយ** នៅឆ្នាំ២០២៩ ពោលគឺ ខ្ពស់ជាងអនុបាតគោលកម្រិត **៤០ ភាគរយ** បន្តិច។

ដូចនេះ លទ្ធផលនៃការវិភាគខាងលើ បញ្ជាក់ឱ្យឃើញថា ប្រសិនបើខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី **២,៥ ប៊ីលាន** ទៅ **៣,៥ ប៊ីលានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣ នោះស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា នឹងមិនអាចបន្តរក្សាបាននូវចីរភាពទេ ពោលគឺ អាចនឹងត្រូវប្រឈមនូវ **«ហានិភ័យកម្រិតមធ្យម»**។


---

[2] ជាបទដ្ឋានបច្ចេកទេសអន្តរជាតិ គេត្រូវពិនិត្យមើលបម្រែបម្រួលស្ថានភាពបំណុលសាធារណៈ ប្រសិនបើមានរងការប៉ះទង្គិចនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities Shock) នៅឆ្នាំបន្ទាប់ (២០២០)។ តាមការព្យាករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក Contingent Liabilities Shock របស់កម្ពុជា នៅឆ្នាំ២០២០ អាចមានទំហំប្រមាណ ១១,៣% នៃ ផសស ក្នុងនោះ៖ ៦,៣% កើតចេញពីការធានារបស់រដ្ឋលើគម្រោង PPP និង ៥% ពីវិស័យធនាគារនិងហិរញ្ញវត្ថុ។


[3] គេត្រូវពិនិត្យមើលបម្រែបម្រួលស្ថានភាពបំណុលសាធារណៈ ប្រសិនបើកំណើន ផសស រងការប៉ះទង្គិច (Real GDP Growth Shock) ក្នុងរយៈពេល ២ឆ្នាំទៅមុខ គឺ ឆ្នាំ២០២០ - ២០២១។ ជារួម, Real GDP Growth Shock ត្រូវបានព្យាករដោយផ្អែកលើទិន្នន័យនៃកំណើន ផសស ជាក់ស្តែងក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ (២០០៩ - ២០១៨) ដែល ផសស នៅឆ្នាំ២០២០ - ២០២១ អាចមានកំណើនដូចគ្នាត្រឹមកម្រិត ៤,១%។

ក្រាហ្វទី៧- លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី៣


ក- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ:សរុបធៀបនឹង ផសស




ខ- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹង ផសស




គ- តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹងការនាំចេញ



ឃ- សេវាបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹង ការនាំចេញ



ង- សេវាបំណុលសាធារណៈ:ក្រៅប្រទេសធៀបនឹង ចំណូលថវិកាជាតិ





* *លទ្ធផលនៃការវិភាគនេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ*

តារាងទី៤៖ លទ្ធផលនៃការវិភាគតាមសេណារីយ៉ូទី៣

សូចនាករបំណុល Debt Indicators		អនុបាតគោល Threshold	2019	2020	2021	2022	2023	2024	2025	2026	2027	2028	2029
អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប / PV of Total Public Debt													
ធៀបនឹងផលិតផលក្នុងស្រុក *to GDP*	Baseline	55%	21.7	23.2	25.4	28.1	29.0	31.8	34.2	36.1	37.3	38.2	38.9
	Sensitivity		21.7	24.6	29.3	33.3	35.2	39.3	42.9	45.9	48.2	50.0	51.6
	Customized		21.7	23.5	26.0	28.9	30.0	33.3	36.3	38.7	40.5	41.9	43.5
អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស/ PV of Public and Publicly Guaranteed External Debt													
ធៀបនឹងផលិតផលក្នុងស្រុក *to GDP*	Baseline	40%	21.7	23.2	25.4	28.0	28.9	31.7	34.1	35.9	37.1	37.9	38.5
	Sensitivity		21.7	29.1	28.4	31.8	33.4	37.0	**40.2**	**42.6**	**44.2**	**45.4**	**46.4**
	Customized		21.7	23.2	25.4	28.0	28.9	31.9	34.5	36.7	38.4	39.7	41.2
ធៀបនឹងការនាំចេញ *to Exports*	Baseline	180%	28.0	30.3	33.1	36.3	40.2	44.4	48.0	51.0	53.1	54.6	55.9
	Sensitivity		28.0	39.3	58.5	61.3	65.0	69.2	72.8	75.6	77.4	78.3	78.5
	Customized		28.0	30.3	33.1	36.3	40.2	44.2	48.4	52.0	54.9	57.4	60.5
អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស/ Public and Publicly Guaranteed External Debt Service													
ធៀបនឹងការនាំចេញ *to Exports*	Baseline	15%	1.5	1.6	1.8	2.0	2.2	2.3	2.2	2.3	2.6	2.7	2.8
	Sensitivity		1.5	1.8	2.4	2.9	3.0	3.1	3.0	3.0	3.4	3.8	4.5
	Customized		1.5	1.6	1.8	2.0	2.2	2.3	2.3	2.3	2.7	2.8	3.0
ធៀបនឹងចំណូលថវិកាជាតិ *to Revenue*	Baseline	18%	5.1	5.6	6.3	6.9	6.8	6.9	6.8	6.8	7.7	7.8	8.1
	Sensitivity		5.1	5.6	6.7	8.2	7.8	7.9	7.7	7.6	8.5	9.2	10.7
	Customized		5.1	5.6	6.3	6.9	6.8	7.0	6.9	6.9	8.0	8.1	8.6

ជំពូកទី៦
សន្និដ្ឋាន

ជាសន្និដ្ឋានរួម ផ្អែកតាមលទ្ធផលនៃការវិភាគចីរភាពបំណុលខាងលើ បង្ហាញថា៖

ក- សេណារីយ៉ូទី១៖ ទំហំនៃការខ្វីថ្មីបន្ថែម ក្នុងរង្វង់ **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ២,១ ប៊ីលាន ទៅ ២,៨ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»**។

ខ- សេណារីយ៉ូទី២៖ ទំហំនៃការខ្វីថ្មីបន្ថែម ក្នុងរង្វង់ **២ ប៊ីលាន** ទៅ **៣ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ២,៨ ប៊ីលាន ទៅ ៤,២ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»**។

គ- សេណារីយ៉ូទី៣៖ ទំហំនៃការខ្វីថ្មីបន្ថែម ក្នុងរង្វង់ **២,៥ ប៊ីលាន** ទៅ **៣,៥ ប៊ីលាន អេសដេអ៊ែរ** (សមមូលនឹងប្រមាណ ៣,៥ ប៊ីលាន ទៅ ៤,៩ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៩ - ២០២៣ ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានឹងមិនអាចបន្តរក្សាបាននូវចីរភាពទេ ពោលគឺ អាចនឹងត្រូវប្រឈមនូវ **«ហានិភ័យកម្រិតមធ្យម »**។

ដូចនេះ ក្នុងបរិការណ៍សេដ្ឋកិច្ចបច្ចុប្បន្ន, សម្រាប់ឆ្នាំ២០១៩-២០២៣ កម្ពុជាមានសមត្ថភាពខ្វីថ្មីបន្ថែមពីក្រៅប្រទេស ក្នុងរង្វង់ **១,៥ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ២,១ ប៊ីលាន ទៅ ២,៨ ប៊ីលានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ និងអាចកើនដល់ **៣ ប៊ីលានអេសដេអ៊ែរ** (សមមូលនឹងប្រមាណ ៤,២ ប៊ីលានដុល្លាអាមេរិក) ក្នុងករណីចាំបាច់ អាស្រ័យតាមវិឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែង ពោលគឺ អាចឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទាន ដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។ ទន្ទឹមនេះ ដើម្បីបន្តរក្សាចីរភាពបំណុលសាធារណៈក្នុងរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាបបាន លុះត្រាតែ៖

- សម្រិតសម្រាំងខ្វីតែឥណទានសម្បទាន ដែលមានហានិភ័យទាប និងខ្វីសម្រាប់តែវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង ហើយរាល់គម្រោងវិនិយោគសាធារណៈដែលនឹងត្រូវហិរញ្ញប្បទានដោយឥណទានសម្បទាន ត្រូវតែជាគម្រោងដែលមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។
- សម្រាប់ឆ្នាំ២០១៩ - ២០២៣ កំណើន ផសស នឹងសម្រេចបាន ក្នុងរង្វង់ ៧ ភាគរយ ហើយកំណើនចំណូលថវិកាជាតិ នឹងសម្រេចបាន ជាមធ្យម ០,៣ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ តាមគោលដៅកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ និងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។
- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវកម្មវិធីកែទម្រង់គន្លឹះៗ ដែលជាមូលដ្ឋាននៃការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ដូចជា៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈ, ២) កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, និង ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ល។

- បន្តពង្រឹងការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់ ជាពិសេស ហានិភ័យ ដែលអាចកើតចេញពីគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP និងវិស័យធនាគារនិងហិរញ្ញវត្ថុ៕

ផែនការអភិវឌ្ឍន៍
សមត្ថភាពស្ថាប័ន និងធនធានមនុស្ស
សម្រាប់
ការគ្រប់គ្រងបំណុលសាធារណៈ
២០១៩ - ២០២៣

មាតិកា

ជំពូកទី១៖ សេចក្តីផ្តើម ១

ជំពូកទី២៖ គោលបំណង, គោលដៅ, និងវិសាលភាព ៣

២.១. គោលបំណង ៣

២.២. គោលដៅ ៣

២.៣. វិសាលភាព ៣

ជំពូកទី៣៖ ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង ៤

៣.១. ចំណុចខ្លាំង ៤

៣.២. ចំណុចខ្សោយ ៤

៣.៣. កាលានុវត្តភាព ៥

៣.៤. ការគំរាមកំហែង ៥

ជំពូកទី៤៖ ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០១៩ - ២០២៣ ..... ៦

៤.១. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន ៦

៤.២. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពធនធានមនុស្ស ៦

ជំពូកទី៥៖ គម្រោងប៉ាន់ស្មានថវិកាចំណាយ សម្រាប់ការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០១៩ - ២០២៣ ..... ៨

ជំពូកទី១
សេចក្តីផ្តើម

ដោយយល់ច្បាស់ពីសារៈសំខាន់នៃកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ កន្លងមក រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ក្លាប់ជាឧបសម្ព័ន្ធ នៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ចំនួន ២លើក រួចមកហើយ គឺ ទាំងក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១ - ២០១៨ និងក្នុងយុទ្ធសាស្ត្របច្ចុប្បន្នកម្មស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨។

រាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ បានអនុវត្តដោយជោគជ័យនូវផែនការទាំង ២ ដំណាក់កាលខាងលើ ហើយបានធ្វើឱ្យសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ព្រមទាំងទទួលបានការកោតសរសើរ និងវាយតម្លៃខ្ពស់ពីដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជាៈ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, អង្គការសន្និសីទសហប្រជាជាតិសម្រាប់ពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (United Nations Conference on Trade and Development – UNCTAD), និងអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (Organization for Economic Co-operation and Development – OECD) ជាដើម។

ជាក់ស្តែង, នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន យើងមានមុខងារសំខាន់ៗទាំង ៣ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ រួចហើយ រួមមានៈ ១) ការិយាល័យជួរមុខ (Front Office), ២) ការិយាល័យជួរកណ្តាល (Middle Office), និង ៣) ការិយាល័យជួរក្រោយ (Back Office) ដែលស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនេះ យើងក៏កសាងបាននូវធនធានមនុស្ស ដែលមានសមត្ថភាពធ្វើកិច្ចការសំខាន់ៗជាច្រើនប្រកបដោយភាពជាម្ចាស់ ដូចជាៈ ១) ការកសាងបទដ្ឋានគតិយុត្ត; ២) ការរៀបចំឯកសារគោលនយោបាយ, យុទ្ធសាស្ត្រ, នីតិវិធី, និងទស្សនាទាន; ៣) ការផលិតរបាយការណ៍និងព្រឹត្តិបត្រស្ថិតិបំណុល; ៤) ការវិភាគចីរភាពបំណុល, ចង្កោមបំណុល, ធាតុអំណោយ, ហានិភ័យបំណុលពាក់ព័ន្ធ ដោយរួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ; និង ៥) កិច្ចការពាក់ព័ន្ធសំខាន់ជាច្រើនផ្សេងទៀត។

បើទោះបីជាមុខងារសំខាន់ៗទាំង ៣ នៃការគ្រប់គ្រងបំណុលសាធារណៈ ស្ថិតក្រោមឆត្ររួមនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយក៏ដោយ ក៏ប៉ុន្តែ បច្ចុប្បន្ន មុខងារការិយាល័យជួរមុខ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស និងបំណុលសាធារណៈក្រៅប្រទេស នៅមានភាពបែកខ្ញែកគ្នានៅឡើយ ដែលចាំបាច់ត្រូវមានការត្រួតពិនិត្យឡើងវិញ និងធ្វើសមាហរណកម្ម នាកាលៈទេសៈសមស្របណាមួយ តាមការចាំបាច់ ដើម្បីឱ្យការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា កាន់តែមានភាពរឹងមាំថែមទៀត។ ទន្ទឹមនេះ នៅក្នុងបរិការណ៍ថ្មីនៃការឡើងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដែលនាំឱ្យការគ្រប់គ្រងបំណុលសាធារណៈកាន់តែមានភាពស្មុគស្មាញជាងមុន, កម្ពុជាក៏មានភាពចាំបាច់ត្រូវយកចិត្តទុកដាក់ខ្លាំងក្លាថែមទៀត ក្នុងការបន្តពង្រឹងសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ផងដែរ ជាពិសេស លើការងារវិភាគស៊ីជម្រៅ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវ **«ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣»** សម្រាប់ប្រើប្រាស់ជាគ្រឹះវិស័យក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ និងឈានទៅដល់ការរៀបចំយុទ្ធសាស្ត្រស្តីពីការ

គ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ នាឆ្នាំ២០២៣ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាប។

ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ជាឧបករណ៍ដ៏មានសារៈសំខាន់ និងមិនអាចខ្វះបាន ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ ហើយផែនការនេះ ជា **«ឯកសាររស់»** ដែលអាចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់។

ជំពូកទី២
គោលបំណង, គោលដៅ, និងវិសាលភាព

២.១. គោលបំណង

ផែនការនេះ មានគោលបំណងបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាប។

២.២. គោលដៅ

ផែនការនេះ មានគោលដៅដាក់ចេញនូវផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ។

២.៣. វិសាលភាព

ផែនការនេះ មានវិសាលភាពគ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា។

ជំពូកទី៣
ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង

ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈបច្ចុប្បន្ន បើទោះជាមានកម្មវិធីកសាងសមត្ថភាពតាមអភិក្រមនានាជាច្រើនឆ្នាំកន្លងមកហើយក្តី ក៏កម្ពុជានៅតែមានភាពចាំបាច់ ក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សបន្ថែមទៀត សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារ ពិសេស កិច្ចការដែលមានលក្ខណៈស្មុគស្មាញ ដូចជា៖ ការវិភាគចីរភាពបំណុល, ការវិភាគចង្កោមបំណុល, ការគ្រប់គ្រងនិងតាមដានហានិភ័យបំណុលពាក់ព័ន្ធ, និងការរៀបចំយុទ្ធសាស្ត្របំណុលសាធារណៈ ក្រោយៗទៀត ជាដើម។

ក្នុងស្មារតីនេះ, ដើម្បីជាមូលដ្ឋានឈានទៅដាក់ចេញនូវផែនការសកម្មភាពបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ឆ្នាំ២០១៩ - ២០២៣ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងប្រាកដនិយម, រាជរដ្ឋាភិបាលបានវិភាគលើចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង (SWOT Analysis) ដូចខាងក្រោម៖

៣.១. ចំណុចខ្លាំង

- រាជរដ្ឋាភិបាលមានរបៀបវារៈគោលនយោបាយច្បាស់លាស់ ក្នុងការបន្តកសាង និងអភិវឌ្ឍប្រទេស ដូចបញ្ជាក់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលបានផ្តល់អាទិភាពទី១ លើ **មនុស្ស**។
- រាជរដ្ឋាភិបាលមានឆន្ទៈគោលនយោបាយខ្ពស់ ក្នុងការបន្តសកម្មអនុវត្តនូវកម្មវិធីកែទម្រង់គន្លឹះៗទាំង ៣ រួមមាន៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និង ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលក្នុងនោះក៏ផ្តោតសំខាន់លើការបន្តពង្រឹងគុណភាពស្ថាប័ន និងធនធានមនុស្សនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ផងដែរ។
- រចនាសម្ព័ន្ធស្ថាប័នបច្ចុប្បន្ននៃអង្គភាពគ្រប់គ្រងបំណុលសាធារណៈ មានភាពរឹងមាំ ដោយគ្របដណ្តប់នូវមុខងារសំខាន់ទាំង ៣ នៃការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ រួមមាន៖ ១) ការិយាល័យជួរមុខ (Front Office), ២) ការិយាល័យជួរកណ្តាល (Middle Office), និង ៣) ការិយាល័យជួរក្រោយ (Back Office)។
- សមត្ថភាពធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយមានភាពជាម្ចាស់ធ្វើកិច្ចការសំខាន់ៗជាច្រើនបាន ដូចជា៖ ការរៀបចំឯកសារបទដ្ឋានគតិយុត្ត, គោលនយោបាយ, និងយុទ្ធសាស្ត្រនានា, ព្រមទាំងការវិភាគ និងកិច្ចការពាក់ព័ន្ធជាច្រើនផ្សេងទៀត។
- មន្ត្រីពាក់ព័ន្ធភាគច្រើន មានទំនួលខុសត្រូវខ្ពស់ចំពោះតួនាទី និងភារកិច្ចរបស់ខ្លួន ព្រមទាំងមានឆន្ទៈមោះមុតក្នុងការអភិវឌ្ឍសមត្ថភាពជំនាញបន្ថែម។

៣.២. ចំណុចខ្សោយ

- មុខងារការិយាល័យជួរមុខ នៅមានភាពបែកខ្ញែកគ្នានៅឡើយ រវាងការគ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស និងបំណុលសាធារណៈក្រៅប្រទេស។
- មុខងារនៃការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការធានា ពុំទាន់មានលក្ខណៈប្រមូលផ្តុំនៅឡើយ។
- ថ្វីត្បិតតែ សមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ក្តី ក៏ប៉ុន្តែ ទាំងចំនួន និងកម្រិតសមត្ថភាពមន្ត្រី ជាពិសេស លើការងារវិភាគ

ស៊ីជម្រៅ និងការងារជំនាញពាក់ព័ន្ធមួយចំនួនទៀត នៅពុំទាន់អាចឆ្លើយតបបានតាមទំហំការងារជាក់ស្តែងនៅឡើយ។

- ភាគច្រើននៃមន្ត្រីថ្មី ដែលទើបត្រូវបានជ្រើសរើសឱ្យមកបំពេញការងារ មានតែចំណេះដឹងជំនាញទូទៅពោលគឺ ពុំធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈនៅឡើយ ទន្ទឹមនេះ ក៏នៅស្ទើរបទពិសោធន៍ការងារដែរ។

៣.៣. ការលុបបំបាត់

- **ផ្នែកបច្ចេកទេស៖** កម្ពុជាមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា (ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម) តាមរយៈការផ្តល់ជំនាញការអន្តរជាតិ ឬអ្នកជំនាញបច្ចេកទេស មកធ្វើបទបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ដើម្បីផ្តល់ចំណេះដឹងជំនាញ និងបទពិសោធន៍លើការងារគ្រប់គ្រងបំណុលសាធារណៈ និងការងារពាក់ព័ន្ធនានា។
- **ផ្នែកហិរញ្ញវត្ថុ៖** រាជរដ្ឋាភិបាលអាចប្រើប្រាស់ជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀតសម្រាប់ហិរញ្ញប្បទានមន្ត្រីពាក់ព័ន្ធទៅចូលរួមសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, ទស្សនកិច្ចសិក្សា, សន្និសីទ, វេទិកា ទាំងក្នុងស្រុក និងក្រៅប្រទេស និងសម្រាប់ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់។

៣.៤. ការគំរាមកំហែង

- ភាពទាក់ទាញខ្លាំងនៃការងារនៅតាមវិស័យឯកជន និងអង្គការ ស្ថាប័ននានា ដែលអាចជាបញ្ហាប្រឈមដ៏ចម្បង ក្នុងការរក្សាទុក និងស្រូបយកនូវធនធានមនុស្សល្អៗ ឱ្យនៅបន្ត និងមកបម្រើការងារ។
- ការផ្លាស់ប្តូរគោលនយោបាយជាយថាហេតុរបស់ដៃគូអភិវឌ្ឍន៍ ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់កម្ពុជា។
- ភាពវិវត្តឥតឈប់ឈរនៃវិស័យព័ត៌មានវិទ្យា ដែលកម្ពុជាអាចនឹងពិបាកក្នុងការបត់បែនបានភ្លាមៗនូវរបៀបរបបនៃការអនុវត្តការងារ។

ជំពូកទី៤
ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស
២០១៩ - ២០២៣

ក្នុងគោលបំណងបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាបក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តនូវផែនការសកម្មភាព ដូចតទៅ៖

៤.១. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន

បច្ចុប្បន្ន មុខងារនៃការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា ត្រូវបានបែងចែកជា ៣ រួមមាន៖ មុខងារការិយាល័យជួរមុខ, មុខងារការិយាល័យជួរកណ្តាល, និងមុខងារការិយាល័យជួរក្រោយ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ទោះជាយ៉ាងណាក្តី មុខងារការិយាល័យជួរមុខ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស និងបំណុលសាធារណៈក្រៅប្រទេស នៅមានភាពបែកខ្ញែកគ្នានៅឡើយ ដែលចាំបាច់ត្រូវមានការត្រួតពិនិត្យឡើងវិញ និងធ្វើសមាហរណកម្ម នាកាលៈទេសៈសមស្របណាមួយ តាមការចាំបាច់ ដើម្បីឱ្យការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា កាន់តែមានភាពរឹងមាំថែមទៀត។ ទន្ទឹមនេះ ក៏ត្រូវបន្តពង្រឹងមុខងារនៃការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការធានា ផងដែរ។

ដើម្បីគាំទ្រនូវការអនុវត្តមុខងារគន្លឹះនីមួយៗ នៃការគ្រប់គ្រងបំណុលសាធារណៈ ឱ្យកាន់តែមានភាពរឹងមាំ និងមានសមត្ថភាពពេញលេញ ក្នុងការបំពេញការងារ ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តនូវអកិក្រម ដូចខាងក្រោម៖

- បន្តអនុវត្តវិធានការចាំបាច់នានាក្នុងការរក្សាទុកមន្ត្រីមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់ ដែលមានស្រាប់ ឱ្យនៅបំពេញការងារ ដើម្បីបន្តនិរន្តរភាព។
- បន្តជ្រើសរើសមន្ត្រី និងមន្ត្រីកិច្ចសន្យាថ្មី ដែលមានសមត្ថភាពនិងឆន្ទៈវិជ្ជាជីវៈខ្ពស់បន្ថែមទៀត ប្រកបដោយតម្លាភាព និងភាពប្រកួតប្រជែង ឱ្យស្របតាមទំហំការងារជាក់ស្តែង។
- បន្តអនុវត្តការងារជាក្រុម, ប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ, ប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម, និងរៀនផង - ធ្វើផង។

៤.២. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពធនធានមនុស្ស

ដើម្បីពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការងារគ្រប់គ្រងបំណុលសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តនូវផែនការសកម្មភាព ដូចខាងក្រោម៖

- បន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពធនធានមនុស្ស លើមុខជំនាញសំខាន់ៗ ពាក់ព័ន្ធនឹងសមត្ថកិច្ចនៅតាមក្រសួង-ស្ថាប័ន របស់ខ្លួន ដូចជា៖
  - ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ (Medium Term Debt Management Strategy – MTDS)
  - ការវិភាគចីរភាពបំណុល (Debt Sustainability Analysis – DSA)
  - ការវិភាគចង្កោមបំណុល (Debt Portfolio Analysis – DPA)

- ការវិភាគថ្លៃ និងហានិភ័យ (Cost at Risk – CaR and Value at Risk – VaR)
- ការគណនាកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities Calculation)
- ការវិភាគកម្រិតសម្បទាននៃឥណទាន (Grant Element)
- ការវិភាគវិបត្តិបំណុលរបស់បណ្តាប្រទេសនានាលើសកលលោក
- ការគ្រប់គ្រងការធានា និងការផ្តល់ឥណទានរបស់រដ្ឋ
- ការរៀបចំបោះផ្សាយ និងដាក់លក់មូលបត្ររដ្ឋ និងសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ
- ការរៀបចំយន្តការបញ្ចៀស ឬបង្ការការខាតបង់តម្លៃហិរញ្ញវត្ថុ (Hedging Mechanism)
- ការតាមដាន និងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ
- ការរៀបចំនិតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ
- ការកត់ត្រា និងធ្វើឯកភាពទិន្នន័យបំណុល
- ការរៀបចំរបាយការណ៍ និងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ
- ការគ្រប់គ្រង និងថែរក្សាទិន្នន័យបំណុល
- ការរៀបចំការវាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈ (Debt Management Performance Assessment – DeMPA)
- ការវិភាគ និងវាយតម្លៃលើគម្រោងវិនិយោគសាធារណៈធំៗ និងស្មុគស្មាញតាមយន្តការ PPP
- ការវិភាគ និងវាយតម្លៃគម្រោងតាមវិធីសាស្ត្រតម្លៃនៃលុយ (Value for Money)
- ការបែងចែកហានិភ័យក្នុងគម្រោងវិនិយោគសាធារណៈ តាមយន្តការ PPP (Risk Allocation)
- ការវិភាគ និងវាយតម្លៃលើហានិភ័យថវិកានៃគម្រោង តាមយន្តការ PPP (PPP Fiscal Risk Assessment Model – PFRAM)
- ការគណនា និងវិភាគហិរញ្ញវត្ថុនៃគម្រោង (Project Financial Analysis)
- ការគ្រប់គ្រងរដ្ឋបាល, ការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មគម្រោង
- ការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Investment Management Assessment – PIMA)
- ការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ
- ការព្យាករសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ
- និងមុខជំនាញពាក់ព័ន្ធចាំបាច់ផ្សេងទៀត។

– បន្តបំពាក់បំប៉នសមត្ថភាពមន្ត្រីពាក់ព័ន្ធ តាមអភិក្រម ដូចខាងក្រោម៖

- **ការបណ្តុះបណ្តាលក្នុងស្រុក** ដែលរួមមាន៖ ១) ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញដែលបង្ហាត់បង្ហាញដោយជំនាញការអន្តរជាតិ ឬមន្ត្រីនៃស្ថាប័នជំនាញអន្តរជាតិនានា, ២) ការរៀបចំសិក្ខាសាលា, វេទិកា ឬសន្និសីទ ដោយមានចូលរួមពីជំនាញការជាតិ អន្តរជាតិ ឬមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ, និង ៣) ការសិក្សាតាមប្រព័ន្ធអ៊ីនធើណែត។
- **ការបណ្តុះបណ្តាលក្រៅប្រទេស** ដែលរួមមាន៖ ១) ការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ដែលរៀបចំដោយអង្គការ-ស្ថាប័នក្នុងតំបន់ ឬ អន្តរជាតិនានា, ២) ការចូលរួមសិក្ខាសាលា, វេទិកា ឬសន្និសីទក្នុងតំបន់ ឬអន្តរជាតិ លើប្រធានបទជំនាញពាក់ព័ន្ធ, និង ៣) ការធ្វើទស្សនកិច្ចសិក្សានៅតាមក្រសួង-ស្ថាប័នជំនាញនៃប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿននានាលើសកលលោក។ បន្ថែមលើនេះ ត្រូវរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុង ដើម្បីជាការចែករំលែកចំណេះដឹងបន្តពីមន្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ដល់មន្ត្រីពាក់ព័ន្ធផ្សេងទៀត។

ជំពូកទី៥
គម្រោងប៉ាន់ស្មានថវិកាចំណាយ សម្រាប់ការបន្តពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស ២០១៩ - ២០២៣

ឯកតា៖ ពាន់ដុល្លារអាមេរិក

ផែនការសកម្មភាព	ឆ្នាំទី១	ឆ្នាំទី២	ឆ្នាំទី៣	ឆ្នាំទី៤	ឆ្នាំទី៥	សរុប
១) ក្នុងស្រុក	**១៧៥**	**១៧៥**	**១៧៥**	**១៧៥**	**១៧៥**	**៨៧៥**
ក) វគ្គបណ្តុះបណ្តាលជំនាញ	៩០	៩០	៩០	៩០	៩០	៤៥០
ខ) សិក្ខាសាលា	៤០	៤០	៤០	៤០	៤០	២០០
គ) វេទិកា	២០	២០	២០	២០	២០	១០០
ឃ) សន្និសីទ	២០	២០	២០	២០	២០	១០០
ង) ការសិក្សាតាមប្រព័ន្ធអ៊ីនធើណែត	៥	៥	៥	៥	៥	២៥
២) ក្រៅប្រទេស	**៣០០**	**៣០០**	**៣០០**	**៣០០**	**៣០០**	**១ ៥០០**
ក) វគ្គបណ្តុះបណ្តាលជំនាញ	៥០	៥០	៥០	៥០	៥០	២៥០
ខ) សិក្ខាសាលា	៥០	៥០	៥០	៥០	៥០	២៥០
គ) វេទិកា	៥០	៥០	៥០	៥០	៥០	២៥០
ឃ) សន្និសីទអន្តរជាតិ	៥០	៥០	៥០	៥០	៥០	២៥០
ង) ទស្សនកិច្ចសិក្សា	១០០	១០០	១០០	១០០	១០០	៥០០
សរុប (១+២)៖	**៤៧៥**	**៤៧៥**	**៤៧៥**	**៤៧៥**	**៤៧៥**	**២ ៣៧៥**

អនុក្រឹត្យ
ស្តីពី
ការគ្រប់គ្រងបំណុលសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...១៣.១...អនក្រ/បក

អនុក្រឹត្យ

ស្តីពី

ការគ្រប់គ្រងបំណុលសាធារណៈ

ꕥ ꕥ ꕥ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤/អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ . _

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវ គោលការណ៍ណែនាំ គោលនយោបាយ យុទ្ធសាស្ត្រ មុខងារគ្រប់គ្រង យន្តការគ្រប់គ្រង និងបទប្បញ្ញត្តិនានាស្តីពីការ គ្រប់គ្រងបំណុលសាធារណៈ ។

មាត្រា ២ . _

អនុក្រឹត្យនេះមានគោលបំណង ៖

១- ធានាថា ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានអនុវត្តដោយអនុលោម តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ធនាគារជាតិនៃកម្ពុជា ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងបទប្បញ្ញត្តិ ពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

២- កំណត់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឲ្យបាននូវ ៖

- ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច
- ការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទាន ដោយរក្សាហានិភ័យ និង បន្ទុកសេវាបំណុលសាធារណៈឲ្យនៅកម្រិតអប្បបរមា
- ការរួមចំណែកអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣- កំណត់គោលដៅ និងគោលការណ៍នៃការខ្ចីប្រាក់ពីគេ និងនៃការធានារបស់រដ្ឋ ។

៤- កំណត់គោលការណ៍រៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

៥- កំណត់គោលការណ៍រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

៦- កំណត់គោលការណ៍រៀបចំរបាយការណ៍គណនេយ្យ ស្តីពីបន្ទុកសេវាបំណុលសាធារណៈ ស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ។

៧- ធានាលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋឲ្យបានត្រឹមត្រូវ តាមរយៈការធ្វើប្រតិភូកម្ម និងការត្រួតពិនិត្យរាល់សកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

មាត្រា ៣ . _

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើប្រតិបត្តិការដូចខាងក្រោម ៖

១- ការផ្តល់សិទ្ធិអំណាច ការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រងបំណុលសាធារណៈ

២- ការខ្ចីប្រាក់ពីក្នុង និង ក្រៅប្រទេស

៣- ការបោះផ្សាយមូលបត្ររដ្ឋលើទីផ្សារហិរញ្ញវត្ថុក្នុងប្រទេស

៤- ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ

៥- ការឱ្យប្រាក់គេខ្ចី

៦- ការធានា និងការកត់ត្រាកាតព្វកិច្ចបំណុលជាយថាហេតុ

៧- ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា

៨- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ

៩- កិច្ចបញ្ជិកា និងការរៀបចំរបាយការណ៍បំណុលសាធារណៈ ។

មាត្រា ៤ . _

និយមន័យនៃវាក្យស័ព្ទសម្រាប់ប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដោយសន្ធានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

ជំពូកទី ២

សិទ្ធិអំណាច ការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវ

មាត្រា ៥ . _

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចចាត់ចែងលើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

មាត្រា ៦ . _

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងស្ថិតក្រោមអំណាចនាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការវិនិយោគ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា ការឲ្យប្រាក់គេខ្ចី និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ។

លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និង ទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

មាត្រា ៧ . _

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិធ្វើប្រតិភូកម្មអំណាចដល់មន្ត្រីមួយ ឬច្រើនរូប ដើម្បីបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ។ ការធ្វើប្រតិភូកម្មអំណាចត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

មាត្រា ៨ . _

វៀរលែងតែមានបដិប្បញ្ញត្តិដោយច្បាប់ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចខ្ចីប្រាក់ពីគេសម្រាប់បម្រើឲ្យគោលដៅ ដូចខាងក្រោម ៖

១- ហិរញ្ញប្បទានលើគម្រោងអាទិភាព ដែលមានកំណត់ក្នុងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល

២- បន្តពង្រឹងការគ្រប់គ្រងគោលនយោបាយថវិកា

៣- ផ្តល់ឲ្យសហគ្រាសសាធារណៈខ្ចី

៤- ផ្តល់ឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុខ្ចី ដោយធ្វើការពិគ្រោះយោបល់ជាមួយធនាគារជាតិនៃកម្ពុជាជាមុន

៥- ហិរញ្ញប្បទានលើឱនភាពថវិកា

៦- ទទួលបាននូវរូបិយប័ណ្ណបរទេស

៧- ហិរញ្ញប្បទានលើបំណុលដែលដល់ឥណប្រតិទាន

៨- ផ្តល់ឲ្យរដ្ឋបរទេសខ្ចី ។

មាត្រា ៩ . _

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិបត្តិការណាមួយដែលនាំឲ្យកើតមានបំណុលសាធារណៈបាន លុះត្រាតែធ្វើឡើងស្របតាមគោលការណ៍ និងលក្ខខណ្ឌកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១០ . _

រាល់ការដោះស្រាយកាតព្វកិច្ចបំណុលសាធារណៈរបស់រដ្ឋ ត្រូវធ្វើឡើងតាមគោលការណ៍ស្មើភាពចំពោះគ្រប់ម្ចាស់បំណុលទាំងអស់ ។

វៀរលែងតែមានបដិប្បញ្ញត្តិដោយច្បាប់ រាជរដ្ឋាភិបាលមិនត្រូវយកធនធាន ឬទ្រព្យសម្បត្តិរដ្ឋ ឬចំណូលរដ្ឋ ធ្វើជាកម្មវត្ថុនៃការបញ្ចាំក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការផ្តល់ការសន្យាឬការធានាណាមួយ ដែលនាំឲ្យកើតកាតព្វកិច្ចបំណុលបានទេ ។ ធនធាន ឬទ្រព្យសម្បត្តិរដ្ឋ ឬចំណូលរដ្ឋ ត្រូវទទួលបាននូវការការពារដោយរាជរដ្ឋាភិបាលពីការរឹបអូស ឬការឃាត់ទុកផ្សេងៗ ។

មាត្រា ១១ . _

រាជរដ្ឋាភិបាល ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានភារកិច្ចរៀបចំនិងត្រួតពិនិត្យ

ការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ និងពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈមុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ត្រូវមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ។

មាត្រា ១២ . _

រាល់ការងារបច្ចេកទេសនិងប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា ក្នុងនាមជាភ្នាក់ងារគ្រប់គ្រងមូលបត្ររដ្ឋរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៣ . _

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដើម្បីគ្រប់គ្រងការបោះផ្សាយនិងការទូទាត់សងមូលបត្ររដ្ឋ និងការងារពាក់ព័ន្ធផ្សេងទៀត ។

អនុញ្ញាតឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មអំណាចពាក់ព័ន្ធនឹងប្រតិបត្តិការ និងការគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ជូនទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

មាត្រា ១៤ . _

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដើម្បីពិនិត្យ ពិភាក្សា និងលើកយោបល់ជូនគណៈកម្មាធិការចម្រុះសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ស្តីពីការរៀបចំក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ព្រមទាំងកិច្ចប្រតិបត្តិការនិងការគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ។

មាត្រា ១៥ . _

គណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវមានសមាជិកយ៉ាងច្រើន ៩រូប ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងសមាជិកជាមន្ត្រីជាន់ខ្ពស់ ដែលមានសមាសភាពមកពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ផ្អែកតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងប្រធានស្ថាប័នពាក់ព័ន្ធ ។

គណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវដឹកនាំដោយអគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវមានលេខាធិការដ្ឋានសម្រាប់តាមដានត្រួតពិនិត្យលើប្រតិបត្តិការពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្ររដ្ឋ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

មាត្រា ១៦ . -

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវទទួលបន្ទុកលើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋមិនអាចជួញដូរបាន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៧ . -

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា តាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ជំពូកទី ៣
បំណុលសាធារណៈ ការខ្ចីប្រាក់តែខ្លី និងការធានិយោគ

មាត្រា ១៨ . -

រាល់ការខ្ចីប្រាក់ពីគេ ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ការធានា និងកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវធ្វើឡើងស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់ស្តីពីមូលបត្ររដ្ឋ ។

រាល់ការងារបច្ចេកទេស និងប្រតិបត្តិការពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ការបោះផ្សាយនិងការដាក់

លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ការធានា និងកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ និងតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។

មាត្រា ១៩ . _

រាល់ការដកសាច់ប្រាក់ ការចាត់ចែង និងការទូទាត់សេវាបំណុលសាធារណៈក្រៅប្រទេស ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌ និងនីតិវិធី ដែលមានចែងក្នុងកិច្ចព្រមព្រៀងឥណទាន និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ត្រូវអនុវត្តតាមច្បាប់ស្តីពីមូលបត្ររដ្ឋ ។

ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ត្រូវអនុវត្តតាមសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។ ការចាត់ចែង និងការទូទាត់សេវាបំណុលនៃសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចព្រមព្រៀង ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២០ . _

ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាល គឺជាអ្នកផ្តល់ការធានាជាលាយលក្ខណ៍អក្សរលើកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬគម្រោងដែលអនុវត្តដោយសហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

រាល់សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានាពីរាជរដ្ឋាភិបាល ត្រូវទូទាត់កម្រៃធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀតជូនរាជរដ្ឋាភិបាល ។

គោលនយោបាយកំណត់កម្រៃធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀត ព្រមទាំងកាតព្វកិច្ចរបាយការណ៍របស់សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាល់ការចរចាពាក់ព័ន្ធនឹងការធានា ត្រូវធ្វើឡើងដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយកកម្រៃពីការធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀត សម្រាប់ជាគុណប្រយោជន៍នៃចំណូលថវិការដ្ឋ និងការគ្រប់គ្រងបំណុលសាធារណៈ ។

មាត្រា ២១ . _

សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានាពីរាជរដ្ឋាភិបាល តែការធានានោះត្រូវបានដកហូតមកវិញ ដោយសារការខកខានមិនបានបំពេញកាតព្វកិច្ចសេវាបំណុលតាមកិច្ចព្រមព្រៀង ត្រូវមានកាតព្វកិច្ចទូទាត់ជូនរាជរដ្ឋាភិបាលនូវរាល់ការចំណាយពាក់ព័ន្ធរួមមាន ៖ សេវាបំណុល ប្រាក់ពិន័យ និងចំណាយពាក់ព័ន្ធផ្សេងទៀត ។

មាត្រា ២២ . _

រាល់ការឱ្យប្រាក់គេខ្ចី ត្រូវធ្វើឡើងស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្រោមទម្រង់ជាកិច្ចព្រមព្រៀងឥណទានដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាល ឬតាមការប្រទានសិទ្ធិ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

រាល់ឥណទាយិក ដែលទទួលបានហិរញ្ញប្បទានឥណទានពីរាជរដ្ឋាភិបាល ត្រូវទូទាត់សេវាបំណុលជូនរាជរដ្ឋាភិបាល ។

គោលនយោបាយកំណត់លក្ខខណ្ឌនៃការឲ្យប្រាក់គេខ្ចី និងកាតព្វកិច្ចរបាយការណ៍របស់ឥណទាយិក ដែលទទួលបានហិរញ្ញប្បទានឥណទានពីរាជរដ្ឋាភិបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាល់ការងារបច្ចេកទេស និងប្រតិបត្តិការពាក់ព័ន្ធនឹងការឱ្យប្រាក់គេខ្ចី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២៣ . _

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចនាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិក្នុងការវិនិយោគដោយ

ប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា ក្រោមទម្រង់ជាការវិនិយោគលើសញ្ញាប័ណ្ណរដ្ឋ អធិបតេយ្យនៃរដ្ឋបរទេស និងការវិនិយោគលើអចលកម្មហិរញ្ញវត្ថុផ្សេងៗ ។

ជំពូកទី ៤
ការទូទាត់សេវាបំណុលសាធារណៈ

មាត្រា ២៤ . _

រាល់ការទូទាត់សេវាបំណុលសាធារណៈ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងកិច្ចព្រមព្រៀងឥណទាន ។

មាត្រា ២៥ . _

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចព្យាករណ៍សេវាបំណុលសាធារណៈស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

មាត្រា ២៦ . _

រាល់ការទូទាត់សេវាបំណុលសាធារណៈ ត្រូវធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែការទូទាត់ដោយប្រើមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដែលត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ។

នីតិវិធី និងយន្តការនៃការទូទាត់សេវាបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៥
យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ

មាត្រា ២៧ . _

យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលចែងអំពីគោលដៅគ្រប់គ្រងបំណុលសាធារណៈរយៈពេលមធ្យម ឬវែង របស់រាជរដ្ឋាភិបាល អនុលោមតាមបរិបទនៃក្របខ័ណ្ឌគោលនយោបាយថវិកា ស្ថានភាពបំណុលបច្ចុប្បន្ន និង

ផែនការតម្រូវការហិរញ្ញប្បទាន ដោយរក្សាហានិភ័យ និងបន្ទុកសេវាបំណុលសាធារណៈ ឲ្យនៅកម្រិតអប្បបរមា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈរៀងរាល់ ៥ឆ្នាំម្តង ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈពិនិត្យយល់ព្រម មុននឹងសុំការសម្រេចពីនាយករដ្ឋមន្ត្រី ។

យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ អាចត្រូវបានធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ។

មាត្រា ២៨ . _

រាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ត្រូវអនុវត្តអនុលោមតាមយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

មាត្រា ២៩ . _

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចផ្សព្វផ្សាយជាសាធារណៈនូវខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

ទម្រង់ និងខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣០ . _

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចតាមដានរាល់សូចនាករសំខាន់ៗនៃបំណុលក្រៅប្រទេសនិងបំណុលសាធារណៈ និងវិភាគចីរភាពបំណុលរៀងរាល់ ២ឆ្នាំម្តង ។ ការវិភាគចីរភាពបំណុល អាចត្រូវបានធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ។

មាត្រា ៣១ . _

យន្តការ និងវិធីសាស្ត្រក្នុងការវិភាគចីរភាពបំណុល និងការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៦
កិច្ចបញ្ជិកា និង ការរៀបចំរបាយការណ៍

មាត្រា ៣២ . _

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចធ្វើកិច្ចបញ្ជិកានូវរាល់ប្រតិបត្តិការហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគណនីរតនាគារជាតិ ស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ។

មាត្រា ៣៣ . _

វិធាននៃកិច្ចបញ្ជិកាគណនេយ្យ ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣៤ . _

អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចេញផ្សាយជាផ្លូវការនូវព័ត៌មានស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ។

ទម្រង់ និងខ្លឹមសារនៃព័ត៌មានស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៧
ទោសប្បញ្ញត្តិ

មាត្រា ៣៥ . _

មន្ត្រីសាធារណៈគ្រប់ជាន់ថ្នាក់ ដែលត្រូវបានរកឃើញថា មិនបានគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ៣៦ . _

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៧ . _

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឲ្យ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចមាត្រា ៣៧
- ឯកសារ-កាលប្បវត្តិ

បានឃើញសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

តាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សព្វាវុធ្រមសម្រាប់ប្រើប្រាស់ក្នុង
អនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

ការខ្ចីប្រាក់ពីគេ (Borrowing) សំដៅដល់ប្រតិបត្តិការដូចខាងក្រោម ៖

១- ការបោះផ្សាយមូលបត្ររដ្ឋ

២- ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ

៣- ការចុះកិច្ចព្រមព្រៀងឥណទានជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឬរដ្ឋាភិបាលបរទេស ឬ ភ្នាក់ងារឥណទានរបស់រដ្ឋាភិបាលបរទេស

៤- ការចុះកិច្ចព្រមព្រៀងឥណទានជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៥- ការខ្ចីប្រាក់ពីធនាគារជាតិនៃកម្ពុជា សម្រាប់ហិរញ្ញប្បទានលើឱនភាពថវិការយៈពេលខ្លី ស្របតាមលក្ខខណ្ឌកំណត់នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

៦- ការចុះកិច្ចព្រមព្រៀងឥណទានផ្សេងទៀត ។

រាល់ការទិញជំពាក់នូវទំនិញ ឬសេវា ដែលមានរយៈពេល តិចជាងឬស្មើ ១៨០ថ្ងៃ គិតចាប់ពីថ្ងៃទិញ មិនត្រូវបានចាត់ទុកជាការខ្ចីប្រាក់ពីគេឡើយ ។

ការគ្រប់គ្រងបំណុលសាធារណៈ (Public Debt Management) សំដៅដល់ការគ្រប់គ្រងលើរាល់ប្រតិបត្តិការរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹង ការខ្ចីប្រាក់ពីគេ ការឲ្យប្រាក់គេខ្ចី ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការធានា កាតព្វកិច្ចបំណុលជាយថាហេតុ ការទូទាត់សេវាបំណុល ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ ការគ្រប់គ្រងហានិភ័យ ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា និងប្រតិបត្តិការផ្សេងទៀតពាក់ព័ន្ធនឹងបំណុលសាធារណៈ។

កាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liability) សំដៅដល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលក្នុងការទូទាត់សំណង ប្រសិនបើមានព្រឹត្តិការណ៍

ជាក់លាក់ណាមួយកើតឡើងនាពេលអនាគត ដូចជា ការធានា ការរ៉ាប់រង ការទូទាត់សំណងអន្តរាយ ការបង់វិភាគទានដើម្បីធានាសមាជិកភាពកម្ពុជាក្នុងអង្គការអន្តរជាតិនានា និងការផ្តល់សំណងតាមបណ្តឹងនីត្យានុកូល ។

ការធានា (Guarantee) សំដៅដល់កាតព្វកិច្ចទូទាត់សេវាបំណុលរបស់សហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលរាជរដ្ឋាភិបាលបានធានាសងជំនួសនូវការប្រាក់ ឬប្រាក់ដើម ឬទាំងការប្រាក់និងប្រាក់ដើម ព្រមទាំងកម្រៃពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដែលសហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ ពុំមានលទ្ធភាពបំពេញកាតព្វកិច្ចទូទាត់សេវាបំណុល ។

ការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ (Debt Restructuring) សំដៅដល់ ការធ្វើហិរញ្ញប្បទានឡើងវិញចំពោះបំណុលបច្ចុប្បន្ន ការបំប្លែងបំណុល ការបង្រួមបំណុល ការទូទាត់សងបំណុលមុនឥណប្រតិទាន ការរៀបចំកម្មវិធីសងបំណុលឡើងវិញ ការរំកិលបំណុល ការទិញបំណុលមកវិញ និងការដោះដូរបំណុល ដើម្បីកាត់បន្ថយបន្ទុកសេវាបំណុល និងហានិភ័យ ។ វាក្យស័ព្ទដែលប្រើសម្រាប់និយមន័យនេះត្រូវបានកំណត់ដូចខាងក្រោម ៖

- **ការបំប្លែងបំណុល** (Debt Conversion) សំដៅដល់ការដោះដូរបំណុលដើម្បីទទួលបានជាថ្នូរមកវិញនូវទុនវិនិយោគ សម្រាប់ហិរញ្ញប្បទានលើគម្រោង ឬការអនុវត្តគោលនយោបាយអាទិភាពបន្ទាន់ណាមួយ ។

- **ការបង្រួមបំណុល** (Debt Consolidation) សំដៅដល់ការបោះផ្សាយនិងដាក់លក់បំណុលថ្មី ដើម្បីហិរញ្ញប្បទានដល់ការប្រមូលទិញបំណុលបច្ចុប្បន្នមកវិញ ក្នុងគោលដៅកាត់បន្ថយចំនួនប័ណ្ណរតនាគារ ឬសញ្ញាប័ណ្ណរតនាគារ ។ ប្រតិបត្តិការនេះច្រើនប្រើនៅក្នុងទីផ្សារមូលបត្រក្នុងប្រទេស ។

- **ការទូទាត់សងមុន** (Prepayment) សំដៅដល់ការអនុវត្តសិទ្ធិក្នុងការទូទាត់សងប្រាក់ដើមមុនឥណប្រតិទានតាមតម្លៃចារឹក ឬដោយមានបន្ថែមប្រាក់ពិន័យ ដូចមានចែងក្នុងកិច្ចព្រមព្រៀងឥណទាន ។

- **ការរំកិលបំណុល** (Rolling Over) សំដៅដល់ការបោះផ្សាយ និងដាក់លក់បំណុលថ្មី សម្រាប់ទូទាត់សងបំណុលបច្ចុប្បន្នដែលដល់ឥណប្រតិទាន ។ ប្រតិបត្តិការនេះច្រើនប្រើសម្រាប់ការដាក់លក់ប័ណ្ណរតនាគារ ។

- **ការដោះដូរបំណុល** (Debt Swap) សំដៅដល់ការប្តូរពីកាតព្វកិច្ច

បំណុលមួយទៅកាតព្វកិច្ចបំណុលមួយផ្សេងទៀត ដែលមានរចនាសម្ព័ន្ធបំណុលផ្សេងគ្នា ដូចជា ៖ រូបិយប័ណ្ណ ឬអត្រាការប្រាក់ ឬឥណប្រតិទាន ។

ការវនិយោគ (Investments) សំដៅដល់ការទិញសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យនៃរដ្ឋបរទេស ឬការវិនិយោគលើអចលកម្មហិរញ្ញវត្ថុផ្សេងទៀត ដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា ។

ការឱ្យប្រាក់តេឌ្ឋី (Lending and Onlending) សំដៅដល់ប្រាក់របស់រដ្ឋ ឬប្រាក់ដែលរដ្ឋខ្ចីពីគេ ឬហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ សម្រាប់ឲ្យសហគ្រាសសាធារណៈ ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬរដ្ឋបរទេសខ្ចី ក្នុងគោលដៅជម្រុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (Annual Financial Management Law) គ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋ ។

បំណុលក្រៅប្រទេស (External Debt) សំដៅដល់បំណុលក្រៅប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជាដែលរួមមាន ៖ បំណុលសាធារណៈ បំណុលផ្នែកឯកជន និងបំណុលដែលរដ្ឋាភិបាលមុនមិនទាន់បានដោះស្រាយ ។

បំណុលសាធារណៈ (Public Debt) សំដៅដល់បំណុលរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត និងដោយមិនរាប់បញ្ចូលបំណុលដែលពុំមានការធានាពីរាជរដ្ឋាភិបាល។

ភ្នាក់ងារគ្រប់គ្រងមូលបត្ររដ្ឋ (Government Securities Management Agency – GSMA) សំដៅដល់ធនាគារជាតិនៃកម្ពុជាដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋតាមការធ្វើប្រតិភូកម្មអំណាចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋមិនអាចជួញដូរបាន ។

មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ (Government Securities Management Fund – GSMF) សំដៅដល់ប្រាក់ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាល និងប្រាក់ដែលបានមកពីស្ថាប័នឯកជន និងសាធារណៈតាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ។

មូលបត្ររដ្ឋមិនអាចជួញដូរបាន (Non-marketable Securities) សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឲ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬសន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាពនិងការកំណត់របស់ប្រកាសដែលដាក់ឲ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អ្នកកាន់កាប់មូលបត្រ ឬសន្តតិជនពេញសិទ្ធិ មានសិទ្ធិស្នើសុំការទូទាត់សង

មុនឥណប្រតិទាន ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ ។

មូលបត្ររដ្ឋ **(Government Securities)** សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ ឬ ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះ ផ្សាយក្នុងនាមរាជរដ្ឋាភិបាល។ មូលបត្ររដ្ឋរួមមាន ៖

១- ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ

២- សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ

៣- សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់ជាមួយនឹងអត្រាអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ

៤- មូលបត្ររដ្ឋដែលមិនអាចជួញដូរបាន

៥- មូលបត្ររដ្ឋផ្សេងៗដទៃទៀត ដែលបោះផ្សាយស្របតាមច្បាប់អនុញ្ញាត ។

សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ **(Sovereign Bonds)** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុ បញ្ជាក់ពីការទទួលស្គាល់បំណុល ដែលត្រូវបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលលើ ទីផ្សារអន្តរជាតិ ។

សេវាបំណុល **(Debt Service)** សំដៅដល់ការទូទាត់ប្រាក់ដើម ការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀតនៃកាតព្វកិច្ចបំណុល ។

សហគ្រាសសាធារណៈ **(Public Enterprise)** សំដៅដល់សហគ្រាសដែល មានដើមទុនទាំងអស់ឬភាគច្រើនជារបស់រដ្ឋ ។ សហគ្រាសសាធារណៈមានបេសកកម្ម បង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធាន ធម្មជាតិ និងការបង្កើតអាជីព ។

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មាធិការ
គ្រប់គ្រងបំណុលសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤២.សសរ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១._

បង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈមានសមាសភាព ដូចខាងក្រោម÷

១-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ	**អូន ព័ន្ធមុនីរ័ត្ន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ប្រធាន
២-ឯកឧត្តម	**ទង្សី វិសិទ្ធ**	រដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធានប្រចាំការ
៣-លោកជំទាវ	**ងាវ ចំន្ទថារ៉ា**	ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា	អនុប្រធាន
៤-ឯកឧត្តម	**ហែម វណ្ណឌី**	អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
៥-លោកជំទាវ	**ស្រ៊ី ស៊ុយុត**	អគ្គពិនិត្យ ធនាគារជាតិនៃកម្ពុជា	សមាជិក
៦-លោកជំទាវ	**ជា សិរី**	អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា	សមាជិក
៧-ឯកឧត្តម	**ម៉ែន ធីរុទ្ធ**	អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក។

ប្រការ២._

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល មានមុខងារ និងភារកិច្ច ដូចតទៅ÷

- រៀបចំ និងត្រួតពិនិត្យការអនុវត្តចក្ខុវិស័យ និងគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- ពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ មុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី
- ធ្វើជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលគោលនយោបាយពាក់ព័ន្ធ ដើម្បីធានាឱ្យមានសង្គតិភាពរវាងកិច្ចដំណើរការគ្រប់គ្រងបំណុលសាធារណៈ ជាមួយនឹងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ, ថវិកា, និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល។

ប្រការ៣._

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេល ៦ (ប្រាំមួយ) ខែមួយដង តាមការអញ្ជើញរបស់ប្រធាន ឬអាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ។

ប្រការ៤._

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចបង្កើតគណៈកម្មការ ឬក្រុមការងារផ្សេងៗទៅតាមការចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាព កម្មវិធីនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ។

ប្រការ៥._

ប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមិនមែនជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យចូលរួមប្រជុំតាមតម្រូវការចាំបាច់នៃការងារ។

ប្រការ៦._

ក្នុងករណីអវត្តមានសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈអាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីចាត់តាំងមន្ត្រីពាក់ព័ន្ធឱ្យចូលរួមប្រជុំជំនួស។ សមាជិកគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារគ្រប់គ្រងបំណុលសាធារណៈ ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ។

ប្រការ៧._

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មាននាយកដ្ឋានគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋានបំពេញមុខងារជាសេនាធិការបច្ចេកទេសរបស់ខ្លួនក្នុងការបំពេញការងារ។

ប្រការ៨._

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន។

ប្រការ៩._

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១០._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៨កើត ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ១០
-រាជកិច្ច
-ឯកសារ - កាលប្បវត្តិ

សមាសភាព

ក្រុមការងារបច្ចេកទេសរៀបចំ

យុទ្ធសាស្ត្រស្តីពី

ការគ្រប់គ្រងបំណុលសាធារណៈ

២០១៩ - ២០២៣

*យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ ត្រូវបានរៀបចំ និងព្រាងឡើងដោយ **ក្រុមការងារបច្ចេកទេសរបស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អសប) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ** ដែលបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១១ សសរ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ តាមទស្សនៈគិតគូរដែងឆ្ងាយប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។*

*ក្រុមការងារបច្ចេកទេសនេះ ដឹកនាំផ្ដាល់ដោយឯកឧត្តម **ម៉ែន ឆិរុទ្ធ** អគ្គនាយក នៃ អសប និងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដែលរួមមាន៖*

ក- <u>ក្រុមវិភាគ និងរៀបចំ</u>

១-	លោក	**ម៉ាច សុតារ៉ា**	ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ
២-	លោក	**ហ៊ុល បុណ្ណារ័ត្ន**	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី
៣-	លោកស្រី	**ឈុន ឌីរៈវឌ្ឍនា**	ប្រធានការិយាល័យវិភាគបំណុល
៤-	លោក	**ខៀវ ណាង៉ា**	ប្រធានការិយាល័យទូទាត់សេវាបំណុល
៥-	លោកស្រី	**ឌុន ម៉ូនីតា**	អនុប្រធានការិយាល័យវិភាគបំណុល
៦-	លោក	**ជាង សុភុទ្ធី**	អនុប្រធានការិយាល័យវិភាគបំណុល
៧-	លោក	**យ៉ន ហ៊ុន**	អនុប្រធានការិយាល័យរដ្ឋបាល និងព័ត៌មានវិទ្យា
៨-	លោក	**ឆួន សុភាឥណ្ណា**	មន្ត្រីបច្ចេកទេសនៃការិយាល័យវិភាគបំណុល
៩-	លោក	**អ៊ុន ពិសិដ្ឋ**	ជំនាញការផ្នែកវិភាគបំណុល
១០-	កញ្ញា	**ខឿន ឥត្តិឈរគ្រីស្ទីនា**	ជំនាញការផ្នែកវិភាគបំណុល
១១-	លោក	**ឥដ្ឋ ពេជ្រវិសាល**	ជំនាញការផ្នែកវិភាគបំណុល
១២-	លោក	**គន សេងហ៊ាន់**	ជំនាញការផ្នែកព័ត៌មានវិទ្យា

ខ- <u>ក្រុមគាំទ្រ</u>

១-	លោកស្រី	**ស៊ុន ណាលី**	អគ្គនាយករង នៃ អសប
២-	លោក	**យ៉ែន សុធា**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល
៣-	លោកស្រី	**ឆាយ សុវណ្ណារី**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល
៤-	លោកស្រី	**អ៊ុន ឌៀ**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល
៥-	លោកស្រី	**គង់ សោភី**	ប្រធានការិយាល័យរដ្ឋបាល និងព័ត៌មានវិទ្យា
៦-	លោកស្រី	**ហាស់ ជាណា**	អនុប្រធានការិយាល័យទូទាត់សេវាបំណុល
៧-	លោកស្រី	**សឿម ស្រីលក្ខណ៍**	អនុប្រធានការិយាល័យទូទាត់សេវាបំណុល
៨-	កញ្ញា	**ណាង៉ា ឆារីរតន៍**	ជំនួយការផ្នែកគ្រប់គ្រងបំណុល
៩-	លោកស្រី	**ផល ស្រីណែត**	ជំនួយការផ្នែកគ្រប់គ្រងបំណុល
១០-	លោក	**សុវណ្ណ តារៈ**	ជំនួយការផ្នែកគ្រប់គ្រងបំណុល